សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# តួនាទីអភិបាលក្នុងក្រុមហ៊ុនមូលធន

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **អ៊ុខ ជាហ្វា**

**ក. សុខ ដួរ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ព្រុំ រិទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាម យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២៣ (អាហារូបករណ៍) ក្រុម $L_4B_2$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ទាំងពីររូបរួមមាន ខ្ញុំបាទឈ្មោះ **អ៊ុង ដារ៉ា** និងនាងខ្ញុំឈ្មោះ **សុខ ដួរ**។

## យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

លោក **ឪពុក** និងអ្នក **ម្តាយ** របស់យើងទាំងពីរ ដែលលោកទាំងពីរបានផ្តល់កំណើត និង ជីវិតដែលពោរពេញទៅដោយអត្ថន័យ។ ក្រៅពីផ្តល់ជីវិតដល់រូបកូន លោក ឪពុក និងអ្នកម្តាយបាន លះបង់ពេលវេលា កម្លាំងកាយ និងកម្លាំងចិត្តក្នុងការយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ ផ្តល់ភាពកក់ក្តៅ និងផ្តល់នូវដំបូន្មានល្អៗដល់រូបកូនដើម្បីជាទុនក្នុងការរស់នៅក្នុង សង្គម ក៏ដូចជាការសិក្សា។ ទង្វើរបស់លោកទាំងពីរបានធ្វើអោយកូនមិនអាចភ្លេចនូវអំពើល្អ និង គុណូបការៈដ៏សែនធំរកអ្វីប្រៀបផ្ទឹមពុំបាន។

គណៈគ្រប់គ្រងសាលា សាស្ត្រាចារ្យ លោកគ្រូ និងអ្នកគ្រូដែលបានបង្រៀនយើងទាំងពីរ តាំងពីថ្នាក់តូចដល់ថ្នាក់បរិញ្ញាបត្រ ដែលលោកបានខិតខំបង្ហាត់បង្រៀនយើងខ្ញុំ ផ្តល់ការទូន្មាន ប្រៀនប្រដៅ និងណែនាំផ្លូវល្អៗសម្រាប់ពេលអនាគត។ ជាពិសេសបានផ្តល់ចំណេះដឹងតាមរយៈ ការបង្ហាត់បង្រៀនដោយមិនគិតពីការនឿយហត់។

លោកសាស្ត្រាចារ្យ **ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះដែល លោកគ្រូបានចំណាយកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃរបស់លោកក្នុងណែនាំផ្តល់នូវ គំនិតយោបល់ ដំបូន្មាន វិធីសាស្ត្រល្អៗដែលពាក់ព័ន្ធនឹងប្រធានបទ និងកែលម្អទៅលើចំណុច ខ្វះខាតរបស់យើងទាំងពីរ តាំងពីដើមរហូតដល់យើងខ្ញុំទាំងពីរបានចងក្រងស្នាដៃនេះឡើង។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យ ដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ដែលបានចូលរួមចំណែកឲ្យសារណាបញ្ចប់ការសិក្សា ស្តីពី **តួនាទីអភិបាលក្នុងក្រុមហ៊ុនមូលធន** ឲ្យបានលេចចេញជារូបរាងឡើង ឲ្យមានសុខភាព ល្អ មានសុភមង្គល និងមានអាយុយឺនយូរគ្រប់ៗគ្នា។

# អារម្ភកថា

ក្រោយពីបានសិក្សា និងទទួលបានការបណ្តុះបណ្តាលលើផ្នែកទ្រឹស្តី ពីសំណាក់លោកសាស្ត្រាចារ្យនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមកនេះ ក្នុងចំណោមមុខវិជ្ជា ដែលយើងខ្ញុំទាំងពីរបានចាប់អារម្មណ៍ទៅលើ គឺផ្នែកក្រុមហ៊ុន ដែលជាកត្តាជម្រុញទឹកចិត្ត និងសម្រេចចិត្តជ្រើសរើសប្រធានបទនេះឡើង ដែលមានចំណងជើងថា **តួនាទីអភិបាលក្នុងក្រុមហ៊ុនមូលធន** ដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សា។ ដោយយល់ឃើញថា នៅក្នុងការដឹកនាំក្រុមហ៊ុនមូលធនប្រកបដោយភាពជោគជ័យ គឺអភិបាលជាកត្តាចំបង ព្រោះអភិបាលប្រៀបបានដូចក្បាលម៉ាស៊ីនដែលមាន អំណាចសម្រេចលើកិច្ចការពាណិជ្ជកម្មក្រុមហ៊ុន។

បន្ថែមពីនេះ ការអនុវត្តតួនាទីរបស់អភិបាលនៅប្រទេសកម្ពុជា មិនទាន់ឃើញមានលក្ខណៈណាមួយស្តង់ដារនៅឡើយទេ បើទោះបីជានៅក្នុងច្បាប់ស្តីសហគ្រាសពាណិជ្ជកម្មបានចែងក៏ដោយ ក៏ការអនុវត្តនៅមានភាពចន្លោះខ្វះខាតដោយមិនដឹងពីមូលហេតុនៃការខ្វះខាតបទប្បញ្ញត្តិគ្រប់គ្រងវិស័យនេះ ឬ មូលហេតុណាមួយទេ។ ដូចនេះ តួនាទីនេះពិតជាចំណុចសំខាន់ ក្នុងការធ្វើអោយក្រុមហ៊ុនមួយទទួលបានប្រសិទ្ធិភាពក្នុងដំណើរការក្រុមហ៊ុន។ ហើយជាក់ស្តែង នៅប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងទៅលើវិស័យក្រុមហ៊ុន ដែលជាវិស័យឯកជនមួយដ៏សំខាន់ ក្នុងការជួយអភិវឌ្ឍប្រទេសជាតិក៏ដូចជា ការជួយសម្រួលការងារជាច្រើន ដល់ប្រជាពលរដ្ឋផងដែរ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំសង្ឃឹមថា សារណានេះនឹងបានផ្តល់នូវប្រយោជន៍ដល់ និស្សិតជំនាន់ក្រោយអាចយកទៅសិក្សាបន្ត ព្រមជាមួយគ្នានេះដែរ យើងខ្ញុំពិតជាមានជំនឿជឿជាក់ថា លទ្ធផលនៃការស្រាវជ្រាវនេះនឹងមានភាពចន្លោះខ្វះខាតផងដែរ ក្រុមយើងខ្ញុំក៏រីករាយនឹងទទួលការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និង មិត្តអ្នកអានទាំងអស់ដោយក្តីរីករាយបំផុត។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ ឥរិយាបថរបស់អភិបាល** ........ ៥

**ផ្នែកទី១៖ តួនាទីរបស់អភិបាល** ........ ៧

**១.១.តួនាទីការយកចិត្តទុកដាក់** ( Duty of Care) ........ ៨

**១.២. តួនាទីភក្តីភាព**( Duty of Loyalty ) ........ ១០

**ផ្នែកទី២៖ សិទ្ធិ និងអំណាចរបស់អភិបាល** ........ ១២

**២.១.សិទ្ធិ និងអំណាចអភិបាលតាមច្បាប់** ........ ១៥

**២.២ សិទ្ធិ និងអំណាចអភិបាលតាមលក្ខន្តិកៈ** ........ ១៦

**ផ្នែកទី៣៖ ទំនាក់ទំនងអភិបាល និងភាគីពាក់ព័ន្ធ** ........ ១៨

**៣.១.ទំនាក់ទំនងអភិបាល និងភាគហ៊ុនិក** ........ ២០

**៣.២.ទំនាក់ទំនងរវាងអភិបាល និងក្រុមប្រឹក្សាភិបាល** ........ ២៣

**ជំពូកទី២៖ ការទទួលខុសត្រូវរបស់អភិបាល** ........ ២៩

**ផ្នែកទី១៖ ការប្រព្រឹត្តខុសតួនាទីរបស់អភិបាល** ........ ៣១

**១.១.ការល្មើសសិទ្ធិ និងអំណាចស្របច្បាប់** ........ ៣២

**១.២.កំហុសនៃការដឹកនាំ** ........ ៣៥

**ផ្នែកទី២៖ ការទទួលខុសត្រូវរដ្ឋប្បវេណី** ........ ៣៩

**២.១.ការទទួលខុសត្រូវរបស់អភិបាលក្នុងនីតិការខារ** ........ ៤០

២.២.តួនាទីអភិបាលនៅក្នុងដំណាក់កាលធនក្ស័យក្រុមហ៊ុន.................................... ៤៥
ផ្នែកទី៣៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អភិបាល.......................................... ៤៧
៣.១.បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត............... ៤៩
៣.២.បទស៊ីសំណូករបស់អភិបាលជាអាទិ៍........................................................ ៥៣
សេចក្តីសន្និដ្ឋាន.................................................................................................... ៥៦
អនុសាសន៍.............................................................................................................. ៥៨
ឯកសារយោង
ឧបសម្ព័ន្ធ

# ពាក្យសរសេរកាត់

| | |
|---|---|
| Above n | Above footnote number |
| ASEAN | Association of Southeast Asian Nation |
| Below n | Below footnote number |
| CEO | Chief Executive Director |
| CSX | Cambodia Securities Exchange |
| Ibidem | Ibid |
| SECC | Securities and Exchange Commission of Cambodia |
| WTO | World Trade Organization |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ |
| ក្រមរដ្ឋប្បវេណី | ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ |
| ច្បាប់ការងារ | ច្បាប់ការងារឆ្នាំ១៩៩៧ |
| ច្បាប់សហគ្រាសពាណិជ្ជកម្ម | ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ |

# សេចក្តីផ្តើម

នៅមុនការបង្កើតច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ រាល់ការចុះបញ្ជីពាណិជ្ជកម្ម ឬ ការកំណត់អំពីក្រុមហ៊ុន មានតែច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មប៉ុណ្ណោះដែលត្រូវយកមកអនុវត្តដែលជាផ្នែកមួយនៅក្នុងវិស័យក្រុមហ៊ុន។[1] ច្បាប់នេះមិនមានភាពទូលំទូលាយដែលអាចគ្របដណ្តប់លើផ្នែកទាំងអស់ពាក់ព័ន្ធនឹងច្បាប់ក្រុមហ៊ុននោះទេ។ មកដល់ឆ្នាំ២០០៣ កម្ពុជាបានត្រៀមខ្លួនចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក World Trade Organization (WTO) ហើយនៅក្នុងបរិបទនៃការវិនិយោគ កម្ពុជាត្រូវទទួលយកនូវគោលការណ៍មួយចំនួននៃ WTO។[2] នៅក្នុងនោះ ទាក់ទងនឹងប្រព័ន្ធច្បាប់កម្ពុជា WTO បានដាក់នូវគោលការណ៍គ្រោងនឹងបង្កើតឲ្យមានច្បាប់ដែលអាចទាក់ទាញនូវការវិនិយោគ និងបង្កើនសេដ្ឋកិច្ចជាតិផងដែរ។[3] មកដល់ឆ្នាំ២០០៥ ជាសមិទ្ធផល កម្ពុជាបានបង្កើតច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលច្បាប់នេះមានភាពទូលំទូលាយ និងកំណត់និយមន័យក្រុមហ៊ុនស្របច្បាប់រួមមានបញ្ញត្តិដូចជា តួនាទីរបស់អភិបាល និងភាគហ៊ុនិក ទំនួលខុសត្រូវ និងការទទួលខុសត្រូវរបស់ភាគហ៊ុនិក និងអភិបាលផងដែរ។[4] ច្បាប់នេះក៏បានបង្កើតផ្លូវសម្រាប់ទីផ្សារមូលបត្រនៅពេលអនាគត នៅឆ្នាំ២០១១ កម្ពុជាបានបង្កើតឲ្យមានផ្សារមូលបត្រកម្ពុជា Cambodia Securities Exchange (CSX)។[5] ទន្ទឹមនឹងនេះ កម្ពុជាត្រូវបានជំរុញឲ្យមានអភិបាលកិច្ចនៅក្នុងការគ្រប់គ្រងក្រុមហ៊ុន ជាពិសេសទៅលើក្រុមហ៊ុនមូលធន និងក្រុមហ៊ុនដែលមានបំណងចូលខ្លួនទៅក្នុងទីផ្សារមូលបត្រកម្ពុជា។[6] គណៈកម្មការមូលបត្រកម្ពុជា Securities and Exchange Commission of Cambodia (SECC) មានចេញនូវប្រកាសដែលជាការដាក់ឲ្យក្រុមហ៊ុនយកជាមូលដ្ឋានក្នុងការអនុវត្ត ដើម្បីត្រៀមខ្លួនចូលទីផ្សារ

---

[1] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងចុះបញ្ជីពាណិជ្ជកម្ម,លេខ នស/រកម/១១៩៩/១២, ១៨ វិច្ឆិកា ១៩៩៩, មាត្រា ១០ថ្មី។

[2] MPDF, “A Summary of Cambodia’s WTO Agreement”, *Business Issue Bulletin* 6 (2005), 2.

[3] MPDF, "កិច្ចព្រមព្រៀងជាមួយអង្គការពិភពលោក (WTO) របស់កម្ពុជា (ការពិនិត្យមើលកាតព្វកិច្ចនីតិកម្ម)", *ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្ម* ១០ (២០០៥), ១។

[4] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១ (ចាប់ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម)។ See also, Janna Hamilton, "NA passes law on commercial enterprises," *Phnom Penh Post*, 20 May 2005), Available at: https://www.phnompenhpost.com/ national/na-passes-law-commercial-enterprises.

[5] Ibid.

[6] May Kunmakara, “Cambodia urged to focus on good corporate governance,” Khmer Times , January 23, 2018, Available at: https://www.khmertimeskh.com/50103714/cambodia-urged-to-focus-on-good-corporate-governance/.

ផងដែរ ហើយវាក៏ជាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុនមូលធននៅកម្ពុជាផងដែរ។[7] មកដល់ពេលនេះ ក្រុមហ៊ុនមួយចំនួន ក៏បានអនុវត្តទៅតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងប្រកាសផ្សេងៗពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម។[8]

ម៉្យាងវិញទៀត អភិបាលកិច្ចសាជីវកម្មនេះ ត្រូវបានជំរុញឲ្យមាននៅក្នុងក្រុមហ៊ុននៅកម្ពុជានាពេលបច្ចុប្បន្ន ពីព្រោះមានការសិក្សាបានបង្ហាញថា ក្រុមហ៊ុននៅក្នុងស្រុកជាច្រើន បានកត់សម្គាល់ឃើញថា ពុំមានអភិបាលកិច្ចសាជីវកម្មតាមស្តង់ដាណាមួយដែលអាចចាត់ទុកថា ត្រឹមត្រូវទៅតាមច្បាប់តម្រូវនោះទេ។[9] នេះបង្ហាញឲ្យឃើញនូវផលវិបាកមួយចំនួនចំពោះអ្នកវិនិយោគ និងអ្នកគ្រប់គ្រងពិបាកក្នុងការបំពេញកាតព្វកិច្ច។[10] ការជំរុញឲ្យកម្ពុជាយកចិត្តទុកដាក់លើវិស័យនេះ វាមានផលប្រយោជន៍សម្រាប់សេដ្ឋកិច្ច និងកំណើននៃវិស័យឯកជនរីកចម្រើន វាក៏នាំឲ្យមានក្រុមហ៊ុនអន្តរជាតិជាច្រើនធ្វើការបណ្តាក់ទុន និងចុះបញ្ជីនៅកម្ពុជា ហើយផ្សារហ៊ុននឹងមានការកើនឡើងជាលំដាប់។[11] បើយោងតាមវេទិកាដែលរៀបចំដោយគណៈកម្មការមូលបត្រកម្ពុជា (SECC) បានបង្ហាញថា ក្រុមហ៊ុនដែលមានវប្បធម៌អភិបាលកិច្ចសាជីវកម្មរឹងមាំ គឺជាយុទ្ធសាស្ត្រមួយដែលនាំឲ្យបុគ្គលិកម្នាក់ៗយល់ដឹងកាន់តែច្បាស់ អំពីតួនាទី និង មុខងាររបស់ខ្លួននៅក្នុងក្រុមហ៊ុន និងជួយឲ្យក្រុមហ៊ុនប្រើប្រាស់នូវធនធានប្រកបដោយប្រសិទ្ធភាព និងបញ្ចៀសនូវវិបត្តិផ្សេងៗបានល្អ។[12] មិនតែប៉ុណ្ណោះ ការចូលជាសមាជិកអាស៊ាន ASSOCIATION OF SOUTHEAST ASIAN NATION (ASEAN) របស់កម្ពុជាក៏ធ្វើឲ្យកម្ពុជាកាន់តែត្រូវយកចិត្តទុកដាក់លើការពង្រឹងសេដ្ឋកិច្ចរបស់ខ្លួនដែរ។[13] ទន្ទឹមគ្នានេះ ASEAN Economic Community មានគោលដៅពង្រឹងច្បាប់ទាក់ទងនឹងអភិបាលកិច្ចសាជីវកម្ម និងទីផ្សារនៅក្នុងតំបន់ ដោយលើកឡើងថា ASEAN គឺជាតំបន់មួយ ដែលត្រូវចាត់ទុកគោលការណ៍នៃអភិបាលកិច្ចសាជីវកម្មនេះជាវិស័យអាទិភាព។[14] នៅក្នុងឆ្នាំ២០១៥ ការជួបជុំផ្តើមគំនិតមួយដែលធ្វើឡើងនៅប្រទេសវៀតណាម ទាក់ទងនឹង

[7] Hor Kimsay, "Regulator pushes for corporate governance," *Phnom Penh Post*, 12 April 2017, Available at: https://www.phnompenhpost.com/business/regulator-pushes-corporate-governance.

[8] Ibid.

[9] Ibid.

[10] Ibid.

[11] Austin Tyler, Junior Policy Analyst and et al, "OECD-Southeast Asia Corporate Governance Initiative", (Hanoi, Vietnam, Issue Paper 12-13 May 2015), 15.

[12] May Kunmakara, above n 6.

[13] Siv Meng, "A year on, Cambodia has gained little from the AEC integration," *Phnom Penh Post*, 15 December 2016 Available at: https://www.phnompenhpost.com/post-property/year-cambodia-has-gained-little-aec-integration.

[14] Cheng Sokhorng, "Firms flimsy on corporate governance," *Phnom Penh Post*, 05 August 2016, Available at: https://www.phnompenhpost.com/business/firms-flimsy-corporate-governance. See also, Austin Tyler, Junior Policy Analyst and et al, above n 11, 14.

អភិបាលកិច្ចសាជីវកម្មនៅតំបន់ ASEAN បានលើកឡើងជាសំខាន់ទៅលើប្រទេសចំនួនបួនគឺ ប្រទេសកម្ពុជា វៀតណាម ឡាវ និងមីយ៉ាន់ម៉ា ក្នុងការពង្រឹងនូវវិធានច្បាប់ទាក់ទងនឹងបញ្ហានៃអភិបាលកិច្ចល្អ។[15]

នៅក្នុងអត្ថបទនេះនឹងធ្វើការសិក្សាតែទៅលើអភិបាលកិច្ចសាជីវកម្មនៅកម្ពុជា តាមពិតទៅអភិបាលកិច្ចសាជីវកម្មនេះ នៅក្នុងវិស័យផ្សារមូលបត្រវាគ្រាន់តែជាស្តង់ដាមួយបន្ថែមពីអ្វីដែលមានស្រាប់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មតែប៉ុណ្ណោះ។ សម្រាប់ក្រុមហ៊ុនមូលធនទោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្តី ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតក្តីបោះមូលបត្រលក់ទៅសាធារណៈក្តី មិនបោះមូលបត្រលក់ក្តី ក៏តម្រូវឲ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួនដែរ។[16] ប៉ុន្តែអ្វីដែលសំខាន់ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិតត្រូវបានកំណត់អំពីរចនាសម្ព័ន្ធគ្រប់គ្រងមួយចំនួនដូចជា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក និងកិច្ចប្រជុំមហាសន្និបាតរបស់ក្រុមប្រឹក្សាភិបាលជាដើម។[17] ក្រុមហ៊ុនមួយចំនួនដែលមានអាជីវកម្មទាក់ទងនឹងអាជីវកម្មធនាគារ ធានារ៉ាប់រង និងក្រុមហ៊ុនឥណទាន ត្រូវតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។[18]

មូលហេតុសំខាន់ ដែលនាំឲ្យជ្រើសយកប្រធានបទនេះ ក្រៅពីការជំរុញដោយអង្គការអន្តរជាតិទាក់ទងនឹងវិស័យនេះ ក៏មានមូលហេតុចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហានៃការគ្រប់គ្រងដែលមានទាំងភាគហ៊ុនិក និងអភិបាលនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះផងដែរ។ ជាឧទាហរណ៍ ក្រុមហ៊ុនហិរញ្ញវត្ថុចំនួនបី រួមមាន Asean Instrument Foundation, Investment Consultant Association និង Empire Big Capital បានធ្វើពាណិជ្ជកម្មរបស់ខ្លួនដោយឆបោកប្រជាពលរដ្ឋជាច្រើន ជនរងគ្រោះបានដាក់ពាក្យបណ្តឹងជាក្រុមទៅរាជរដ្ឋាភិបាលប្រឆាំងនឹងទង្វើដែលប្រព្រឹត្តដោយអភិបាល និងអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនទាំងបីខាងលើនេះ។[19] មួយវិញទៀត អត្ថបទក៏មានលើកឡើងអំពីបញ្ហាទាក់ទងនឹងបទដ្ឋានគតិយុត្តិនៅកម្ពុជាក្នុងទំហំនៃការទទួលខុសត្រូវរបស់អភិបាលក្រុមហ៊ុន ដោយបង្ហាញថា នៅកម្ពុជាការយល់ដឹងរបស់អភិបាលនៅក្នុង

[15] Austin Tyler, Junior Policy Analyst and et al, above n 11, 2.

[16] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ៨៧។

[17] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២៨, ១២៩, ២០៧។

[18] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ៨៥។

[19] Hor Kimsay, “Suits filed over ponzi schemes,” *Phnom Penh Post*, 31 May 2017, Available at: https://www.phnompenhpost.com/business/suits-filed-over-ponzi-schemes. See also, Kong Meta, “Number of plaintiffs in Empire Big Capital fraud suit up to 900,” *Phnom Penh Post*, 08 January 2018, Available at: https://www.phnompenh post.com/national/number-plaintiffs-empire-big-capital-fraud-suit-900.

ក្រុមហ៊ុនចំពោះតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅមានកម្រិត។[20] នៅក្នុងច្បាប់ពាក់ព័ន្ធនឹងបញ្ហានេះអភិបាលមានតួនាទីច្រើន ហើយការទទួលខុសត្រូវមានទំហំតូចផងធំផង ចាប់ពីការទទួលខុសត្រូវដែលពិន័យជាទឹកប្រាក់ និងពិន័យដោយការដាក់ពន្ធនាគារផង។[21] អភិបាល និងអ្នកគ្រប់គ្រងក្រុមហ៊ុនក៏មានការភ្ញាក់ផ្អើល នៅពេលដែលពួកគេអាចនឹងទទួលខុសត្រូវផ្ទាល់ចំពោះអំពើទាំងឡាយដែលបានប្រព្រឹត្ត ឬ មិនគោរពតាមបទប្បញ្ញត្តិមួយចំនួនដូចជា អភិបាលកិច្ចសាជីវកម្ម និងការតម្រូវចំពោះផ្នែករដ្ឋបាលនៅក្នុងក្រុមហ៊ុន ក្នុងការប្រាកដថាក្រុមហ៊ុនបានអនុវត្តត្រូវនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ។[22]

អត្ថបទនេះនឹងធ្វើការដោះស្រាយថាតើ ការទទួលខុសត្រូវរបស់អភិបាលនៅក្នុងទំហំនៃការគ្រប់គ្រងរបស់ខ្លួនមានអ្វីខ្លះ នៅក្នុងច្បាប់របស់ប្រទេសកម្ពុជានៅពេលដំណើរការក្រុមហ៊ុន។ សំណួរមួយទៀតដែលអត្ថបទនេះនឹងឆ្លើយនោះ តើតួនាទី និងឥរិយាបថរបស់អភិបាលនាំឲ្យអភិបាលមានការទទួលខុសត្រូវដូចម្ដេច? សំណួរមួយវិញទៀតនោះ តើនៅក្នុងឋានៈជាអភិបាលត្រូវមានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធណាខ្លះនៅក្នុងក្រុមហ៊ុន? អត្ថបទនេះក៏លើកឡើងអំពីបញ្ហាដែលអាចកើតមានឡើងទាក់ទិននឹង ការប្រតិបត្តិតួនាទីរបស់អភិបាលនៅក្នុងប្រទេសកម្ពុជាដោយសារមូលហេតុមួយចំនួនដែលជាបទពិសោធន៍របស់ប្រទេសម៉ាឡេស៊ី និងតៃវ៉ាន់ ក៏ដូចជាសាធារណរដ្ឋប្រជាមានិតចិន។ ដើម្បីពិភាក្សាលើបញ្ហានេះ និងឆ្លើយនឹងសំណួរនៃប្រធានបទអត្ថបទនេះធ្វើការបែងចែងជាពីរជំពូក។ **(ជំពូកទី១)** បកស្រាយអំពីឥរិយាបថនៃការគ្រប់គ្រងរបស់អភិបាលដោយក្នុងជំពូកនេះនឹងមានការសិក្សាទៅលើ សិទ្ធិ និងអំណាចរបស់អភិបាល តួនាទីរបស់អភិបាល និងទំនាក់ទំនងរវាងអភិបាល និងភាគីពាក់ព័ន្ធ។ ចំណែកឯ **(ជំពូកទី២)** ពន្យល់ទៅលើការទទួលខុសត្រូវរបស់អភិបាល ក្នុងជំពូកនេះនឹងលើកពីសកម្មភាពដែលកំណត់ថាជាសកម្មភាពដែលខុសតួនាទីរបស់អភិបាល ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

[20] DFDL law firm, *A Look at Cambodia's Legal Framework for Company Director Liability*, (10 November 2011), Available at: https://www.dfdl.com/resources/legal-and-tax-updates/a-look-at-cambodias-legal-framework-for-company-director-liability/.
[21] Ibid.
[22] Ibid.

# ជំពូកទី១៖ ឥរិយាបថរបស់អភិបាល

អភិបាល គឺជាអ្នកគ្រប់គ្រង ឬ ដឹកនាំនៅក្នុងក្រុមហ៊ុនមូលធន ឬ ម្យ៉ាងទៀតអភិបាល គឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនដែលមានភារកិច្ចក្នុងការគ្រប់គ្រងសកម្មភាព និងកំណត់ទិសដៅទាំងឡាយនៅក្នុងក្រុមហ៊ុន។[23] នៅក្នុងការគ្រប់គ្រងសកម្មភាពក្រុមហ៊ុន អភិបាលមានសិទ្ធិ និងអំណាចក្នុងការបំពេញសកម្មភាពសម្រាប់ និងក្នុងនាមជាក្រុមហ៊ុន។[24] រាល់សកម្មភាពរបស់អភិបាល គឺត្រូវតែជាផលប្រយោជន៍របស់ក្រុមហ៊ុន និងសម្រាប់គោលបំណងរបស់ក្រុមហ៊ុនដើម្បីភាពជោគជ័យ និងភាពរីកចម្រើនរបស់ក្រុមហ៊ុនទាំងមូល។[25] គោលបំណងរបស់ក្រុមហ៊ុនបានសម្រេច ឬ អត់នោះ វាអាស្រ័យទាំងស្រុងទៅលើសកម្មភាពរបស់អភិបាលក្នុងការដឹកនាំ និងគ្រប់គ្រង។[26] នៅក្នុងក្រុមហ៊ុនត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ហើយអភិបាលជាអ្នកមានទំនួលខុសត្រូវក្នុងការអនុវត្ត។[27] អភិបាលនៅពេលខ្លះមិនអាចជាភ្នាក់ងារទេ ព្រោះអភិបាលដើរតួនាទីក្នុងនាមជាក្រុមហ៊ុន គ្មានអភិបាលណាម្នាក់អាចធ្វើសកម្មភាពក្នុងនាមជាភ្នាក់ងារដែលចងភ្ជាប់នឹងក្រុមហ៊ុននោះទេ ហើយក្នុងនាមជាក្រុមប្រឹក្សាភិបាលទាំងអស់គ្រប់គ្រងក្រុមហ៊ុននៅក្នុងវិធីមួយដែលភ្នាក់ងារមិនអាចធ្វើបានដើម្បីគ្រប់គ្រងម្ចាស់សិទ្ធិឡើយ។[28] មួយវិញទៀត អភិបាលក៏មិនត្រូវបានចាត់ទុកថាជាអ្នកទទួលគ្រប់គ្រង (Trustee) ដោយសារតែលើកឡើងថា អភិបាលជាអ្នកមានតំណែងមួយដែលជាការទុកចិត្ត និងគ្រប់គ្រងទៅលើក្រុមហ៊ុននោះទេ ផ្ទុយពីអ្នកគ្រប់គ្រង (Trustee) អភិបាលមិនមានឈ្មោះកាន់កាប់ទ្រព្យសម្បត្តិដើម្បីប្រើប្រាស់ និងទទួលបានផលប្រយោជន៍ពីអ្នកដទៃនោះទេ។[29] ប៉ុន្តែបើមើលទៅលើបញ្ញត្តិនៃការតំណាង នៅក្នុងមាត្រា ៣៦៤ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណី សិទ្ធិនៃការតំណាងអាចកើតឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និងអ្នកតំណាង ឬ ដោយបញ្ញត្តិច្បាប់។ នៅក្នុងសេចក្តីពន្យល់នៃមាត្រានេះបានលើកឡើងថា ការតំណាងអាចជាករណីម្ចាស់សិទ្ធិមានកិច្ចសន្យាផ្ទេរសិទ្ធិទៅឲ្យ អ្នកតំណាងក្នុងទំហំសិទ្ធិដែលបានប្រគល់នោះ ហើយករណីមួយទៀតនោះគឺ អ្នកតំណាងដែលជ្រើសតាំងដោយបញ្ញត្តិនៃច្បាប់ ដូច្នេះទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ ដោយច្បាប់ដែរ។ នៅក្នុងចំណុចនេះ ទំនាក់ទំនងរបស់នីតិបុគ្គល

---

[23] Roger LeRoy Miller & Gaylord A. Jentz, below n 27, 132.

[24] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម,មាត្រា ២៨៩។

[25] Andrew Keay, "THE DUTY TO PROMOTE THE SUCCESS OF THE COMPANY: IS IT FIT FOR PURPOSE?," University of Leeds School of Law, Centre for Business Law and Practice Working Paper, (August 20, 2010), 16.

[26] Ibid.

[27] Roger LeRoy Miller & Gaylord A. Jentz, *Business Law today: text and summarized cases legal, ethical, regulatory & internation environment*, (west publishing company,1997), 696.

[28] Ibid 697.

[29] Ibid.

និងអ្នកតំណាងនីតិបុគ្គល គឺជាការតំណាងមួយដែលស្ថិតនៅចន្លោះករណីទី១ និងទី២។ ករណីតំណាងនេះជាទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និងអ្នកតំណាង។

ហេតុដូចនេះភារកិច្ចមួយត្រូវបានកំណត់ចំពោះអភិបាល ដែលត្រូវបំពេញសម្រាប់ក្រុមហ៊ុន គឺជាទំនាក់ទំនងនៃការជឿទុកចិត្ត ជាគោលការណ៍នៃការទទួលខុសត្រូវដែលភ្ជាប់ជាមួយនឹងភារកិច្ច និងតួនាទីជាអភិបាល ដោយហេតុនេះអភិបាលអាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដោយមានទំនួលខុសត្រូវពេញលេញ។[30] បន្ថែមពីនេះ តួនាទីរបស់អភិបាលមួយចំនួនមានទំនាក់ទំនងទៅនឹងឥរិយាបថនៅពេលដែលអភិបាលបំពេញមុខងាររបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ តួនាទីរបស់អភិបាល គឺជាគោលការណ៍គ្រប់គ្រងមួយដែលលេចចេញ នៅក្នុងបណ្តាប្រទេស Common Law ដែលវិវត្តន៍មកពីយុទ្ធសាស្ត្រតុលាការ ហើយក្រោយមក តួនាទីរបស់អភិបាលត្រូវបានកំណត់នៅក្នុងក្រមនៃនីតិក្រុមហ៊ុន បើមើលទៅប្រព័ន្ធច្បាប់របស់ប្រទេសអង់គ្លេស។[31] នៅក្នុងប្រទេស Common Law ដូចជាប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិច តួនាទីរបស់អភិបាលត្រូវបានបែងចែកទៅជាច្រើនប្រភេទដូចជា តួនាទីភក្តីភាព (Duty of Loyalty) និងតួនាទីការយកចិត្តទុកដាក់ (Duty of Care) ។[32] ប៉ុន្តែផ្ទុយទៅវិញ នៅក្នុងប្រទេស Civil Law មានតែតួនាទីមួយប្រភេទដែលនឹងអាចមានឥទ្ធិពលទៅតួនាទីផ្សេងទៀត។[33] ឧទាហរណ៍ នៅក្នុងច្បាប់ក្រុមហ៊ុនរបស់ប្រទេសចិនមានតែតួនាទីភក្តីភាព (Duty of Loyalty) ប៉ុន្តែមិនមានតួនាទីការយកចិត្តទុកដាក់ (Duty of Care) ទេ។[34] ដោយឡែកនៅកម្ពុជា តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឃើញមានចែងអំពីតួនាទីរបស់អភិបាល និងអ្នកគ្រប់គ្រងផ្សេងទៀតផងដែរ ដែលក្នុងនោះក៏មានតួនាទីភក្តីភាព (Duty of Loyalty) និងតួនាទីការយកចិត្តទុកដាក់ (Duty of Care)។[35] ដើម្បីអោយកាន់តែយល់ច្បាស់ពីអត្ថន័យ នៅក្នុងជំពូកទី១ នេះនឹងធ្វើការបែងចែកជា ៣ផ្នែក រួមមាន៖ តួនាទីរបស់អភិបាល **(ផ្នែកទី១)** សិទ្ធិ និងអំណាចរបស់អភិបាល **(ផ្នែកទី២)** និងទំនាក់ទំនងអភិបាល និងភាគីពាក់ព័ន្ធ **(ផ្នែកទី៣)**។

---

[30] Ibid 700.

[31] Christopher CHEN Choa-hung, "Transplantation of Fiduciary Duties into Civil Law Jurisdiction: Experiences from Taiwan," Hong Kong (2010), 3.

[32] Fidy Xiangxing Hong, "DIRECTOR REGULATION IN CHINA: THE SINONIZATION PROCESS," (November 2010), 509.

[33] Ibid.

[34] Ibid.

[35] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៤, ២៨៩។

## ផ្នែកទី១៖ តួនាទីរបស់អភិបាល

ការដាក់បញ្ចូលតួនាទីរបស់អភិបាល នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មនៅកម្ពុជា មានបទប្បញ្ញត្តិជាច្រើនដែលបានយកមកពីប្រទេស Common Law ដែលនឹងនាំឲ្យមានការជួបទៅនឹងបញ្ហាមួយចំនួនដោយមូលហេតុថា តួនាទីរបស់អភិបាលដែលមានចែងនៅក្នុងច្បាប់នេះមិនមានលក្ខណៈលម្អិត ហើយការអនុវត្តត្រូវការជំនួយច្រើនក្នុងការបកស្រាយ។ ម្យ៉ាងវិញទៀតប្រសិន បើច្បាប់មានលក្ខណៈស្រពិចស្រពិលនោះ នាំឲ្យការអនុវត្តអាចផ្ទុយនឹងឆន្ទៈ ដែលច្បាប់នេះចង់បាន។ ប្រហាក់ប្រហែលគ្នាដែរ នៅតៃវ៉ាន់ ប្រទេសចិន ត្រូវបានលើកឡើងថា ការអនុវត្តច្បាប់ក្រុមហ៊ុន (company act 2001) បានធ្វើឲ្យមានបញ្ហាដូចជា ការអនុវត្តខុសនឹងបញ្ញត្តិ នៃបញ្ញត្តិដែលជាអត្តសញ្ញាណដើមរបស់តួនាទីរបស់អភិបាល ហើយធ្វើឲ្យប្រព័ន្ធច្បាប់អាចមានការជ្រៀតជ្រែកពីប្រព័ន្ធ Common Law ពីសហរដ្ឋអាមេរិក និងប្រទេសអង់គ្លេសជាដើម។[36] តួនាទីរបស់អភិបាលនឹងមានការផ្លាស់ប្តូរទៅតាមទម្រង់នៃទំនាក់ទំនងរបស់អភិបាល និងក្រុមហ៊ុន ថាតើអភិបាលជាអ្នកតំណាងឲ្យក្រុមហ៊ុន ឬ ជាបុគ្គលដែលស្ថិតក្នុងកិច្ចសន្យាការងារ។ យោងតាមក្រមរដ្ឋប្បវេណី អភិបាលអាចជាអ្នកតំណាងរបស់នីតិបុគ្គលដោយសារ អភិបាលបានបង្ហាញឆន្ទៈយល់ព្រមនឹងការតែងតាំងជាអភិបាលដោយមហាសន្និបាតភាគហ៊ុនិក ហើយអភិបាលអាចត្រូវបានកំណត់នូវសិទ្ធិតាមរយៈកិច្ចសន្យា ដែលអាចជាលក្ខន្តិកៈក្រុមហ៊ុន ប៉ុន្តែ ប្រសិនបើគ្មានការកំណត់ពិសេសនោះទេ អភិបាលក៏អាចជាអ្នកតំណាងដែលច្បាប់បានកំណត់ ហើយអនុវត្តសិទ្ធិ និងអំណាចជាអ្នកតំណាងដែលច្បាប់បានចែង។[37] ជាការបកស្រាយតួនាទីរបស់អភិបាលនៅប្រទេសកម្ពុជា នៅក្នុងចំណុចនេះនឹងលើកយកតួនាទី២សំខាន់ៗដែលរួមមាន តួនាទីការយកចិត្តទុកដាក់ (Duty of Care) (១.១) និងតួនាទីភក្តីភាព (Duty of Loyalty) (១.២)។

[36] Christopher CHEN Choa-hung, above n 31, 4.

[37] ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖២០១០), ២៖ មាត្រា ៣៦៥។

## ១.១.តួនាទីការយកចិត្តទុកដាក់ (Duty of Care)

តួនាទីការយកចិត្តទុកដាក់ គឺជាទំនួលខុសត្រូវមួយដែលតម្រូវឲ្យអភិបាលផ្តល់ការទុកចិត្តដល់ក្រុមហ៊ុន ហើយតួនាទីនេះតម្រូវឲ្យអភិបាលធ្វើការសម្រេចចិត្តលើអ្វីមួយប្រកបដោយភាពសុចរិត និងមធ្យ័តភាព។[38] នៅក្នុងការអនុវត្តកិច្ចការក្រុមហ៊ុន និងតួនាទីរបស់អភិបាល អភិបាលត្រូវធ្វើសកម្មភាពមួយចំនួនដូចជា ការធ្វើសកម្មភាពដោយមានភាពស្មោះត្រង់ បំពេញសកម្មភាពដោយជំនាញដូចបុគ្គលដែលមានភាពមធ្យ័តអនុវត្តក្នុងកាលៈទេសៈមួយដូចគ្នាដែរ និងការធ្វើសកម្មភាពណាដែលអភិបាលសម្រេចថា ជាផលប្រយោជន៍ដ៏ល្អបំផុតរបស់ក្រុមហ៊ុន។[39] នៅក្នុងទំនាក់ទំនងរបស់បទប្បញ្ញត្តិទូទៅ និងដែលមានចែងក្នុងច្បាប់បានធ្វើឲ្យមានភាពស្មុគស្មាញដល់ការទទួលខុសត្រូវរបស់អភិបាលនៅក្នុងបរិបទនៃតួនាទីនេះ។[40] ឧទាហរណ៍ ចំពោះតួនាទីរបស់អភិបាលនៅក្នុងច្បាប់របស់ប្រទេសអូស្ត្រាលីបានបង្កើតឲ្យមានទំនាក់ទំនងមួយ ដែលកាន់តែស្មុគស្មាញសម្រាប់ការអនុវត្តនូវតួនាទីរបស់អភិបាលជាងប្រព័ន្ធច្បាប់ Delaware (US) និងច្បាប់របស់ប្រទេសអង់គ្លេសផងដែរ។[41] Delaware គឺជារដ្ឋមួយនៃសហរដ្ឋអាមេរិចដែលមានក្រុមហ៊ុនធំៗជាច្រើនបានកកើតឡើង ហើយច្បាប់ក្រុមហ៊ុនរបស់រដ្ឋ Delaware នេះតែងតែយកមកធ្វើជាយុទ្ធសាស្ត្រសម្រាប់រដ្ឋដទៃរបស់សហរដ្ឋអាមេរិច និងបណ្តាប្រទេសមួយចំនួន ដែលមើលលើច្បាប់នេះពេលគេអភិវឌ្ឍច្បាប់ និងយុទ្ធសាស្ត្រ។[42] អភិបាលនៅក្នុងប្រទេសអូស្ត្រាលីត្រូវទទួលខុសត្រូវទៅលើលទ្ធិទូទៅផង និងតួនាទីដែលមានចែងនៅក្នុងច្បាប់ផង។[43] តួនាទីយកចិត្តទុកដាក់នេះ គឺជានិមិត្តរូបមួយដែលបង្ហាញថាមានភាពស្មុគស្មាញ និងខុសពីគេទៀតផង។ វាក៏ជាតួនាទីមួយដែលបង្ហាញនូវឧទាហរណ៍មួយដ៏សំខាន់ទាក់ទងនឹងផលប៉ះពាល់សុវត្ថិភាពនៃដំណើរការក្រុមហ៊ុន និងការទទួលខុសត្រូវដែលនាំឲ្យមានលក្ខណៈខុសៗពីគ្នាដែរ។[44]

នៅក្នុងតួនាទីនេះមានវិធានពីរធំៗ ដែលមានទំនាក់ទំនងក្នុងការកំណត់នូវព្រំដែន និងការអនុវត្តនៃតួនាទីនេះ ក្នុងនោះមានវិធានសម្រាប់សេចក្តីសម្រេចរបស់ក្រុមហ៊ុន និងខដែលមានចែងអំពីការរួចទោសរបស់អភិបាលចំពោះការសម្រេចរបស់អភិបាល ដែលមានការធ្វេសប្រហែស។[45]

[38] Roger LeRoy Miller & Gaylord A. Jentz, above n 27, 700.
[39] Ibid.
[40] Matthew Conaglen and Jennifer G. Hill, “Directors’ Duties and Legal Safe Harbours: A Comparative Analysis”, (March 2017), 1.
[41] Ibid 2.
[42] Bernard S. Sharfman, “Shareholder Wealth Maximization And Its Implementation Under Corporate Law”, (Vol. 66, 2014), 393.
[43] Ibid.
[44] Christopher CHEN Choa-hung, above n 31, 3-4.
[45] Matthew Conaglen and Jennifer G. Hill, above n 40, 16.

បើយោងតាមការអនុវត្តរបស់ច្បាប់សាជីវកម្មរបស់សហរដ្ឋអាមេរិច អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន គឺចាំបាច់ត្រូវមានតួនាទីក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងការខិតខំប្រឹងប្រែងខ្ពស់បំផុត។[46] នៅក្នុងទំនាក់ទំនងរវាងអភិបាល និងភាគហ៊ុនិកនៅសហរដ្ឋអាមេរិច បណ្តឹងជំនួសមុខដែលធ្វើឡើងដោយភាគហ៊ុនិកគឺមានច្រើនលើសលប់តាំងពីយូរណាស់មកហើយដែលប្តឹងប្រឆាំងនឹងអភិបាល ចំពោះការល្មើសនឹងតួនាទីយកចិត្តទុកដាក់នេះ។[47] មួយវិញទៀតនៅក្នុងបណ្តឹងពាក់ព័ន្ធនឹងតួនាទីដែលអភិបាលត្រូវមានការយកចិត្តទុកដាក់ខ្ពស់នេះអាចទទួលបានជោគជ័យទៅបាន លុះត្រាតែតួនាទីដែលបានល្មើសនេះមានការជាប់ទាក់ទងនឹងតួនាទីភក្តីភាពរបស់អភិបាលផងដែរ។[48] ក្រោយៗមកយុត្តាធិការនៃ Delaware បានយកលំនាំតាមនេះ ក្នុងការសម្រេចលើការទទួលខុសត្រូវរបស់អភិបាលចំពោះការល្មើសទៅលើតួនាទីការយកចិត្តទុកដាក់នេះ។[49] ចំពោះករណី Disney ឆ្នាំ២០០៥ បានបង្ហាញពីភាពដាច់ដោយឡែកពីគ្នារវាងវិធានអនុវត្ត និងវិធានដែលប្រើចំពោះសេចក្តីសម្រេចនៅក្នុងទំនាក់ទំនងតួនាទីយកចិត្តទុកដាក់របស់អភិបាល។ នៅក្នុងការសម្រេចសេចក្តីនៃបណ្តឹង Disney 2005 នេះ បានបង្ហាញភាពខុសគ្នារវាងការអនុវត្តរបស់ច្បាប់ ចំពោះតួនាទីរបស់អភិបាល និងស្តង់ដានៃអភិបាលកិច្ចសាជីវកម្មដែលវាគ្រាន់តែជាគោលគំនិតមួយពង្រឹងការអនុវត្តប៉ុណ្ណោះ។[50] ក្នុងសេចក្តីសម្រេចនៃបណ្តឹង Disney 2005 Chancellor Chandler បានលើកឡើងថា ច្បាប់ Delaware មិនមានឥទ្ធិពលទៅលើការទទួលខុសត្រូវ ចំពោះតួនាទីយកចិត្តទុកដាក់សម្រាប់ការដែលមិនបានគោរពតាមគោលគំនិតនៃគោលការណ៍ការអនុវត្តល្អបំផុតរបស់ក្រុមហ៊ុននោះទេ។[51] ងាកមកមើលប្រទេសកម្ពុជាវិញទាក់ទិននឹងតួនាទីការយកចិត្តទុកដាក់នេះ នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជាក៏បានចែងថា អ្នកដែលកំពុងប្រតិបត្តិតួនាទីជាអភិបាល និងអ្នកគ្រប់គ្រងក្រុមហ៊ុនត្រូវអនុវត្តតួនាទីនោះប្រកបដោយការយកចិត្តទុកដាក់ ឧស្សាហ៍ព្យាយាម និងមានជំនាញ។[52]

[46] Ibid.
[47] Ibid 17.
[48] Ibid.
[49] Ibid.
[50] Ibid.
[51] Ibid.
[52] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៨៩។

## ១.២. តួនាទីភក្តីភាព( Duty of Loyalty )

តួនាទីភក្តីភាព គឺជាការទទួលខុសត្រូវរបស់អភិបាលមួយទៅរាល់សកម្មភាពទាំងអស់ក្នុងគោលបំណងដើម្បីផលប្រយោជន៍ល្អសម្រាប់ក្រុមហ៊ុន។[53] តួនាទីភក្តីភាពនេះ ជាតួនាទីមួយក្នុងចំណោមតួនាទីចម្បងពីរដែលតម្រូវឲ្យអភិបាលត្រូវតែមានជាដាច់ខាត។[54] បន្ថែមពីនេះ តួនាទីនេះតម្រូវឲ្យអភិបាលគ្រប់រូបត្រូវប្រកាន់ខ្ជាប់ជានិច្ចចំពោះក្រុមហ៊ុន។[55] នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម នៅត្រង់ចំណុចដែលនិយាយអំពីតួនាទីភក្តីភាពនេះ គឺផ្អែកទៅលើគោលគំនិតនៃ Fiduciary Duty នៅក្នុងប្រព័ន្ធច្បាប់ Common Law ពីព្រោះថានៅក្នុងច្បាប់នៃបណ្តាប្រទេសប្រព័ន្ធ Commom Law តួនាទីភក្តីភាពរបស់អភិបាល គឺជានិច្ចជាកាលតួនាទីភក្តីភាពតែងតែមាននៅករណីមួយចំនួនដែលកំណត់ថា ជាករណីដែលអភិបាលបានប្រព្រឹត្តផ្ទុយនឹងតួនាទីរបស់ខ្លួន។[56]

តើតួនាទីភក្តីភាពនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ របស់កម្ពុជាគ្រប់គ្រាន់ដែរឬទេក្នុងការចងអភិបាលចំពោះការអនុវត្តតួនាទី?

ជាធម្មតា អភិបាលត្រូវប្រកាន់យកនូវតួនាទីជាច្រើន ដែលទាំងនោះត្រូវបានភ្ជាប់ជាមួយនឹងតួនាទីភក្តីភាពនេះ ក្នុងនោះមានបម្រាមមិនឲ្យអភិបាលប្រព្រឹត្តនូវសកម្មភាពមួយចំនួនដែលនាំឲ្យល្មើសនឹងតួនាទីភក្តីភាពនេះដូចជា អភិបាលមិនត្រូវប្រកួតប្រជែងជាមួយនឹងក្រុមហ៊ុន មិនត្រូវទាញយកអត្ថប្រយោជន៍នៃឱកាសរបស់ក្រុមហ៊ុន មិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយនឹងផលប្រយោជន៍របស់ក្រុមហ៊ុន មានទំនាក់ទំនងនឹងការលក់ភាគហ៊ុន (ដូចជាយកពត៌មានដែលមិនមែនជាពត៌មានសាធារណៈដើម្បីទាញយកផលចំណេញពីការទិញលក់ភាគហ៊ុន) អនុញ្ញាតឲ្យមានសកម្មភាពពាណិជ្ជកម្មដែលនាំឲ្យមានផលប៉ះពាល់ដល់ភាគហ៊ុនិកដែលមានភាគហ៊ុនតិច និងការលក់ការគ្រប់គ្រងរបស់ក្រុមហ៊ុន។[57] សម្រាប់ប្រទេសកម្ពុជាដែលកាន់ប្រព័ន្ធ Civil Law វិញនៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជាបានចែងថាៈ

---

[53] គុយ នាម, *ច្បាប់ក្រុមហ៊ុន* (២០១៦), ៤២១-៤២២។

[54] Ibid.

[55] Ibid.

[56] Christopher CHEN Choa-hung, above n 31.

[57] Roger LeRoy Miller & Gaylord A. Jentz, above n 27, 701.

"អភិបាល ឬ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវបង្ហាញនូវទំហំផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅឲ្យក្រុមហ៊ុន ឬ ស្នើឲ្យមានសេចក្តីប្រកាសដែលបានដាក់បញ្ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងករណីៈ

ក.ដែលខ្លួនជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន។

ខ.ដែលខ្លួនមានអត្ថប្រយោជន៍ជាមួយបុគ្គលណាម្នាក់ ដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន។"[58]

នៅក្នុងមាត្រានេះតម្រូវអោយអភិបាលបង្ហាញពី ភាពជាប់ពាក់ព័ន្ធផលប្រយោជន៍នៅក្នុងកិច្ចសន្យា ដែលអភិបាលនោះជាភាគី ឬ ជាជនដែលជាប់ផលប្រយោជន៍ជាមួយតតិយជនដែលចុះកិច្ចសន្យាជាមួយក្រុមហ៊ុន។ ឧទាហរណ៍ អភិបាលម្នាក់បានលក់រថយន្តទៅអោយក្រុមហ៊ុន មានន័យថាអភិបាលនោះត្រូវបង្ហាញពត៌មាន និងតម្លៃនៅលើទីផ្សារពីរថយន្តនោះ ដើម្បីជៀសវាងពីការកេងចំណេញពីក្រុមហ៊ុន ឬ បង្ហាញថាភាគីតតិយជននោះជាប់សាច់ញាតិជាប្រពន្ធ កូន ឬ បងប្អូនរបស់អភិបាលនោះ។ ម្យ៉ាងទៀតបង្ហាញពីតម្លាភាពរវាងអភិបាល និងក្រុមហ៊ុន ដើម្បីការពារទំនាស់ផលប្រយោជន៍នាពេលអនាគត ក្នុងករណីដែលអភិបាលនោះបានប្រព្រឹត្តដោយសុចរិត។[59]

ឧទាហរណ៍[60] នៅក្នុងករណីដែលអភិបាលធ្វើការទិញភាគហ៊ុនណាមួយរបស់ក្រុមហ៊ុន តើត្រូវបានចាត់ទុកជាការទាញយកអត្ថប្រយោជន៍ពីឱកាសរបស់ក្រុមហ៊ុនដែរឬទេ? នៅឆ្នាំ១៩៩៥ តុលាការកំពូលរដ្ឋ Delaware (Supreme Court of Delaware) នៅក្នុងរឿងក្តី Yiannatsis v. Stephanis បានសម្រេចថា ការទិញភាគហ៊ុន ដែលមិនបានគោរពតាមកិច្ចព្រមព្រៀងរបស់ភាគហ៊ុនិក ត្រូវបានចាត់ទុកថាបានទាញយកឱកាសរបស់ក្រុមហ៊ុន។ នៅក្នុងរឿងនេះ Demos, Stella, Yiannatsis, បងប្អូនជីដូនមួយរបស់ Demos ឈ្មោះ Jonh និង Costas Stephanis គឺជាអភិបាលនៃក្រុមហ៊ុន Sunview Corporation។ Demos, Jonh និង Costas គឺជាភាគហ៊ុននិកផងដែរ។ នៅឆ្នាំ១៩៧៥ ភាគហ៊ុនិកទាំងបីបានព្រមព្រៀងគ្នាថា ប្រសិនបើភាគហ៊ុនិកណាមួយចង់ចាត់ចែងភាគហ៊ុន ឬ នៅក្រោយពេលដែលភាគហ៊ុនិកបានទទួលមរណភាពនោះ គឺភាគហ៊ុនិកនឹងលក់ Sunview ភាគហ៊ុន ឬ ទ្រព្យសម្បត្តិ ដែលក្នុងកិច្ចព្រមព្រៀងនោះ បានផ្តល់ឱកាសឲ្យនៃការទិញភាគហ៊ុននោះទៅក្រុមហ៊ុនមុនគេ។ គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺធ្វើឡើងដើម្បីការពារកុំឲ្យភាគហ៊ុន ឬ ទ្រព្យសម្បត្តិរបស់ម្ចាស់ហ៊ុនត្រូវបានលក់ទៅឲ្យភាគីដទៃ។ នៅឆ្នាំ១៩៨៤ Costas បាន

[58]ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៩។

[59] គុយ នាម, above n 53, 421-422.

[60] Roger LeRoy Miller & Gaylord A. Jentz, above n 27, 702.

ទទួលមរណភាព។ នៅក្នុងកិច្ចប្រជុំមហាសន្និបាត អ្នកប្រតិបត្តិបណ្តាំមរតករបស់ Costas បានដាក់លក់ភាគហ៊ុនរបស់ Costas ក្នុងតម្លៃ $150.000 ជាសាច់ប្រាក់ នឹងអាចបង់មុន $55.000។ អភិបាល Demos Stella និង Jonh បានបោះឆ្នោតបដិសេធសំណើ។ បន្ទាប់មក Stella បានស្នើទិញភាគហ៊ុននៅក្នុងពាក្យពេចន៍មួយខុសពីមុន។ អ្នកប្រតិបត្តិបណ្តាំបានយល់ព្រម។ Jonh បានដាក់ពាក្យបណ្តឹងទៅតុលាការ Delaware ប្រឆាំងនឹង Stella និង Demos ដោយលើកឡើងថា ពួកគេបានទាញយកផលប្រយោជន៍ពីឱកាសរបស់ក្រុមហ៊ុន។ តុលាការ Delaware បានឲ្យ Jonh ឈ្នះ បន្ទាប់មកចុងចម្លើយបានប្តឹងទៅតុលាការជាន់ខ្ពស់។

តុលាការកំពូលរដ្ឋ Delaware (Supreme Court of Delaware) បានយល់ស្របលើការកាត់ក្តីរបស់តុលាការជាន់ទាប ដោយលើកឡើងថា Demos និង Stella បានធ្វើសកម្មភាពដោយមិនគោរពតាម កិច្ចព្រមព្រៀងឆ្នាំ១៩៧៥ ឬ មិនគោរពតាមតួនាទីភក្តីភាព (Fiduciary Duty) ដែលក្នុងនាមជាអភិបាលមានចំពោះក្រុមហ៊ុន និង Jonh ។ Demos និង Stella ចំពោះសកម្មភាពនេះបានចាត់ទុកជាឧទាហរណ៍គំរូមួយ នៃសកម្មភាពពុំស្មោះត្រង់ និងពួកគេមិនត្រូវបានទទួលផលប្រយោជន៍ពីសកម្មភាពមិនត្រឹមត្រូវរបស់គេទេ។

## ផ្នែកទី២៖ សិទ្ធិ និងអំណាចរបស់អភិបាល

បណ្តាប្រទេសជាច្រើនបានកំណត់អំពីសិទ្ធិ និងអំណាចរបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានកំណត់ដោយច្បាប់ ផ្ទុយពីនេះក៏មានច្បាប់នៃប្រទេសមួយចំនួនទៀតដែលសិទ្ធិ និងអំណាចគ្រប់គ្រងការងាររបស់ក្រុមហ៊ុន មិនត្រូវបានប្រគល់ទៅឲ្យក្រុមប្រឹក្សាភិបាលតាមរយៈច្បាប់ទេ។[61] ការគ្រប់គ្រងដែលមិនបានផ្តល់នូវសិទ្ធិ និងអំណាចទៅឲ្យក្រុមប្រឹក្សាភិបាលតាមច្បាប់នោះ គឺត្រូវមានលក្ខន្តិកៈក្រុមហ៊ុនមួយដែលត្រូវអនុម័តដោយក្រុមហ៊ុន ហើយយោងទៅតាមលក្ខន្តិកៈនោះ គឺអភិបាលជា អ្នកទទួលខុសត្រូវសម្រាប់រាល់ការគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មរបស់ក្រុមហ៊ុននេះ គឺជាគោលបំណងមួយដែលផ្តល់សិទ្ធិ និងអំណាចទៅឲ្យអភិបាលក្នុងការអនុវត្តរាល់សិទ្ធិ និងអំណាចរបស់ក្រុមហ៊ុន។[62] បើលើកឡើងអំពីទម្រង់នៃការគ្រប់គ្រងនោះ ជានិច្ចកាលមានបីទម្រង់ គឺការគ្រប់គ្រងដែលភាគហ៊ុនិកមានសិទ្ធិ និងអំណាចតាមរយៈលក្ខន្តិកៈ (Shareholder Primacy) ការគ្រប់គ្រងដោយអភិបាល (Managerialist Models) និងការគ្រប់គ្រងដែលមានម្ចាស់ហ៊ុន

[61] Susan Watson, “The Significance of the Source of the Power of Boards of Directors in UK company Law”, 1.
[62] Ibid 2.

(Stakeholderist Models)។[63] នៅក្នុងទម្រង់នៃការគ្រប់គ្រងបែប Shareholder Primacy គឺផ្ដោតសំខាន់ទៅលើភាគហ៊ុនិកដែលមានសិទ្ធិ និងអំណាចតាំងទៅលើការគ្រប់គ្រងក្រុមហ៊ុន និងទទួលបាននូវសិទ្ធិលើតួនាទីរបស់អភិបាល (Fiduciary Duty)។[64] ទម្រង់មួយទៀតនោះ Managerialist Models នៅក្នុងទម្រង់នេះ គឺសំដៅទៅលើការគ្រប់គ្រងដោយអ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន ដូចជា ក្រុមប្រឹក្សាភិបាលជាដើម។[65] ទម្រង់ចុងក្រោយ គឺ Stakeholderist Models សម្រាប់ទម្រង់មួយនេះ មានភាគតិចណាស់ដែលផ្ដោតទៅលើបញ្ហានៃការគ្រប់គ្រង ប៉ុន្តែវាបានលើកឡើងថា ភាគហ៊ុនិកមិនគួរត្រូវទទួលបានអត្ថប្រយោជន៍ម្នាក់ឯង ចំពោះតួនាទីរបស់អភិបាល និងបុគ្គល (Fiduciary Duty) នោះទេ។[66]

នៅសហរដ្ឋអាមេរិច ក្រុមប្រឹក្សាភិបាលមានសិទ្ធិ និងអំណាចទៅតាមច្បាប់កំណត់ ដោយលើកឡើងថាសិទ្ធិ និងអំណាចរបស់ក្រុមហ៊ុនត្រូវអនុវត្តដោយ ឬ នៅក្រោមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ហើយរាល់កិច្ចការពាណិជ្ជកម្ម និងកិច្ចការគ្រប់គ្រងរបស់ក្រុមហ៊ុនត្រូវគ្រប់គ្រងដោយ ឬ ក្រោមទិសដៅរបស់ក្រុមប្រឹក្សាភិបាល (The Model Business Corporation Act)។[67] ប្រទេសញ៉ូហ្សេលែន នៅក្នុងច្បាប់ក្រុមហ៊ុនឆ្នាំ ១៩៩៣ ក៏បានឲ្យសិទ្ធិ និងអំណាចទៅឲ្យអភិបាល ដូចជា តួនាទីក្នុងការគ្រប់គ្រង កំណត់ទិសដៅ និងតួនាទីក្នុងការត្រួតពិនិត្យ ព្រមទាំងសិទ្ធិ និងអំណាចសំខាន់ៗដែលត្រូវអនុវត្តតួនាទី (Section 128(1) and (2) of New Zealand Company Law)។[68] ប្រហាក់ប្រហែលគ្នានេះដែរ នៅអូស្ត្រាលី Corporations Act 2001 Section 198A បានលើកឡើងថា អាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានគ្រប់គ្រងដោយ ឬ ក្រោមគោលដៅនៃអភិបាល ហើយអភិបាលត្រូវអនុវត្តនូវសិទ្ធិ និងអំណាចរបស់ក្រុមហ៊ុន លុះត្រាតែករណីដែលសិទ្ធិ និងអំណាចនោះត្រូវបានកំណត់ដោយច្បាប់ ឬ លក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឲ្យអនុវត្តនៅក្នុងការប្រជុំមហាសន្និបាត។[69] ប៉ុន្តែនៅប្រទេសអង់គ្លេស ការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន គឺត្រូវប្រគល់ឲ្យអភិបាលជាអ្នកអនុវត្តសិទ្ធិ និងអំណាចរបស់ក្រុមហ៊ុន ហើយសិទ្ធិ និងអំណាចនោះមិនបានផ្ដល់ឲ្យដោយច្បាប់នោះទេ វាជាសិទ្ធិ និងអំណាចដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន។[70] សិទ្ធិ និង

[63] Stephen M. Bainbridge, "Director Primacy: The Means and Ends of Corporate Governance", (University of California, Research Paper No. 02-06), 18.
[64] Ibid.
[65] Ibid.
[66] Ibid.
[67] Susan Watson, above n 61.
[68] Ibid.
[69] Susan Watson, above n 61, 2.
[70] Ibid 3.

អំណាចរបស់អភិបាលតាមបែបនេះ គឺបានមកពីភាគហ៊ុនិកតាមរយៈការផ្ទេរសិទ្ធិ និងអំណាច តាមការកំណត់នៅក្នុងលក្ខន្តិកៈ ហើយមិនមែនបានមកពីការផ្តល់ឲ្យដោយច្បាប់នោះទេ។[71]

នៅក្នុងអត្ថបទនេះលើកឡើងអំពីសិទ្ធិ និងអំណាចរបស់ក្រុមប្រឹក្សាភិបាល និងអភិបាលនៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម របស់ប្រទេសកម្ពុជា។ បើយោងតាមការបង្ហាញខាងលើ ប្រទេសទាំងអស់ដែលបានលើកឡើង គឺសុទ្ធតែប្រទេសដែលប្រកាន់ប្រព័ន្ធ Common Law។ ដោយឡែកកម្ពុជាប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល ច្បាប់សហគ្រាសពាណិជ្ជកម្ម នៅកម្ពុជាបានចែងអំពីការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ដែលត្រូវបានផ្តល់ឲ្យដោយច្បាប់នេះ ហើយបញ្ញត្តិមួយចំនួនក៏ត្រូវបានកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុនផងដែរ។ តាមរយៈច្បាប់សហគ្រាសពាណិជ្ជកម្មចែងថា ៖

> "ក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងអាជីវកម្មនិងការងាររបស់ក្រុមហ៊ុន។លក្ខន្តិកៈត្រូវមានចែងអំពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍..."។[72]

តាមន័យនៃមាត្រានេះបានបង្ហាញថា សិទ្ធិ និងអំណាចរបស់អភិបាលតាមរយៈច្បាប់នេះក្រៅពីមានកំណត់នៅក្នុងច្បាប់ ក៏អាចកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុនផងដែរ។ មូលហេតុនេះហើយដែលនាំឲ្យច្បាប់របស់កម្ពុជា មានលក្ខណៈស្រដៀងទៅនឹងបទប្បញ្ញត្តិអំពីសិទ្ធិ និងអំណាចរបស់ច្បាប់នៃប្រទេសអូស្ត្រាលី។ ហេតុនេះ នាំឲ្យមានការលើកឡើងថា តើរវាងអំណាចដែលមានចែងនៅក្នុងលក្ខន្តិកៈ និង អំណាចដែលមានចែងដោយច្បាប់ នាំឲ្យមានការអនុវត្តខុសគ្នាដូចម្តេច? ជាការបកស្រាយ អត្ថបទនេះនឹងធ្វើការបែងចែកសិទ្ធិ និងអំណាចរបស់ក្រុមប្រឹក្សាភិបាលជាពីរ គឺសិទ្ធិ និងអំណាចតាមច្បាប់កំណត់ **(២.១)** និង សិទ្ធិ និងអំណាចតាមលក្ខន្តិកៈ **(២.២)**។

[71] Ibid.

[72] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៩។

## ២.១.សិទ្ធិ និងអំណាចអភិបាលតាមច្បាប់

បើមើលទៅលើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ត្រង់ចំណុចមាត្រា ១១៩ នោះវា គឺជាសិទ្ធិ និងអំណាចដែលច្បាប់នេះបានផ្តល់ឲ្យក្រុមប្រឹក្សាភិបាល ហើយអភិបាលត្រូវគោរពតាមសិទ្ធិ និង អំណាចដែលមានតាមរយៈក្រុមប្រឹក្សាភិបាលនេះ។[73] នៅក្នុងច្បាប់នេះក៏បានតម្រូវឲ្យក្រុមហ៊ុនមូលធនទាំងពីរប្រភេទដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវមានអភិបាល ហើយតម្រូវឲ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬ ច្រើននាក់ ចំណែកឯ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតវិញនោះ តម្រូវអោយមានអភិបាលយ៉ាងតិចបីនាក់។[74] ច្បាប់នេះមានចែង អំពីសិទ្ធិរបស់អភិបាលដែលកំណត់ថា សិទ្ធិនោះត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ដូចជា ការតែងតាំង កំណត់នូវសិទ្ធិ និងដកហូតអ្នកគ្រប់គ្រងទាំងអស់ កំណត់ប្រាក់បៀវត្សផ្សេងៗ ចេញប័ណ្ណកំណត់កិច្ចសន្យា ក៏ដូចជាលិខិតស្នាមផ្សេងៗ ស្នើសុំម្ចាស់ហ៊ុនកែប្រែ ឬលុបចោលលក្ខន្តិកៈក្រុមហ៊ុន ស្នើសុំការរំលាយ ក្រុមហ៊ុនចូលគ្នា ស្នើសុំដើម្បីលក់ទ្រព្យក្រុមហ៊ុន ស្នើសុំដើម្បីរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ប្រកាសភាគលាភ ចេញប័ណ្ណភាគហ៊ុន ខ្ចីប្រាក់ បោះមូលបត្រ ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន ធ្វើហ៊ីប៉ូតែក ផ្សេងៗ និងរៀបចំការបិទបញ្ជីសម្រាប់ម្ចាស់ភាគហ៊ុន។[75]

ក្នុងកាលៈទេសៈដែលអភិបាល គឺជាបុគ្គលដែលមានសិទ្ធិ និងអំណាចក្នុងការគ្រប់គ្រងដោយផ្អែកទៅលើការសម្រេចចិត្តលើកិច្ចការនានារបស់ក្រុមហ៊ុន និងមិនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគហ៊ុនិកឡើយចំពោះគោលនយោបាយរបស់អភិបាល។[76] នៅត្រង់ចំណុចនេះមានបញ្ហាមួយដែលលើកឡើងថា តើទ្រព្យសម្បត្តិរបស់ភាគហ៊ុនិកត្រូវបានការពារដោយរបៀបណា?

ចំណុចនេះ ច្បាប់គឺជាអ្នកមានឥទ្ធិពលទៅលើតួនាទីរបស់អភិបាល (Fiduciary Duty) ក្នុងការកំណត់អំពីការធ្វើសកម្មភាពរបស់អភិបាលក្នុងការគ្រប់គ្រងប្រចាំថ្ងៃ។ បន្ថែមពីលើនេះ នៅពេលដែលមានទំនាស់ទាក់ទងនឹងការគ្រប់គ្រងរវាងអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ សិទ្ធិ និងអំណាចរបស់អភិបាល គឺមានឥទ្ធិពលជាង ព្រោះក្រុមប្រឹក្សាភិបាលមានសិទ្ធិ និងអំណាចត្រឹមត្រូវតាមច្បាប់ដែលក្រុមប្រឹក្សាភិបាលមានសិទ្ធិ និងអំណាចក្នុងការជ្រើសរើស និងបញ្ឈប់

[73] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៩។

[74] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៨។

[75] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៩។

[76] Roger LeRoy Miller & Gaylord A. Jentz, above n 27, 696.

បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនបាន។[77] នៅក្នុងទំនាក់ទំនងរវាងអភិបាល និងភាគហ៊ុនិក គឺអភិបាលបានទទួលស្គាល់ថា ភាគហ៊ុនិកសំខាន់នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងការសម្រេចចិត្តដ៏ត្រឹមត្រូវនានា ប៉ុន្តែមិនយល់ស្របទេចំពោះការលើកឡើងថា ភាគហ៊ុនិកមានសិទ្ធិ និងអំណាចលើការសម្រេចចិត្តទាំងដោយផ្ទាល់ ឬ ដោយប្រយោលនោះ។[78]

## ២.២ សិទ្ធិ និងអំណាចអភិបាលតាមលក្ខន្តិកៈ

លក្ខន្តិកៈក្រុមហ៊ុន គឺជាលក្ខន្តិកៈដើម ឬ លក្ខន្តិកៈធ្វើការកែប្រែ។[79] ទោះបីសិទ្ធិ និងអំណាចមួយចំនួនរបស់អភិបាលត្រូវបានកំណត់ដោយច្បាប់ក៏ដោយ ក៏មានលក្ខខណ្ឌមួយចំនួន ដែលច្បាប់នេះបានទុកឱកាសឲ្យលក្ខន្តិកៈរបស់ក្រុមហ៊ុនជាអ្នកកំណត់អំពីការគ្រប់គ្រងផងដែរ។ ដូចជាបញ្ញត្តិអំពីលក្ខណសម្បត្តិដែលត្រូវក្លាយជាអភិបាល ច្បាប់បានទុកឲ្យលក្ខន្តិកៈរបស់ក្រុមហ៊ុនជាអ្នកដោះស្រាយនូវបញ្ហានេះ។[80] មួយវិញទៀត ទាក់ទងនឹងអាណត្តិរបស់អភិបាលក៏ច្បាប់មិនបានកំណត់នោះដែរ ប៉ុន្តែច្បាប់នេះបានទុកឲ្យលក្ខន្តិកៈជាអ្នកកំណត់នូវអាណត្តិរបស់អភិបាលហើយបើលក្ខន្តិកៈមិនបានចែងទេ ទើបអាណត្តិរបស់អភិបាលត្រូវយកតាមច្បាប់នេះ ដែលអភិបាលមានអាណត្តិពីរឆ្នាំ។[81] ម្យ៉ាងវិញទៀត ច្បាប់មិនបានកំណត់អំពីដំណាក់កាលនៃការបញ្ចប់អាណត្តិរបស់អភិបាលនោះដែរ អាណត្តិរបស់អភិបាល គឺត្រូវបានកំណត់ និងរៀបចំដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន។[82] ច្បាប់ក៏បានបង្ហាញយ៉ាងច្បាស់ថា លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចចែងអំពីសិទ្ធិរបស់ភាគហ៊ុនិក ដើម្បីជ្រើសរើសអភិបាលតាមរយៈការបោះឆ្នោត និងកំណត់នូវសិទ្ធិចាត់ចែងការងារផ្សេងៗរបស់អភិបាលផងដែរ។[83] មួយវិញទៀត ច្បាប់បានឲ្យសិទ្ធិទៅភាគហ៊ុនិកក្នុងការដកហូតមុខតំណែងរបស់អភិបាល តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាត ហើយការដកហូតនេះកើតឡើងពេលណាក៏បាន ទោះជាមាន ឬ គ្មានមូលហេតុក៏ដោយ។[84]

[77] Stephen M. Bainbridge, above n 63.
[78] Ibid.
[79] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ៨៨។
[80] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២០។
[81] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២១។
[82] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២២។
[83] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២៣។
[84] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១២៤។

តើគោលគំនិតនៃលក្ខន្តិកៈបានមកពីណា? នៅក្នុងសហរដ្ឋអាមេរិច បទប្បញ្ញត្តិនៃសិទ្ធិ និងអំណាចរបស់អភិបាល គឺត្រូវបានដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈមិនមែននៅក្នុងបញ្ញត្តិច្បាប់នោះទេ។[85] យោងតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន Maine Atlantic Granite Company (1836) មាត្រា ២ លើកឡើងថា អាជីវកម្មរបស់ក្រុមហ៊ុនត្រូវតែធ្វើឡើងដោយអភិបាលចំនួន៧នាក់ ដែលត្រូវជ្រើសរើសដោយភាគហ៊ុនិកជាប្រចាំ។[86] ក្រោយមក ការផ្តល់សិទ្ធិ និងអំណាចឲ្យអភិបាលតាមរយៈលក្ខន្តិកៈមិនត្រូវបានយកមកប្រើនោះទេ នៅក្នុងសហរដ្ឋអាមេរិច។ ស្ទើរតែគ្រប់រដ្ឋនៃសហរដ្ឋអាមេរិចច្បាប់ផ្តល់បញ្ញត្តិដែលលើកឡើងថា ក្រុមហ៊ុនត្រូវបានគ្រប់គ្រងដោយ ឬ ក្រោមទិសដៅនៃក្រុមប្រឹក្សាភិបាល ហើយទម្រង់នៃការគ្រប់គ្រងនេះ ក៏ក្លាយជាទម្រង់មួយដែលប្រើនៅបណ្តាប្រទេស ផ្សេងៗផងដែរ។[87] សិទ្ធិ និងអំណាចក្នុងការគ្រប់គ្រង ត្រូវបានកំណត់យ៉ាងច្បាស់ជាសិទ្ធិដែលទទួលបានពីការកំណត់ដោយច្បាប់ និងមិនអាចធ្វើប្រតិភូតសិទ្ធិបានទេ។[88]

យោងតាមបញ្ញត្តិនៃច្បាប់សហគ្រាសពាណិជ្ជកម្ម មានមាត្រាមួយចំនួនដែលបានបង្ហាញថាអំណាចរបស់ក្រុមប្រឹក្សាភិបាលបានមកពីភាគហ៊ុនិក ដោយក្នុងនោះភាគហ៊ុននិកមានទាំងសិទ្ធិ និងអំណាច ក្នុងការដកហូតសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល តាមរយៈលក្ខន្តិកៈរបស់ក្រុមហ៊ុន។[89] នៅក្នុងនេះ បានបង្ហាញឱ្យឃើញថាភាគហ៊ុនិក គឺជាម្ចាស់នៃសិទ្ធិ និងអំណាច ចំណែកអភិបាល គឺជាភ្នាក់ងារ។[90]

ហេតុនេះ ទើបអភិបាលត្រូវស្ថិតនៅក្រោមការបញ្ញត្តិរបស់ភាគហ៊ុនិក ហើយភាគហ៊ុនិកក៏ជាប្រភពនៃសិទ្ធិ និងអំណាចរបស់អភិបាលផងដែរ។ មិនតែប៉ុណ្ណោះ ភាគហ៊ុនិកមិនត្រឹមតែជាម្ចាស់សិទ្ធិ និងអំណាចនោះទេ តែក៏ជាអ្នកអនុវត្តការគ្រប់គ្រងរបស់ក្រុមហ៊ុនទៀត។[91] មានការលើកឡើងថា ភាពខុសគ្នានោះ គឺភាគហ៊ុនិកជាម្ចាស់នៃក្រុមហ៊ុន ដែលភាគហ៊ុនិកមានសិទ្ធិ លើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងផលចំណេញ។[92] នៅក្នុងទាំង២ករណីនេះ ភាគហ៊ុនិកមានសិទ្ធិកាន់កាប់មុខតំណែងមួយដែលមានឥទ្ធិពលជាម្ចាស់នៃសិទ្ធិ ចំណែកឯអភិបាល និងបុគ្គលិក គឺគ្រាន់តែជាភ្នាក់ងាររបស់ភាគហ៊ុនិកប៉ុណ្ណោះ។[93]

[85] Susan Watson, above n 61, 16.
[86] Ibid.
[87] Ibid 17.
[88] Ibid.
[89] Ibid 20.
[90] Ibid.
[91] Ibid 21.
[92] Ibid.
[93] Ibid.

# ផ្នែកទី៣៖ ទំនាក់ទំនងអភិបាល និងភាគីពាក់ព័ន្ធ

ការគ្រប់គ្រង និងសកម្មភាពរបស់ភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន មានសារៈសំខាន់ណាស់ ព្រោះថា វាគឺជាចំណុចមួយដែលសំខាន់បំផុតក្នុងការបែងចែក និងកំណត់ឲ្យមានតុល្យភាពរវាងអំណាច និងសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក ក្នុងគោលបំណងឲ្យដំណើរការនៃការអនុវត្តនូវអំណាចលើការសម្រេចចិត្តអោយបានត្រឹមត្រូវ និងជាប្រយោជន៍ដល់ក្រុមហ៊ុន។[94] នៅក្នុងនាមជាភាគហ៊ុនិក គឺជាបុគ្គលមួយរូបដែលយកប្រាក់ ឬ ទ្រព្យសម្បត្តិមកបណ្ដាក់ទុនដោយប្រើប្រាស់នូវក្រុមហ៊ុនដែលមានទម្រង់ស្របច្បាប់ដើម្បីរៀបចំជាក្រុមហ៊ុនមួយ។ ជាលទ្ធផលនៃការបណ្ដាក់ទុននេះ ភាគហ៊ុនិកទទួលបាននូវភាគហ៊ុន ហើយតាមរយៈភាគហ៊ុននេះ ភាគហ៊ុនិកទទួលបាននូវសិទ្ធិមួយចំនួនក្នុងការប្រើប្រាស់ដើម្បីការពារការបណ្ដាក់ទុននោះ។[95]

មានមតិលើកឡើងថា[96] ភាគហ៊ុនិក គឺជាបុគ្គលដែលទទួលបាននូវផលចំណេញ នៅពេលដែលម្ចាស់បំណុលទទួលបាននូវចំនួននៃការជំពាក់ និងបុគ្គលិកទទួលបាននូវប្រាក់ប្រចាំខែទៅតាមកិច្ចសន្យាការងាររបស់បុគ្គលិកនីមួយៗ ភាគហ៊ុនិក គឺជាបុគ្គលដែលទទួលបាននូវផលចំណេញចុងក្រោយគេបង្អស់ បន្ទាប់ពីការទូទាត់ចំណូលចំណាយរួចរាល់។ ហេតុដូចនេះ ទើបភាគហ៊ុនិកត្រូវទទួលបាននូវសិទ្ធិក្នុងការសម្រេចគោលនយោបាយរបស់ក្រុមហ៊ុន ទោះជាមានបញ្ហាដែលនាំឲ្យភាគហ៊ុនិកមិនអាចអនុវត្តការសម្រេចរបស់ខ្លួនជាប្រចាំក៏ដោយ ក៏អ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុនដូចជា អភិបាល ឬ អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនយល់ថា ភាគហ៊ុនិក គឺជាបុគ្គលដែលគ្រប់គ្រងលើក្រុមហ៊ុន ដោយសារភាគហ៊ុនិកមានសិទ្ធិក្នុងការសម្រេចខ្ពស់ជាងគេក្នុងក្រុមហ៊ុន។ ហើយបន្ថែមពីនេះ ការយល់ឃើញថា សិទ្ធិមួយចំនួនរបស់ភាគហ៊ុនិកត្រូវបានប្រមូលផ្ដុំគ្នា ហើយធ្វើការបោះឆ្នោតដើម្បីអនុវត្តបាននៅពេលណាមួយក៏បាន។ ទាំងនេះជាមូលហេតុដែលនាំឲ្យអភិបាល និងអ្នកគ្រប់គ្រងធ្វើសកម្មភាព និងប្រតិបត្តិក្នុងនាមផលប្រយោជន៍របស់ភាគហ៊ុនិក ដើម្បីអភិវឌ្ឍការងាររបស់ពួកគេ និងជៀសវាងការបណ្ដេញចេញពីការងារ។

ប៉ុន្តែ មកដល់ពេលនេះទ្រឹស្តីមួយនេះត្រូវបានលើកឡើងផ្ទុយពីនេះថា វាជាទ្រឹស្តីមួយដែលមិនពេញលេញនោះទេ។[97] ជាយូរណាស់មកហើយដែលភាគហ៊ុនិកធ្វើសកម្មភាពរួមគ្នាជាមួយភាគហ៊ុនិកដទៃទៀតនៅក្នុងការប្រជុំភាគហ៊ុនិក នេះគឺជាការសម្រេចដែលខ្ពស់បំផុត និងចុងក្រោយ

[94] Christoph Van der Elst, “Shareholder Rights and Shareholder Activism: The Role of the General Meeting of Shareholders”, 2.
[95] IR Global Rankings Team, “THE BOARD OF DIRECTORS AND SHAREHOLDERS”, (October 2010, issue 21), 1.
[96] Christoph Van der Elst, above n 94, 2-3.
[97] Ibid.

បំផុតនៅក្នុងក្រុមហ៊ុន។[98] ភាគហ៊ុនិកដឹកនាំរាល់គ្រប់អំណាចទាំងអស់នៅក្នុងក្រុមហ៊ុន ដែលមិនមានការផ្តល់អំណាចទៅឲ្យផ្នែកណាមួយក្នុងក្រុមហ៊ុននោះទេ។[99] មកដល់ពេលនេះភាគហ៊ុនិកនៅតែជាបុគ្គលដែលមានសិទ្ធិ និងអំណាចខ្ពង់ខ្ពស់នៅក្នុងក្រុមហ៊ុន ដែលស្គាល់ថាជាម្ចាស់នៃក្រុមហ៊ុន។[100] ផ្ទុយមកវិញ ភាគហ៊ុនិកគ្រាន់តែជាម្ចាស់នៃភាគហ៊ុនដែលធ្វើការបណ្តាក់ទុនទៅក្នុងក្រុមហ៊ុន ដែលមិនមែនជាម្ចាស់នៃក្រុមហ៊ុននោះទេ។[101] នៅពេលដែលមានភាគហ៊ុនិកច្រើននៅក្នុងក្រុមហ៊ុនមួយ នោះក្នុងម្ចាស់ភាគហ៊ុនក៏មានច្រើនទៅតាមចំនួននៃភាគហ៊ុនិក នេះនាំឲ្យចំនួននៃអំណាចនៅក្នុងដៃភាគហ៊ុនិក និងមហាសន្និបាតរបស់ភាគហ៊ុនិកក៏មិនទទួលបានទិន្នផលខ្ពស់។[102]

សព្វថ្ងៃនេះ ឥទ្ធិពលអំណាចត្រូវបានប្តូរទៅឲ្យក្រុមប្រឹក្សាភិបាល ហើយនៅក្នុងមហាសន្និបាតភាគហ៊ុនិកអាចសម្រេចទៅលើបញ្ហាដែលកំណត់ដោយច្បាប់ ឬ លក្ខន្តិកៈដែលមានចែង ផ្តល់សិទ្ធិក្នុងការសម្រេចទៅឲ្យមហាសន្និបាតភាគហ៊ុនិក ការប្រជុំនេះត្រូវប្រើវិធីបោះឆ្នោតដើម្បីសម្រេចបានលទ្ធផល។[103] ជាហេតុនាំឲ្យមានទំនាក់ទំនងមួយកើតឡើងរវាងអភិបាល និងភាគហ៊ុនិក **(៣.១)** មិនតែប៉ុណ្ណោះ នៅពេលដែលក្រុមហ៊ុនត្រូវបានគ្រប់គ្រងដោយអភិបាលចំពោះសកម្មភាពពាណិជ្ជកម្មប្រចាំថ្ងៃ អភិបាលក៏ត្រូវមានទំនាក់ទងជាមួយក្រុមប្រឹក្សាភិបាល **(៣.២)** ដើម្បីសម្រេចបានគោលដៅរបស់ក្រុមហ៊ុនផងដែរ។ ប៉ុន្តែ ចំណុចនេះមិនទាក់ទងទៅនឹងទំនាក់ទំនងរវាងអភិបាល និងតតិយជនដែលជាភាគីមួយដែលនៅក្នុងដំណើរការក្រុមហ៊ុននោះទេ ព្រោះថាច្បាប់ក្រុមហ៊ុនជាច្រើនមិនបានចែងទាក់ទងនឹងទំនាក់ទំនងរវាងក្រុមហ៊ុន និងតតិយជន តតិយជនដែលមានចែងនៅក្នុងច្បាប់ក្រុមហ៊ុននោះ គឺសំដៅទៅម្ចាស់បំណុលរបស់ក្រុមហ៊ុន មូលហេតុនេះមកពីគោលការណ៍នៃការទទួលខុសត្រូវមានកម្រិតរបស់ភាគហ៊ុនិក។[104]

---

[98] Ibid.
[99] Ibid.
[100] Andrew Keay, "Shareholder Primacy in Corporate Law: Can it Survive? Should it Survive?", 9-10.
[101] Ibid, Christoph Van der Elst.
[102] Ibid.
[103] Stephen M. Bainbridge, above n63, 21.
[104] Paul L Davies, "The Board of Directors: Composition, Structure, Duties and Powers, ORGANISATION FOR ECONOMIC CO-OPERATION AND DEVELOPMENT (OECD)", (7-8 Dec 2000, Stockholm Sweden), 4.

## ៣.១.ទំនាក់ទំនងអភិបាល និងភាគហ៊ុនិក

នៅក្នុងមហាសន្និបាតភាគហ៊ុនិក មិនត្រូវបានផ្តល់អំណាចទាំងអស់ទៅឲ្យភាគហ៊ុនិកនោះទេ មហាសន្និបាតភាគហ៊ុនិកមានការប្រជុំទាក់ទងនឹងការជ្រើសរើសក្រុមប្រឹក្សាភិបាល និងការសម្រេចសំខាន់ៗ ទាក់ទងនឹងក្រុមហ៊ុន។[105] បញ្ហាសំខាន់ៗរបស់ក្រុមហ៊ុនអាចជា ការកែប្រែលក្ខន្តិកៈរួមទាំងគោលបំណងរបស់ក្រុមហ៊ុន ការបញ្ចូលក្រុមហ៊ុន និងការរំលាយក្រុមហ៊ុន។ល។[106]

ប្រហាក់ប្រហែលគ្នាផងដែរ នៅប្រទេសកម្ពុជា ច្បាប់សហគ្រាសពាណិជ្ជកម្ម បានកំណត់អំពីកិច្ចការប្រជុំរបស់ភាគហ៊ុនិកជា២ គឺការប្រជុំមហាសន្និបាតភាគហ៊ុនិក និងការប្រជុំមហាសន្និបាតវិសាមញ្ញរបស់ភាគហ៊ុនិក។[107] ចំពោះការប្រជុំមហាសន្និបាតភាគហ៊ុនិក គឺជាការប្រជុំមួយដែលត្រូវតែធ្វើប្រចាំឆ្នាំ ចំណែកការប្រជុំមហាសន្និបាតវិសាមញ្ញវិញនោះ គឺធ្វើឡើងតែក្នុងករណីដែលចាំបាច់តែប៉ុណ្ណោះ។[108] នៅក្នុងច្បាប់នេះ ក៏ដូចជាបណ្តាប្រទេសដទៃទៀត ការប្រជុំភាគហ៊ុនិក គឺត្រូវធ្វើឡើងទៅតាមការកំណត់របស់លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហើយការប្រជុំនេះអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនមានការយល់ព្រមពីម្ចាស់ហ៊ុន។[109] ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់នោះ តាមច្បាប់របស់កម្ពុជាការប្រជុំភាគហ៊ុនិក ទាំងការប្រជុំមហាសន្និបាតប្រចាំឆ្នាំ និងការប្រជុំវិសាមញ្ញត្រូវបានផ្តល់នូវសិទ្ធិនៃការផ្តួចផ្តើមក្នុងការកោះប្រជុំទៅឲ្យក្រុមប្រឹក្សាភិបាល។[110] ចំណុចសម្គាល់នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មនេះ គឺត្រង់ទំនាក់ទំនងរវាងភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាលទាក់ទងនឹងការប្រជុំរបស់ភាគហ៊ុនិក។ ច្បាប់នេះបានកំណត់ថា ការប្រជុំមហាសន្និបាតភាគហ៊ុនិក ក៏អាចស្នើសុំឲ្យមានការកោះប្រជុំដោយភាគហ៊ុនិកបានដែរ ប៉ុន្តែត្រូវភ្ជាប់មកជាមួយនឹងគោលបំណង។ មួយវិញទៀតការស្នើសុំនោះអាចដាក់ស្នើបាន មានតែភាគហ៊ុនដែលមានប័ណ្ណភាគហ៊ុន ចាប់ពី៥១ភាគរយនៃប័ណ្ណរបស់ក្រុមហ៊ុន និងមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាត។[111] ប៉ុន្តែ លិខិតស្នើសុំនោះ ក៏អាចធ្វើឡើងតាមការ

---

105 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥(១) (ចាប់ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណី)។

106 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៩ (៥, ៦, ៨)។

107 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥, មាត្រា ២០៦។ see also ក្រមរដ្ឋប្បវេណី, មាត្រា ៩២-៩៣។

108 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥, មាត្រា ២០៦។

109 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥, មាត្រា ២០៥។

110 គុយ នាម, above n 53. 284-285.

111 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ មាត្រា ២០៧។

ចុះហត្ថលេខាដោយភាគហ៊ុនិកម្នាក់ ឬ ច្រើននាក់។ បន្ទាប់មកទៀត អភិបាលជាអ្នកចាត់ចែងចំពោះការរៀបចំប្រជុំដូចជា ជូនដំណឹងអំពីកាលបរិច្ឆេទនៃការប្រជុំ។[112]

ចំណុចដែលត្រូវលើកឡើងក្នុងមហាសន្និបាតភាគហ៊ុនិក ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរបាយការណ៍នេះត្រូវបានអនុញ្ញាតដោយអភិបាលព្រមទាំងមានចុះហត្ថលេខាផងនោះ ដែលរបាយការណ៍ទាំងនេះ ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាលមុនពេលដាក់ជូនមហាសន្និបាតភាគហ៊ុនិក។[113] ចំពោះប្រទេសមួយចំនួន ការអនុញ្ញាតចំពោះហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុនដោយអភិបាលនេះ ការប្រជុំមហាសន្និបាតភាគហ៊ុនិកនេះគឺទាក់ទងនឹងការសម្រេចរបស់មហាសន្និបាតក្នុងការបំពេញការងាររបស់អភិបាល មានន័យថា ប្រសិនបើអភិបាលបានប្រព្រឹត្តខុសទាក់ទងនឹងការសម្រេចលើហិរញ្ញវត្ថុ នោះអភិបាលនឹងប្រឈមនឹងការបណ្តេញចេញ។[114]

នៅក្នុងប្រទេសអាឡឺម៉ង់ មហាសន្និបាតរបស់ភាគហ៊ុនិក គឺមាននូវអំណាចពិសេសក្នុងការបញ្ឈប់សមាជិកនៃក្រុមប្រឹក្សាភិបាល។[115] ខុសពីប្រទេសអាឡឺម៉ង់ ប្រទេសអង់គ្លេសការប្រជុំមហាសន្និបាត ភាគហ៊ុនិកមិនមានឥទ្ធិពលលើអភិបាលនោះទេ ពីព្រោះនៅប្រទេសអង់គ្លេស ច្បាប់ក្រុមហ៊ុនជាអ្នកកំណត់នូវការបញ្ឈប់អភិបាល ក៏ដូចជាការធ្វើសកម្មភាពរបស់អភិបាលផងដែរ។[116] ប៉ុន្តែមហាសន្និបាតរបស់ភាគហ៊ុនិក អាចអនុម័តលើអាកប្បកិរិយារបស់អភិបាលដែលអាចទាក់ទងនឹងការទទួលខុសត្រូវចំពោះការបំពេញកិច្ចការ ចំពោះការធ្វេសប្រហែស ការខកខានមិនបានបំពេញកាតព្វកិច្ច ការល្មើសនឹងតួនាទី និងសេចក្តីទុកចិត្ត។[117]

នៅក្នុងប្រទេសបារាំង ក្រមពាណិជ្ជកម្មពុំមានចែងអំពីការបញ្ឈប់អភិបាល ឬ ក៏សកម្មភាពប្រចាំថ្ងៃនោះទេ ប៉ុន្តែក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំងបានលើកឡើងថា ការសម្រេចរបស់មហាសន្និបាតរបស់ភាគហ៊ុនិក ពុំអាចជាសិទ្ធិដើម្បីប្រឆាំងនឹងអភិបាលចំពោះការល្មើសនឹងតួនាទីនោះទេ។[118] ចំណែកនៅកម្ពុជា ច្បាប់សហគ្រាសពាណិជ្ជកម្ម មានចែងអំពីការលើកយកករណីរបស់ការស្នើសុំរបស់ភាគហ៊ុនិកមកពិភាក្សានៅក្នុងមាត្រា ២១៦។ មួយវិញទៀតភាគហ៊ុនិកអាចធ្វើការដកហូត សវនករ នៅក្នុងអង្គប្រជុំនេះបាន ប៉ុន្តែពុំមានមាត្រាផ្សេងនៃច្បាប់នេះនិយាយអំពីសិទ្ធិ

---

[112] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២០៧។

[113] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២២៥, ២២៦។

[114] Christoph Van der Elst, above n 94, 10.

[115] Ibid.

[116] Ibid.

[117] Ibid.

[118] Ibid.

របស់ម្ចាស់ហ៊ុនក្នុងការដេកតំណែងអភិបាលនោះទេ។[119] បន្ថែមពីនេះ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៩៥ កថាខណ្ឌទី១ បានចែងអំពីសេចក្តីសម្រេចរបស់មហាសន្និបាតសមាជិកដោយលើកឡើងថា អង្គប្រជុំនេះអាចធ្វើការសម្រេចសេចក្តីបានតែ ក្នុងករណីដែលច្បាប់បានកំណត់ ឬកំណត់ដោយលក្ខន្តិកៈ។ មាត្រានេះនឹងមិនត្រូវយកមកអនុវត្តនោះទេ ចំពោះករណីដែលលក្ខន្តិកៈមានចែងអំពីចំណុចដែលមហាសន្និបាតអាចសម្រេច។

នៅក្នុងក្រមនេះក៏បានកំណត់អំពីឯកសារ ដែលអភិបាលត្រូវដាក់ជូនអង្គប្រជុំមហាសន្និបាតភាគហ៊ុនិកផងដែរ ដែលជាទូទៅឯកសារដែលបានកំណត់នោះ គឺទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុ និងសកម្មភាពកិច្ចការរបស់ក្រុមហ៊ុនមាន ដូចជា តារាងតុល្យការ របាយការណ៍ ចំណេញខាត របាយការណ៍អំពីកិច្ចការ និងសេចក្តីព្រាងនៃសេចក្តីសម្រេចអំពីការចាត់ចែងប្រាក់ដែលនៅសល់ ឬ ដំណោះស្រាយចំពោះការខាតបង់។[120] ក្រៅពីទទួលបានសិទ្ធិតាមរយៈមហាសន្និបាតភាគហ៊ុនិក ភាគហ៊ុនិកក៏ទទួលបាននូវសិទ្ធិផងដែរតាមរយៈ មហាសន្និបាតវិសាមញ្ញ លក្ខន្តិកៈ និងច្បាប់ផងដែរ។ នៅក្នុងមហាសន្និបាតវិសាមញ្ញភាគហ៊ុនិកមានសិទ្ធិក្នុងការសម្រេចលើករណីចាំបាច់ ដែលអភិបាលយល់ឃើញថា វាជាការសម្រេចដែលត្រូវធ្វើឡើងដោយភាគហ៊ុនិក។[121] តាមរយៈលក្ខន្តិកៈភាគហ៊ុនិកមានសិទ្ធិ ព្រោះលក្ខន្តិកៈ គឺជាប្រភពមួយដែលភាគហ៊ុនិកមានសិទ្ធិ និងអំណាចក្នុងការគ្រប់គ្រងក្រុមហ៊ុនទាំងមូល។ ប៉ុន្តែ អ្វីដែលជាសំណួរចោទឡើង នៅក្នុងការទទួលបានសិទ្ធិ និងអំណាចគ្រប់បែបយ៉ាងរបស់ភាគហ៊ុនិកនៅក្នុងការគ្រប់គ្រង ទាំងដែលភាគហ៊ុនិកមិនមែនជាម្ចាស់នៃក្រុមហ៊ុននោះទេ គ្រាន់តែជាម្ចាស់នៃភាគហ៊ុននៅក្នុងក្រុមហ៊ុន និងជាសមាជិកនៅក្នុងក្រុមហ៊ុនម្នាក់តែប៉ុណ្ណោះ។[122] មានមតិមួយចំនួនលើកឡើងថា ទំនាក់ទំនងរវាងភាគហ៊ុនិក និងអភិបាលតាមរយៈសិទ្ធិ និងអំណាចនេះធ្វើឲ្យសម្រេចគោលបំណងរបស់ក្រុមហ៊ុន និងដើម្បីជាប្រភពមួយក្នុងការរក្សាផលប្រយោជន៍របស់ភាគហ៊ុនិកផងដែរ។ ទំនាក់ទំនងរវាងភាគហ៊ុនិក និងអភិបាលក្នុងការធ្វើឲ្យក្រុមហ៊ុនទទួលបានជោគជ័យនោះ គឺត្រូវមានការចូលរួមពី ភាគហ៊ុនិកនៅក្នុងការគ្រប់គ្រង ហើយមហាសន្និបាតភាគហ៊ុនិក គឺជាឱកាសមួយដ៏ប្រសើរ ដើម្បីពង្រឹងទំនាក់ទំនងផ្ទាល់ចំពោះភាគហ៊ុនិក និងអភិបាល។[123] ប៉ុន្តែ បញ្ហាដែលសំខាន់នោះ គឺនៅត្រង់ថា តើការចូលរួម

---

[119] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៣២។

[120] ក្រមរដ្ឋប្បវេណី, មាត្រា ៩៨។

[121] ក្រមរដ្ឋប្បវេណី, មាត្រា ៩៣។ see also ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២០៦។

[122] Christoph Van der Elst, above n 94, 4.

[123] IR Global Rankings Team, above n 95, 2.

របស់ភាគហ៊ុនិក តាមរយៈអង្គប្រជុំភាគហ៊ុនិកជាផ្នែកមួយនៃក្រុមហ៊ុនដើរតួនាទីជាអ្នកមានសិទ្ធិសម្រេចខ្ពស់ បានផ្តល់នូវការរីកចម្រើនដល់ក្រុមហ៊ុនដែរឬទេ។

ជាគោលគំនិត នៅក្នុងអង្គប្រជុំភាគហ៊ុនិកទំនាក់ទំនងរវាងភាគហ៊ុនិក និងអភិបាលនៅក្នុងអង្គប្រជុំ គឺជាក់របាយការណ៍ដែលក្រុមប្រឹក្សាភិបាលបានអនុម័តរួចហើយ អ្វីដែលអង្គប្រជុំអាចធ្វើបាន គឺដើរតួនាទីក្នុងការពិនិត្យរបាយការណ៍ដាក់ជូនដោយអភិបាល។[124] នៅក្នុងក្រុមហ៊ុនដែលអង្គប្រជុំភាគហ៊ុនិកមានតួនាទីបែបនេះ ជាទូទៅភាគហ៊ុនិកពុំមែនជាផ្នែកមួយនៃក្រុមហ៊ុនដែលមានសិទ្ធិក្នុងការសម្រេចខ្ពស់នោះទេ ព្រោះរាល់ពត៌មានផ្សេងៗទាក់ទងនឹងក្រុមហ៊ុន អភិបាលជាអ្នកដែលមានគ្រប់ពត៌មានទាំងអស់ ហើយអភិបាលក៏ជាអ្នកដែលចេញនូវគោលនយោបាយរបស់ក្រុមហ៊ុនផងដែរ។[125] ប្រសិនបើ ភាគហ៊ុនិកជាអ្នកមានសិទ្ធិសម្រេចខ្ពស់នៅក្នុងក្រុមហ៊ុន ភាគហ៊ុនិកគួរតែចូលរួម ក្នុងការកំណត់នូវគោលការណ៍របស់ក្រុមហ៊ុន ជាជាងគ្រាន់តែមានតួនាទីនៅក្នុងអង្គប្រជុំ ក្នុងការទទួលបានពត៌មានទាក់ទងនឹងសកម្មភាពពីមុនដែលអភិបាលបានអនុម័តរួចហើយនោះ។

## ៣.២.ទំនាក់ទំនងរវាងអភិបាល និងក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមិនមាននិយមន័យ នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជាទេ ប៉ុន្តែច្បាប់នេះបានលើកឡើងថា ក្រុមប្រឹក្សាភិបាលជាតួអង្គមួយនៅក្នុងក្រុមហ៊ុនដែលមានតួនាទីជាអ្នកចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន។[126] ពាក្យក្រុមប្រឹក្សាភិបាលនេះត្រូវបានឲ្យនិយមន័យនៅក្នុង ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈថា ជាក្រុមបុគ្គលដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតរបស់ភាគហ៊ុនិកនៅក្នុងមហាសន្និបាតរបស់ភាគហ៊ុនិក ហើយលក្ខន្តិកៈមានចែងអំពីសិទ្ធិអំណាចអនុវត្តភារកិច្ចរបស់អភិបាល។[127]

តួនាទីពីរសំខាន់របស់ក្រុមប្រឹក្សាភិបាល គឺទីមួយមានតួនាទីជាអ្នកប្រឹក្សា មានន័យថាក្រុមប្រឹក្សាភិបាល ត្រូវប្រឹក្សាជាមួយអ្នកគ្រប់គ្រងចំពោះគោលនយោបាយ និងដំណើរការ

[124] Christoph Van der Elst, above n 94, 19.
[125] Ibid.
[126] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១១៩។
[127] ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, លេខ០០២ គ ម ក ប្រការ ៨(១) (ចាប់ពីពេលនេះតទៅហៅថា ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម)។

ក្រុមហ៊ុន។[128] ទីពីរ គឺតួនាទីជាអ្នកត្រួតពិនិត្យ មានន័យថា ក្រុមប្រឹក្សាភិបាលត្រូវត្រួតពិនិត្យការអនុវត្តរបស់ក្រុមហ៊ុន និងកាត់បន្ថយការចំណាយផ្សេងៗដែលពុំចាំបាច់។[129] ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលត្រូវបានបែងចែងខុសពី ទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រង ដោយហេតុថា ក្រុមប្រឹក្សាភិបាលមិនមែនជាអ្នកគ្រប់គ្រងក្រុមហ៊ុននោះទេ។[130] ក្រុមប្រឹក្សាភិបាលត្រូវជ្រើសតាំងដោយភាគហ៊ុនិក ហើយក្រុមប្រឹក្សាភិបាលជាអ្នកជ្រើសរើសអភិបាលប្រតិបត្តិ និងក្រុមប្រឹក្សាប្រតិបត្តិ តួនាទីរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនគឺមានច្រើន និងមានឥទ្ធិពលខ្លាំងក្នុងការដឹកនាំ ព្រោះក្រុមប្រឹក្សាភិបាលជាអ្នកកំណត់នូវគោលការណ៍របស់ក្រុមហ៊ុន ដាក់ឲ្យអភិបាលប្រតិបត្តិ និងក្រុមប្រឹក្សាប្រតិបត្តិដើម្បីអនុវត្ត។[131] ពេលខ្លះត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលនូវរបាយការណ៍ទាក់ទងនឹងដំណើរប្រតិបត្តិការរបស់ក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ និងដំណើរការនៃការអនុវត្តគោលនយោបាយរបស់ក្រុមហ៊ុន នោះគ្រាន់តែជាការគ្រប់គ្រងមួយដែលធ្វើឲ្យមានការរីកចំរើននូវទំនាក់ទំនងល្អរវាង ភាគហ៊ុនិកនឹងក្រុមប្រឹក្សាប្រតិបត្តិការ និង រវាងក្រុមប្រឹក្សាភិបាលនឹងក្រុមប្រឹក្សាប្រតិបត្តិការ ដែលនេះមិនបានទទួលស្គាល់ថា ជាទំនាក់ទំនងដូចគ្នា រវាងក្រុមប្រឹក្សាភិបាលនឹងភាគហ៊ុនិកនោះទេ។[132] អភិបាលប្រតិបត្តិមិនមាននៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម របស់កម្ពុជាទេ ប៉ុន្តែ និយមន័យត្រូវបានឲ្យនៅក្នុងប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈថា ជាបុគ្គលិកដែលមានមុខតំណែងជាន់ខ្ពស់នៅក្នុងក្រុមហ៊ុន។[133] នៅក្នុងច្បាប់ពុំមានចែងពាក់ព័ន្ធនឹងគណនេយ្យភាពដែលក្រុមប្រឹក្សាភិបាលត្រូវមានចំពោះភាគហ៊ុនិកនោះទេ ហេតុនេះទើបភាគហ៊ុនិកមានសិទ្ធិតិចតួចក្នុងការគ្រប់គ្រង និងពុំមានឥទ្ធិពល ទៅលើសេចក្តីសម្រេចគោលនយោបាយដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។[134]

តួនាទីមួយចំនួនដែលក្រុមប្រឹក្សាភិបាលត្រូវមានទំនួលខុសត្រូវចំពោះ តួនាទីជាអ្នកប្រឹក្សា និងត្រួតពិនិត្យ (ក) អនុម័តលើគោលនយោបាយរបស់ក្រុមហ៊ុន (ខ) សាកល្បងគំរូពាណិជ្ជកម្ម និងកំណត់ការអនុវត្តសំខាន់ៗ (គ) កំណត់ចំណុចហានិភ័យ និងហានិភ័យដែលអាចកើតឡើងដោយ

---

[128] Lorne N. Switzer and Yu Cao, Shareholder Interest vs. Board of Director Member's Interests and the Profitability of Firms, (March 2011), 1.
[129] David F. Larcker, "Board of Director: Duties & Liabilities", (Stanford Graduate School of Business, Center for Leadership Development & Research), 2.
[130] Ibid.
[131] IR Global Rankings Team, above n 95, 1.
[132] Ibid.
[133] ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម, ប្រការ៥ (១៣)។
[134] IR Global Rankings Team, above n 95, 2.

ការគ្រប់គ្រង (ឃ) រៀបចំផែនការ និងជ្រើសរើសអភិបាលប្រតិបត្តិថ្មី (ង) រៀបចំកញ្ចប់ថវិកាសម្រាប់ប្រាក់ខែរបស់បុគ្គលិក (ច) ធានានូវភាពស្មោះត្រង់ចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលបានផ្សព្វផ្សាយ (ឆ) អនុម័តលើការទិញទ្រព្យសម្បត្តិសំខាន់ៗ (ជ) ការពារទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន (ឈ) តំណាងផលប្រយោជន៍របស់ភាគហ៊ុនិក (ញ) ធានាការគោរពច្បាប់របស់ក្រុមហ៊ុន។[135]

ក្រុមប្រឹក្សាភិបាលតម្រូវឲ្យមានឯករាជ្យភាព ហើយលក្ខណៈនៃឯករាជ្យភាពនេះត្រូវបានកំណត់ផ្សេងៗទៅតាមស្តង់ដានៃច្បាប់។[136] នៅសហរដ្ឋអាមេរិច ក្រុមប្រឹក្សាភិបាលអាចចាត់ទុកថាឯករាជ្យភាពបានលុះត្រាតែ (ក) ធ្វើសកម្មភាពក្នុងទំហំផលប្រយោជន៍របស់ក្រុមហ៊ុន (ខ) រួចផុតពីជម្លោះដែលត្រូវធ្វើការប្តឹងផ្តល់ (គ) មានលទ្ធភាពកាន់មុខតំណែងផ្សេងពីមុខតំណែងជាអ្នកគ្រប់គ្រង។[137] ដំណើរការរបស់ក្រុមប្រឹក្សាភិបាល គឺមានអធិបតេយ្យភាពពីប្រធានក្រុមប្រឹក្សាភិបាល ជាអ្នកកំណត់នូវរបៀបវារៈ កំណត់ពេលវេលានៃការប្រជុំ សម្របសម្រួលសកម្មភាពរបស់គណៈកម្មាធិការ។[138] ការសម្រេចនៅក្នុងក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយសំឡេងឆ្នោតមតិភាគច្រើន ដើម្បីធ្វើការសម្រេចនេះ ក្រុមប្រឹក្សាភិបាលមានការពឹងផ្អែកទៅលើឯកសារដែលដាក់ឲ្យដោយអ្នកគ្រប់គ្រង មានដូចជា អភិបាលប្រតិបត្តិ ឬ ប្រធានគណៈកម្មាធិការផ្សេងៗ។[139] ប៉ុន្តែ ទោះជាមានការសម្រេចដោយក្រុមប្រឹក្សាភិបាលក៏ដោយ ក៏បញ្ហាមួយចំនួនរបស់ក្រុមហ៊ុនត្រូវបានផ្ទេរទៅឲ្យ អភិបាលម្នាក់ៗ ឬ ទៅគណៈកម្មាធិការផ្សេងៗនៅក្នុងក្រុមហ៊ុនផងដែរ។ នៅក្នុងករណីសំខាន់ ការស្នើលើបញ្ហារបស់គណៈកម្មាធិការត្រូវបានដាក់ឲ្យអនុវត្តមុននឹងធ្វើការបោះឆ្នោតយល់ព្រមពីក្រុមប្រឹក្សាភិបាល។[140] ក្នុងក្រុមប្រឹក្សាភិបាលតម្រូវឲ្យមានគណៈកម្មាធិការដូចជា សវនកម្ម ប្រាក់បៀវត្ស និងគណៈកម្មាធិការតែងតាំង និងគ្រប់គ្រង។[141] អភិបាលត្រូវធ្វើការរួមគ្នាជាមួយអភិបាលដទៃទៀតនៅក្នុងក្រុមប្រឹក្សាភិបាល អភិបាលទាំងអស់ត្រូវធ្វើសកម្មភាពដោយគោរពទៅនឹងគោលការណ៍ Fiduciary Duty។[142] ដោយសារគោលការណ៍ Fiduciary Duty នេះអភិបាល ក៏ដូចជាក្រុមប្រឹក្សាភិបាលត្រូវមានកាតព្វកិច្ចតាមច្បាប់ក្នុងការបំពេញ

[135] David F. Larcker, above n 129, 3

[136] Ibid 4.

[137] Ibid.

[138] Ibid 5.

[139] Ibid.

[140] Ibid 6.

[141] Ibid.

[142] Julian Velasco, HOW MANY FIDUCIARY DUTIES ARE THERE IN CORPORATE LAW?, University of Notre Dame (Notre Dame Law School, Legal Studies Research Paper No. 09-35), (Southen California Law Review: No. 6, Vol. 83, 2010), 1278.

ការងារ (ក) អភិបាលត្រូវធ្វើការសម្រេចដោយយកចិត្តទុកដាក់ និងមានការពិភាក្សាខ្ពស់ (ខ) តម្រូវឲ្យអភិបាលធ្វើសកម្មភាពក្នុងនាមផលប្រយោជន៍របស់ក្រុមហ៊ុន (គ) តម្រូវឲ្យក្រុមប្រឹក្សាភិបាលផ្តល់ពត៌មានដល់ភាគហ៊ុនិក ព្រោះវាសំខាន់ក្នុងការវាយតម្លៃក្រុមហ៊ុន។[143] នៅក្នុងក្រុមហ៊ុនអភិបាលអាចត្រូវបែងចែកជា អភិបាលប្រតិបត្តិ (Executive Director) និងអភិបាលមិនប្រតិបត្តិ (Non Executive Director or Independent Director) ។[144]

នៅក្នុងទំនាក់ទំនងរវាងអភិបាល និងក្រុមប្រឹក្សាភិបាលពុំមានផ្នែកណាដែលនាំឲ្យមានបញ្ហានោះទេ ប៉ុន្តែរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាភិបាលអាចនឹងត្រូវបានផ្លាស់ប្តូរដោយមានការបែងចែកតួនាទីរបស់អភិបាល ក្នុងការបង្កើនគុណភាពនៃការដឹកនាំ និងគ្រប់គ្រង។[145] អភិបាលនៅក្នុងចំណុចនេះសំដៅទៅលើអភិបាលប្រតិបត្តិ Chief Executive Director (CEO) នៅពេលដែលក្រុមហ៊ុនមួយមានក្រុមប្រឹក្សាភិបាលមួយឯករាជ្យ និងមានអភិបាលប្រតិបត្តិ (CEO) ទម្រង់នៃការគ្រប់គ្រងនេះហៅថា Two-Tier Corporate board ។[146] ប្រព័ន្ធនេះភាគច្រើនគេឃើញមាននៅក្នុងក្រុមហ៊ុនរបស់ប្រទេសអង់គ្លេស ហើយវាមានបញ្ហាមួយកើតឡើង គឺចំពោះតួនាទីរបស់អភិបាលដែលជាអភិបាលមិនប្រតិបត្តិ (Non Executive Director) ជាបុគ្គលដែលមានសិទ្ធិ និងអំណាចគ្រប់គ្រងនៅក្នុងក្រុមហ៊ុន និងជាអ្នកកំណត់នូវគោលការណ៍ដាក់ចេញឲ្យអនុវត្ត។[147] មួយវិញទៀតអភិបាលប្រតិបត្តិ (Chief Executive Director) ក៏មាននូវតួនាទីប្រហាក់ប្រហែលនឹងអភិបាលនៅក្នុងក្រុមប្រឹក្សាភិបាលដែរ។[148] ប៉ុន្តែ បញ្ហានេះអាចនឹងគ្មាននោះទេសម្រាប់ប្រទេសកម្ពុជា ព្រោះថានៅពេលដែលក្រុមហ៊ុនសម្រេចយកប្រព័ន្ធនៃការគ្រប់គ្រងក្រុមហ៊ុនរបស់គេនោះ គោលការណ៍មួយចំនួននឹងត្រូវបានបង្កើតឡើងសម្រាប់ជាការដឹកនាំនៅក្នុងក្រុមហ៊ុននោះ។ ប៉ុន្តែ បញ្ហាអាចនឹងកើតមាននៅត្រង់ថា តើអភិបាលប្រតិបត្តិ (Chief Executive Director) នឹងត្រូវយកច្បាប់ណាមកគ្រប់គ្រងចំពោះការប្រព្រឹត្តរបស់អភិបាលនេះ ហើយច្បាប់សហគ្រាសពាណិជ្ជកម្មអាចនឹងអនុវត្តដែរឬទេ?

នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម ពុំឃើញមានបញ្ញត្តិណាមួយបានចែងអំពីជម្រើសដែលក្រុមហ៊ុនមូលធនត្រូវជ្រើសរវាង Single Tier Board និង Two-Tier Corporate Board នោះទេ។ ការអនុវត្តឃើញថា ធនាគារអេស៊ីលីដា មានការគោរពខ្ពស់ទាក់ទងនឹងអភិបាលកិច្ចសាជីវកម្មមាន

---

[143] David F. Larcker, above n129, 13.

[144] David Block and Anne-Marie Gerstner, One-Tier vs. Two-Tier Board Structure: A Comparison Between the United States and Germany, (2016), Comparative Corporate Governance and Financial Regulation, Paper 1, 6.

[145] Nicolene Schoeman, “EXECUTIVE AND NON-EXECUTIVE DIRECTOR IN TERMS OF THE NEW COMPANIES ACT”, (Schoeman Attorneys, 2011), 1-2.

[146] David Block and Anne-Marie Gerstner, above n 144.

[147] Ibid.

[148] Ibid.

រចនាសម្ព័ន្ធនៅធនាគារហាក់បីដូចជាប្រើ Two-Tier Corporate Board ដែលមានភាគហ៊ុនិកជាអ្នកជ្រើសរើសក្រុមប្រឹក្សាភិបាល ដើរតួនាទីក្នុងនាមជា Supervisory Board ហើយក្រុមប្រឹក្សាភិបាលនេះជាអ្នកតែងតាំង Executive Board ក្នុងការអនុវត្តគោលការណ៍នានារបស់ធានាគារ។[149] ចំណែកឯ រចនាសម្ព័ន្ធដែលចាំបាច់សម្រាប់ក្រុមហ៊ុនមូលធន មានកំណត់នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មនោះ បានលើកឡើងថា ក្រុមប្រឹក្សាភិបាលត្រូវបានបង្កើតឡើងដោយភាគហ៊ុនិក ហើយក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងតាមការចាំបាច់ក្នុងការសម្រេចការងាររបស់ខ្លួនដោយមានអភិបាលម្នាក់ ឬ ច្រើននាក់ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការនោះផងដែរ តាមរយៈការផ្ទេរអំណាចពីក្រុមប្រឹក្សាភិបាល។[150] តាមរយៈការគ្រប់គ្រងរចនាសម្ព័ន្ធបែបនេះមាននៅបណ្តាប្រទេសមួយចំនួន ដូចជាសហរដ្ឋអាមេរិចដែលប្រើរចនាសម្ព័ន្ធ Single Tier Board។ម្យ៉ាងវិញទៀត នៅក្នុងទម្រង់បែបនេះពុំមានក្រុមអភិបាលផ្សេងនោះទេ ក្រៅពីក្រុមប្រឹក្សាភិបាល ប៉ុន្តែ មានអ្នកគ្រប់គ្រងក្រុមហ៊ុនជាបុគ្គលិកជាន់ខ្ពស់ មិនមានជា CEO ដែលត្រូវជ្រើសតាំងនៅក្នុង Executive Board នោះទេ។[151]

ទំនាក់ទំនងរវាងអភិបាល និងក្រុមប្រឹក្សាភិបាលនៅកម្ពុជា គឺក្រុមប្រឹក្សាភិបាលដើរតួនាទីពីរជាអ្នកសម្រេចនូវកិច្ចការក្រុមហ៊ុន និងជាអ្នកផ្តល់ប្រឹក្សាដល់គណៈកម្មាធិការផ្សេងៗដែលដឹកនាំដោយអភិបាល។[152] ក្រុមប្រឹក្សាភិបាលមានទំនាក់ទំនងផ្ទាល់តែជាមួយនឹងអភិបាលនៅក្នុងក្រុមប្រឹក្សាភិបាល ដែលបានតែងតាំងជាប្រធាននៃគណៈកម្មាធិការ។[153] ចំណែកឯ Two-Tier Corporate Board អភិបាលនៅក្នុងក្រុមប្រឹក្សាភិបាលមានទំនាក់ទំនងផ្ទាល់ជាមួយអភិបាលនៃ Executive Board ក្នុងការធ្វើប្រតិបត្តិការក្រុមហ៊ុន នៅក្នុងរចនាសម្ព័ន្ធបែបនេះ តួនាទីរបស់ក្រុមប្រឹក្សាភិបាល និង Executive Board ត្រូវធ្វើការបែងចែកឲ្យដាច់ពីគ្នា ប៉ុន្តែទំនាក់ទំនងដែលមានរវាងក្រុមប្រឹក្សាភិបាល និងអភិបាលដែលបានតែងតាំងជាប្រធាននៃគណៈកម្មាធិការនោះ គឺជាទំនាក់ទំនងដែលប្រើតាមការផ្ទេរអំណាចត្រឹមមួយចំនួនប៉ុណ្ណោះ។[154]

នៅក្នុងការបែងចែកអភិបាលទៅជាអភិបាលនៅក្នុងក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិនេះមិនមានការជួយអ្វីដល់ការអនុវត្តគោលការណ៍របស់ក្រុមហ៊ុនទេ ឬ ដើម្បីកំណត់តួនាទី

[149] រចនាសម្ព័ន្ធធនាគារអេស៊ីលីដា, available at: https://www.acledabank.com.kh/kh/eng/ff_orgchart.

[150] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣១។

[151] David Block and Anne-Marie Gerstner, above n 144, 6.

[152] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣១។

[153] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣១។

[154] David Block & Anne-Marie Gerstner, above n 144, 7.

ច្បាស់លាស់ក្នុងក្រុមហ៊ុន ឬ ក្នុងកាលៈទេសៈណាផ្សេងដែលជាតម្រូវការនោះទេ។[155] ម៉្យាងវិញទៀតពុំត្រូវបានរកឃើញការបែងចែកអំពីអភិបាលណាដែលមានចែងនៅក្នុងច្បាប់ដែរ។ ចំពោះនៅក្នុងប្រទេស Common Law នៅពេលដែលអភិបាលទទួលការតែងតាំងក្នុងតំណែងជាអភិបាលនេះមានន័យថា អភិបាលនោះមាន Fiduciary duty ជាមួយក្រុមហ៊ុន និងមានកាតព្វកិច្ចក្នុងការបង្ហាញអំពីភាពស្មោះត្រង់ចំពោះក្រុមហ៊ុន និងចំពោះកិច្ចប្រតិបត្តិការណ៍អាជីវកម្មផង។[156] ទាំងនេះគ្រាន់តែជាលក្ខខណ្ឌទូទៅ ហើយជាបទប្បញ្ញត្តិមួយដែលត្រូវយកមកអនុវត្តទៅលើកាលៈទេសៈមួយជាក់លាក់ដោយអាស្រ័យលើធាតុនៃអង្គហេតុ។[157]

[155] Deloitte Touche Tohmastsu Limited, *Duties of Directors*, (UK, April 2013), 22, available at: https://www2.deloitte.com/content/dam/Deloitte/za/Documents/governance-risk-compliance/ZA_DutiesOfDirec 201 _16042014.pdf.
[156] Ibid.
[157] Ibid.

## ជំពូកទី២៖ ការទទួលខុសត្រូវរបស់អភិបាល

ទន្ទឹមនឹង អភិបាលមានមុខតំណែងរបស់ខ្លួនក្នុងការគ្រប់គ្រងដឹកនាំ និងកំណត់គោលនយោបាយរបស់ក្រុមហ៊ុន អភិបាលក៏ក្លាយជាអ្នកត្រួតពិនិត្យចំពោះបុគ្គល ដែលស្ថិតនៅក្រោមអំណាច។[158] អភិបាលត្រូវបានកំណត់ឲ្យមានការទទួលខុសត្រូវជាច្រើន ហើយការទទួលខុសត្រូវនេះគឺ ផ្អែកសំខាន់ទៅលើករណីដែលអភិបាលមិនបានធ្វើសកម្មភាព ដែលជាប្រយោជន៍ខ្ពស់បំផុតរបស់ក្រុមហ៊ុនក្នុងការបំពេញតួនាទីដោយល្មើសនឹងសិទ្ធិ និងអំណាចជាអភិបាលជាដើម។[159] នៅពេលដែលមានការល្មើសកើតមាន អភិបាលនឹងត្រូវទទួលខុសត្រូវដោយសារភាគហ៊ុនិកប្រើសិទ្ធិបណ្ដឹងជំនួសមុខឲ្យក្រុមហ៊ុនក្នុងការប្ដឹងអភិបាលពីការប្រព្រឹត្តមិនគប្បី។[160] ការទទួលខុសត្រូវរបស់អភិបាលអាចជា ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌដែលបានប្រព្រឹត្តដោយអភិបាលនោះ ឬ ដោយបុគ្គលិកស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន។ ការទទួលខុសត្រូវរបស់អភិបាលមិនបានភ្ជាប់ទៅនឹងក្រុមប្រឹក្សាភិបាលនោះទេ បើទោះបីក្រុមប្រឹក្សាភិបាលជារចនាសម្ព័ន្ធមួយរបស់ក្រុមហ៊ុនក៏ដោយ ពីព្រោះថាក្រុមប្រឹក្សាភិបាលពុំមានបុគ្គលភាពគតិយុត្តិ ដូចនេះទើបការទទួលខុសត្រូវគឺជាការទទួលខុសត្រូវរបស់អភិបាលម្នាក់ៗ។[161]

ច្បាប់សហគ្រាសពាណិជ្ជកម្ម បានកំណត់ការទទួលខុសត្រូវរបស់អភិបាលជា ២យ៉ាងគឺ អភិបាលពេលខ្លះអាចត្រូវទទួលខុសត្រូវដោយផ្ទាល់ និងដោយរួមគ្នា។ មូលហេតុដែលនាំឲ្យមានការទទួលខុសត្រូវគឺ អាស្រ័យទៅលើសកម្មភាពនៅពេលប្រព្រឹត្ត ថាតើសកម្មភាពនោះជាការប្រព្រឹត្តដោយល្មើសនឹងសិទ្ធិ និងអំណាចស្របច្បាប់ ឬ ជាកំហុសនៃការដឹកនាំ។ ការបែងចែកនេះនឹងបង្ហាញឲ្យឃើញថា សកម្មភាពណាដែលអភិបាលត្រូវទទួលខុសត្រូវដោយផ្ទាល់ និងរួមគ្នាក្នុងនាមជាអភិបាលបោះឆ្នោតក្នុងមហាសន្និបាត។ ចំពោះការទទួលខុសត្រូវរបស់អភិបាលនៅក្នុងក្រុមហ៊ុនប្រទេសអង់គ្លេស គឺផ្អែកទៅលើសកម្មភាពទាំងឡាយណាដែលអភិបាលបានប្រព្រឹត្តល្មើសនឹងតួនាទី។[162] ចំណែកឯនៅប្រទេសបារាំងវិញ តុលាការកំពូលរបស់បារាំង បានលើកឡើងថា សមាជិកនីមួយៗរបស់ក្រុមប្រឹក្សាភិបាលដែលធ្វើសកម្មភាព ឬ មិនបោះឆ្នោត ឬ ចូលរួមនៅក្នុងការសម្រេចខុសរបស់ក្រុមប្រឹក្សាភិបាល គឺជាអភិបាលដែលត្រូវទទួលខុសត្រូវ លុះត្រាតែមានការលើកឡើងថា អភិបាលនោះធ្វើសកម្មភាពយ៉ាងប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ការពារផល

[158] Carsten Gerner-Beuerle, Philipp Paech & Edmund Philipp Schuster, “Study on Director’s Duties and Liability”, (London, April 2013), 170.
[159] Ibid.
[160] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៨៧។
[161] Carsten Gerner-Beuerle, Philipp Paech & Edmund Philipp Schuster, above n 158.
[162] Ibid.

ប្រយោជន៍ក្រុមហ៊ុនប្រឆាំងនឹងការសម្រេចខុសនោះ។[163] នៅកម្ពុជា ច្បាប់សហគ្រាសពាណិជ្ជកម្ម បានចែងថា នៅក្នុងការប្រជុំមហាសន្និបាតក្រុមប្រឹក្សាភិបាល ប្រសិនបើអភិបាលមិនបានធ្វើការជំទាស់ មុនពេលការបិទប្រជុំក្រុមប្រឹក្សាភិបាលនោះទេ ត្រូវចាត់ទុកថាបានយល់ព្រម រាល់ការសម្រេចអំពីផែនការ ឬ សកម្មភាពដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។[164] មួយវិញទៀត ចំពោះអភិបាលដែលអវត្តមាន អភិបាលនោះមានពេលរយៈពេល ១៥ថ្ងៃ ពីថ្ងៃដែលទទួលបានដំណឹងក្នុងការជំទាស់។[165] ប្រសិនមិនមានការជំទាស់ទេ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬ សកម្មភាពដែលបានធ្វើរួចហើយ ត្រូវចាត់ទុកថាយល់ព្រមដោយអភិបាលដែលអវត្តមាននោះ។[166] ការទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នារបស់អភិបាលដែលមានចែងនៅក្នុងច្បាប់នេះមានពីរករណី គឺករណីអនុញ្ញាតឲ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូលដែលមិនមែនជាសាច់ប្រាក់ និងករណីបោះឆ្នោតយល់ព្រមឲ្យទិញភាគហ៊ុនក្រុមហ៊ុនដែលបានលក់មកវិញ ឬ ការកាត់បន្ថយដើមទុន ឬ ការបែងចែកភាគលាភដែលផ្ទុយនឹងច្បាប់។[167] ចំពោះករណី ការផ្សព្វផ្សាយពត៌មានក្លែងក្លាយនៅក្នុងប្រទេសអាឡឺម៉ង់ ការទទួលខុសត្រូវដោយផ្ទាល់ផ្នែករដ្ឋប្បវេណីរបស់អភិបាលស្មើរតែសូន្យ។[168] ប៉ុន្តែ មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើសកម្មភាពល្មើសមួយដែលចាត់ទុកថាជាការទទួលខុសត្រូវព្រហ្មទណ្ឌ សកម្មភាពតែមួយនេះក៏ត្រូវតែមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនៅក្នុងនោះដែរ។[169] ប្រសិនបើសកម្មភាពមួយដែលចាត់ទុកថាជាការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី សកម្មភាពដដែលនេះតម្រូវឲ្យមានស្តង់ដាខ្ពស់ក្នុងការកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌ។[170] ចំពោះច្បាប់សហគ្រាសពាណិជ្ជកម្មនៅកម្ពុជា មានការល្មើសខ្លះដែលពាក់ព័ន្ធនឹងការត្រូវទទួលខុសត្រូវ ផ្នែករដ្ឋប្បវេណី និងបទល្មើសខ្លះទៀត ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[171] ប៉ុន្តែ ការទទួលខុសត្រូវរដ្ឋប្បវេណីនេះក៏មាននៅក្នុងច្បាប់ពាក់ព័ន្ធដូចជា ច្បាប់ការងារ ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ។

---

163 Ibid 164.

164 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៤០។

165 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា១៤២។

166 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៤២។

167 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៤០ និង១៤១។

168 MANEUL LADIEGES, “CRIMINAL LIABILITY OF DIRECTORS OF A PRIVATE LIMITED COMPANY SEATED IN GERMANY”, *Springerlink.com*, (DOI 10.1007/s10609-012-9189-x), (2013), 100.

169 Ibid.

170 Carsten Gerner-Beuerle, Philipp Paech & Edmund Philipp Schuste, above n 158.

171 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៩០។

នៅក្នុងអត្ថបទនេះ នឹងលើកយកការល្មើសរបស់អភិបាលដែលកំណត់ដោយច្បាប់ការងារពាក់ព័ន្ធអនាម័យ និងសន្តិសុខរបស់និយោជិត និងការល្មើសទាក់ទងនឹងអំពើអនីត្យានុកូលរបស់នីតិបុគ្គលនៅក្នុងក្រមរដ្ឋប្បវេណី **(ផ្នែកទី២)**។ ចំណែកឯការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌវិញ យោងតាមក្រមព្រហ្មទណ្ឌ មានចែងអំពីការទទួលខុសព្រហ្មទណ្ឌរបស់នីតិបុគ្គល ហើយជាគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ជាការទទួលខុសត្រូវដាច់ដោយឡែករបស់បុគ្គលម្នាក់ៗ។ អត្ថបទនេះនឹងលើកអំពីបទល្មើសពីរដែលអភិបាលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺបទល្មើសទាក់ទងនឹង បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល និងបទស៊ីសំណូករបស់អភិបាល **(ផ្នែកទី៣)**។ រីឯ **(ផ្នែកទី១)** នៅក្នុងជំពូកនេះនឹងលើកពិភាក្សាអំពី សកម្មភាពដែលនាំឲ្យមានការទទួលខុសត្រូវដោយអភិបាល មានន័យថា នឹងធ្វើការកំណត់អំពីការបំពានដល់បញ្ញត្តិច្បាប់ការល្មើសនឹងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬ កំហុសកើតឡើងដោយការដឹកនាំ។

## ផ្នែកទី១៖ ការប្រព្រឹត្តខុសតួនាទីរបស់អភិបាល

សកម្មភាពមួយចំនួនប្រព្រឹត្តដោយអភិបាល មិនសុទ្ធតែចាត់ទុកថាប្រព្រឹត្តដែលផ្ទុយនឹងច្បាប់កំណត់នោះទេ តែវាអាចជាការប្រព្រឹត្តលើសពីសិទ្ធិ និងអំណាចស្របច្បាប់។[172] សកម្មភាពនោះមិនមានប៉ះពាល់ដល់ច្បាប់ណាមួយទេ ដូចជា សកម្មភាពដែលអភិបាលធ្វើការចុះកិច្ចសន្យាជាមួយតតិយជនដោយមិនមានការយល់ព្រមពីភាគហ៊ុនិក។[173] សកម្មភាពនេះ វាជាការប្រព្រឹត្តផ្ទុយនឹងសិទ្ធិ និងអំណាចស្របច្បាប់ដែលផ្តល់ឲ្យដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន។[174] មួយវិញទៀត សកម្មភាពនៃការដឹកនាំ របស់អភិបាលក៏អាចនាំឲ្យខុស ដែលអាចធ្វើឲ្យខូចប្រយោជន៍របស់ភាគហ៊ុនិកដែរ សកម្មភាពនេះកើតឡើងបានដោយសារការធ្វេសប្រហែសជាដើម។[175] សកម្មភាពនេះ ក៏នាំឲ្យមានការទទួលខុសត្រូវរបស់អភិបាលដែរ កំហុសដែលកើតឡើងដោយការធ្វេសប្រហែស និងមកពីការដឹកនាំរបស់អភិបាលនេះដែលតែងតែកើតមាន ហេតុនេះសកម្មភាពរបស់អភិបាលមួយចំនួនត្រូវបានចាត់ទុកថាជាកំហុស។[176] ផ្នែកនេះនឹងធ្វើការបកស្រាយសកម្មភាពដែលនាំឲ្យអភិបាលមានការទទួលខុសត្រូវលើចំណុចពីរគឺ សកម្មភាពប្រព្រឹត្តលើសសិទ្ធិ និងអំណាចស្របច្បាប់ (១.១) និងសកម្មភាពជាកំហុសពីការដឹកនាំ (១.២)។

[172] Roger LeRoy Miller & Gaylord A. Jentz, above n 27, 311.
[173] Ibid.
[174] Ibid 312.
[175] Ibid 133.
[176] Ibid.

## ១.១.ការល្មើសសិទ្ធិ និងអំណាចស្របច្បាប់

ទំនួលខុសត្រូវរបស់អភិបាលត្រូវបានរៀបរាប់នៅក្នុងជំពូកទី១រួចមកហើយ ប៉ុន្តែជាសរុបមកទំនួលខុសត្រូវដែលសំខាន់ និងជាប្រចាំរបស់អភិបាល ហើយអភិបាលមិនអាចធ្វើការអនុម័តយល់ព្រមតែម្នាក់ឯងនោះ មានន័យថាអភិបាលត្រូវបំពេញកាតព្វកិច្ចជាក្រុមនៅក្នុងក្រុមប្រឹក្សាភិបាល ដោយអភិបាលម្នាក់មានសំឡេងឆ្នោតមួយ។[177] ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលមានដូចជា (ក) ការប្រកាស និងបែងចែកភាគលាភទៅភាគហ៊ុនិក (ខ) អនុម័តចំពោះគោលការណ៍របស់ក្រុមហ៊ុន។ ឧទាហរណ៍ ដំណាក់កាលនៃការលក់ ឬ ជួលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនក្រៅពីសកម្មភាពពាណិជ្ជកម្មប្រចាំ ត្រួតពិនិត្យការចរចាកិច្ចសន្យាធំៗ និងការគ្រប់គ្រងលើការចរចាការងារជាដើម (គ) តែងតាំង ត្រួតពិនិត្យ និងដកហូតបុគ្គលិកក្រុមហ៊ុន និងកំណត់ប្រាក់បៀវត្ស។[178] ការទទួលខុសត្រូវរបស់អភិបាលចំពោះក្រុមហ៊ុន ក្នុងករណីណាដែលបាត់បង់នូវផលប្រយោជន៍ដែលកើតឡើង ដោយសារសកម្មភាពដែលមានចែងនៅក្នុងច្បាប់ លក្ខន្តិកៈ ឬ បទបញ្ញាផ្ទៃក្នុងផ្សេងៗរបស់ក្រុមហ៊ុន។[179] ករណីនេះអាចជាការធ្វើសកម្មភាពណាមួយខុសច្បាប់ ឬ ការសម្រេចដោយធ្វេសប្រហែស មានដូចជា ការបែងចែកភាគលាភដោយខុសច្បាប់។[180] ទោះជាមានការទទួលខុសត្រូវក៏ដោយ ក៏មាននូវបញ្ញត្តិលើកលែងចំពោះអភិបាលដែលបានធ្វើសកម្មភាពប្រឆាំងនឹងសកម្មភាពខុសច្បាប់តាមរយៈជូនដំណឹងអំពីការជំទាស់ទៅអង្គប្រជុំ ដើម្បីចៀសវាងពីការទទួលខុសត្រូវ។

ម៉្យាងវិញទៀត នៅក្នុងគោលការណ៍នៃ Respondeat Superior ក្រុមហ៊ុនអាចនឹងត្រូវទទួលខុសត្រូវដោយសារសកម្មភាពប្រព្រឹត្ត ជាផ្នែកមួយនៃអំពើអនីត្យានុកូល ហើយសកម្មភាពនោះបានប្រព្រឹត្តដោយអភិបាល បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន។[181] ប៉ុន្តែ ករណីនៃការទទួលខុសត្រូវដោយក្រុមហ៊ុននេះគឺ ចំពោះតែករណីដែលសកម្មភាពនោះប្រព្រឹត្តក្នុងពេលបំពេញអាជីវកម្មរបស់ក្រុមហ៊ុន។[182] មិនត្រឹមតែត្រូវទទួលខុសត្រូវរដ្ឋប្បវេណីនោះទេ នៅក្នុងករណីដែលការប្រព្រឹត្តដោយអភិបាល បុគ្គលិក ឬ ភ្នាក់ងារនោះជាសកម្មភាពដែលស្ថិតក្នុងរង្វង់នៃការងារក៏ក្រុមហ៊ុនអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដោយគ្មានការលើកឡើងថា ក្រុមហ៊ុនបានហាមការប្រព្រឹត្តចំពោះសកម្មភាពដែលល្មើសច្បាប់នោះទេ។[183]

[177] Roger LeRoy Miller & Gaylord A. Jentz, above n 27, 698.
[178] David F. Larcker, above n 129, 3-4.
[179] Roger LeRoy Miller & Gaylord A. Jentz, above n 27, 133.
[180] Ibid.
[181] ក្រមរដ្ឋប្បវេណី, មាត្រា ៧៤៨។
[182] ក្រមរដ្ឋប្បវេណី, មាត្រា ៧៤៨។
[183] ក្រមព្រហ្មទណ្ឌ, មាត្រា ៤២។

ផ្ទុយពីនេះ សកម្មភាពរបស់អភិបាលដែលប្រព្រឹត្តល្មើសនឹងសិទ្ធិ និងអំណាចដែលមានចែង នៅក្នុងច្បាប់ លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន នេះមានន័យថា អភិបាលបានប្រព្រឹត្ត លើសសិទ្ធិ និងអំណាចដែលបានផ្តល់ឲ្យ (act beyond its legal authority) សកម្មភាពនេះ ហៅថា Ultra Vires។[184] Ultra Vires នេះ គឺជាសកម្មភាពប្រព្រឹត្តដោយអភិបាល ឬ បុគ្គលិកផ្សេងទៀត ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន ប្រព្រឹត្តហួសសិទ្ធិ និងអំណាចស្របច្បាប់ សកម្មភាពនេះនាំឲ្យមានការ ទទួលខុសត្រូវជាច្រើនដូចជា (ក) ភាគហ៊ុនិកប្រហែលនឹងដាក់ពាក្យបណ្តឹងជំនួសមុខឲ្យក្រុមហ៊ុន ដើម្បីបញ្ឈប់សកម្មភាព Ultra Vires (ខ) រដ្ឋាភិបាលអាចនឹងបង្គាប់ឲ្យបញ្ឈប់សកម្មភាព ឬ ប្រសិនបើ សកម្មភាពជាអំពើដែលនាំឲ្យមានការប៉ះពាល់ខ្លាំងអាចបញ្ឈប់ដំណើរការរបស់ក្រុមហ៊ុន (គ) ប្រសិនបើអភិបាលជាអ្នកបញ្ជាឲ្យប្រព្រឹត្តសកម្មភាព Ultra Vires នេះ ក្រុមហ៊ុន ឬ តតិយជនអាច ទាមទារសំណងការខូចខាតពីអភិបាលដែលបញ្ជានោះបាន និង (ឃ) ជាទូទៅកិច្ចសន្យាដែលធ្វើ ឡើងដោយសកម្មភាព Ultra Vires គឺជាកិច្ចសន្យាដែលអាចអនុវត្តបាន ហើយភាគីពាក់ព័ន្ធមិនអាច លើកឡើងការពារខ្លួនថាកិច្ចសន្យាមិនអាចអនុវត្តបានដោយសារសកម្មភាព Ultra Vires នោះ ទេ។[185]

ឧទាហរណ៍ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន YXZ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន JKL ដែលជាក្រុមហ៊ុនប្រឹក្សាផ្នែកហិរញ្ញវត្ថុដើម្បីពិភាក្សាទាក់ទងនឹងការលក់មូលបត្រ។ ប៉ុន្តែ សកម្មភាព នេះបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនថា ត្រូវមានការយល់ព្រមឲ្យអនុវត្តដោយមតិភាគ ច្រើនពីភាគហ៊ុនិកទើបអាចប្រព្រឹត្តបាន ក្នុងករណីនេះក្រុមប្រឹក្សាភិបាលមិនបានធ្វើការស្នើសុំការ អនុម័តនោះទេ។ ចំពោះបញ្ហានេះតើមានព្រឹត្តិការណ៍អ្វីខ្លះដែលអាចកើតឡើង? ការចុះកិច្ចសន្យា ដែលអភិបាលបានធ្វើក្នុងករណីនេះ គឺច្បាស់លាស់ណាស់ថាត្រូវបានហាមឃាត់ដោយលក្ខន្តិកៈ របស់ក្រុមហ៊ុន ហើយសកម្មភាពនេះក៏បានប្រព្រឹត្តរួចហើយ ភាគហ៊ុនិកនឹងមិនទទួលបានផល ប្រយោជន៍អ្វីនោះទេ ប្រសិនបើភាគហ៊ុនិកសុំឲ្យតុលាការបញ្ជាឲ្យបញ្ឈប់នូវសកម្មភាពដែលកើត ឡើង។ ប៉ុន្តែ ចំពោះកិច្ចសន្យា Ultra Vires នេះអនុវត្តបាន ហើយដោយសារកិច្ចសន្យានេះជា ប្រតិបត្តិការឯកជន វាមិនមានការប៉ះពាល់ដល់ច្បាប់សន្តិសុខ ឬ បង្កអសន្តិសុខដល់សង្គមនោះទេ។ ដូចនេះអ្វីដែលក្រុមហ៊ុនអាចធ្វើបាននោះគឺ តម្រូវឲ្យអភិបាលទទួលខុសត្រូវផ្ទាល់ចំពោះសកម្មភាព ល្មើសនឹងសិទ្ធិ និងអំណាចនេះ ដូចជាការទទួលខុសត្រូវលើតម្លៃសេវា ឬ ការខូចខាតណាដែលកើត មានដោយសារការអនុវត្តកិច្ចសន្យានេះ។

[184] Roger LeRoy Miller & Gaylord A. Jentz, above n 27, 579.
[185] Ibid 580.

ការទទួលខុសត្រូវដោយក្រុមហ៊ុន នៅត្រង់ចំណុចនេះមិនមែនមានន័យថា អភិបាល ឬ បុគ្គលិកដែលប្រព្រឹត្តសកម្មភាពពុំមានការទទួលខុសត្រូវនោះទេ។ បើយោងតាមក្រមរដ្ឋប្បវេណី លើកឡើងថា ក្រុមហ៊ុនមានការទទួលខុសត្រូវចំពោះសកម្មភាពដែលប្រព្រឹត្តដោយបុគ្គលដែលមានឋានៈជាសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងផ្សេងទៀត ដែលបានប្រព្រឹត្តអំពើអនីត្យានុកូលទៅលើបុគ្គលដទៃដោយសារកំហុសចេតនា ឬ អចេតនានៅក្នុងវង្វង់នៃការអនុវត្តភារកិច្ច។ បញ្ញត្តិនោះក៏បានលើកឡើងផងដែរថា ទំហំនៃការខូចខាតប្រព្រឹត្តដោយអ្នកតំណាងនោះ នីតិបុគ្គល ឬ ក្រុមហ៊ុនអាចទាមទារមកវិញបាន។[186] មួយវិញទៀត នៅក្នុងក្រមនេះក៏មានចែងអំពីទំនាក់ទំនងនិយោជក ដែលនិយោជកនេះសំដៅលើបុគ្គលដែលប្រើនិយោជិតធ្វើកិច្ចការ ឬ ជាបុគ្គលដែលមានឋានៈជាអ្នកត្រួតពិនិត្យជំនួសនិយោជកផងដែរ ដែលបុគ្គលនេះត្រូវទទួលខុសត្រូវសងការខូចខាតចំពោះសកម្មភាពប្រព្រឹត្តដោយនិយោជិត ហើយអាចទាមទារមកវិញនូវសំណងដែលបានចេញតាមកម្រិតនៃកំហុស។[187]

ឧទាហរណ៍ ក្រុមហ៊ុន JT ជាក្រុមហ៊ុនផលិតសំលៀកបំពាក់កីឡា ក្រុមហ៊ុនបានទទួលការជូនដំណឹងអំពីការប្ដឹងអំពីការប្រព្រឹត្តល្មើស នឹងការរំលោភសេចក្ដីទុកចិត្តដែលប្រព្រឹត្តដោយបុគ្គលក្រុមហ៊ុនចំនួនបួននាក់។ បុគ្គលិកទាំងបួននេះបានព្យាយាមកំណត់តម្លៃជាក់លាក់មួយដែលមិនមានការប្រែប្រួល ហើយក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន JT នេះបានលើកឡើងថា មិនបានដឹង និង មិនបានអនុម័តលើការកំណត់តម្លៃដែលបានប្រព្រឹត្តដោយបុគ្គលិកនោះទេ ក្រុមប្រឹក្សាភិបាលក៏បានលើកឡើងទៀតថា ហេតុនេះទើបតម្រូវឲ្យបុគ្គលិកទាំងបួនមានការទទួលខុសត្រូវចំពោះសកម្មភាពបង្កឡើងដោយពួកគេ។ តើការលើកឡើងដោយអភិបាលនេះត្រឹមត្រូវឬទេ? អភិបាលមិនត្រឹមត្រូវទេ អ្វីដែលអភិបាលលើកឡើងថាមិនបានដឹងអំពីការកំណត់តម្លៃនោះ និងមិនបានអនុម័តនោះ មិនបានធ្វើឲ្យក្រុមហ៊ុនរួចផុតពីការទទួលខុសត្រូវពីលទ្ធផលដែលនាំឲ្យមានការខូចខាតដោយការប្ដឹងនេះទេ។ ប៉ុន្តែ អ្វីដែលក្រុមហ៊ុនត្រូវធ្វើនោះគឺ តម្រូវឲ្យបុគ្គលិកទាំង៤ ទទួលខុសត្រូវចំពោះក្រុមហ៊ុននូវសកម្មភាពដែលបានប្រព្រឹត្តនោះ ដោយចេញសងក្រុមហ៊ុនវិញ នូវចំនួនដែលក្រុមហ៊ុនបានធ្វើការសងចំពោះការប្រព្រឹត្តរបស់ពួកគេ។

[186] ក្រមរដ្ឋប្បវេណី, មាត្រា ៧៥៨។

[187] ក្រមរដ្ឋប្បវេណី, មាត្រា ៧៤៧។

## ១.២.កំហុសនៃការដឹកនាំ

កំហុសនៃការដឹកនាំនេះ គឺភាគច្រើនសំដៅទៅលើ កំហុសដែលកើតឡើងដោយការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាភិបាល រាល់ការសម្រេចលើមុខជំនួញទាំងអស់មិនមានការធានាថា នឹងមិននាំឲ្យមានការបាត់បង់ប្រយោជន៍ដល់ក្រុមហ៊ុននោះទេ។[188] ជាស្តង់ដារគោលការណ៍ដែលយកមកធ្វើការពិចារណាអំពីកំហុសនៃការដឹកនាំចំពោះ អភិបាលនោះ គឺអភិបាលត្រូវមានតួនាទីអនុវត្តការងារដោយយកចិត្តទុកដាក់ និងសុចរិតផងក្នុងការសម្រេចកិច្ចការជំនួញដែលអាចនាំឲ្យខាតបង់ ឬ បើមានការខាតបង់ដោយប្រការណាមួយ ប៉ុន្តែអភិបាលបានអនុវត្តដោយអស់ពីចិត្ត និងគោរពនូវតួនាទីផង។[189]

ច្បាប់សហគ្រាសពាណិជ្ជកម្ម ក៏បានចែងអំពីបញ្ញត្តិដែលនេះជាតួនាទីរបស់អភិបាលផងដែរ ដោយលើកឡើងថា អភិបាលត្រូវធ្វើសកម្មភាពប្រកបដោយភាពស្មោះត្រង់ក្នុង បំណងល្អ និងយកចិត្តទុកដាក់ ព្យាយាម និងជំនាញ[190] និងមានបញ្ញត្តិមួយទៀតលើកអំពីករណីការខាតបង់នោះ អភិបាលបានបំពេញដោយសុចរិត នោះក្រុមហ៊ុននឹងធ្វើការទទួលខុសត្រូវចំពោះការខាតបង់ ត្រង់កន្លែងនេះគឺ ដើម្បីទប់ស្កាត់នឹងការទាញយកផលប្រយោជន៍របស់ក្រុមហ៊ុនទៅជាផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អភិបាល។[191] ទន្ទឹមនឹងនេះ អភិបាលក៏ប្រកាន់ខ្ជាប់នឹងតួនាទីដែលមាន Duty of Care និង Duty of Loyalty នៅក្នុងការបំពេញតួនាទីជាអភិបាល ឬ បុគ្គលិកជាន់ខ្ពស់នៅក្នុងក្រុមហ៊ុន នៅពេលដែលអភិបាលបានល្មើសនឹងតួនាទីនេះនឹងនាំឲ្យមានកំហុសនៅក្នុងការដឹកនាំ។[192] ការធ្វេសប្រហែសរបស់អភិបាលនៅក្នុងការសម្រេចកិច្ចការក្រុមហ៊ុន និងក្នុងការបំពេញកាតព្វកិច្ចជាអភិបាលក៏នាំឲ្យមានការទទួលខុសត្រូវផ្ទាល់ដោយអភិបាលផងដែរ។

ឧទាហរណ៍ ក្រុមហ៊ុន GT Group ជាក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងសំណង់ខ្នាតធំៗ បានជូនដំណឹងអំពីការប្តឹងចំពោះក្រុមហ៊ុន ដោយហេតុថា បុគ្គលិកចំនួនពីរនាក់របស់ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ DC ដោយកែប្រែតម្លៃដើមដែលកិច្ចសន្យាទិញ លក់ពីកិច្ចសន្យាមុនដោយគ្មានការជូនដំណឹងពីក្រុមហ៊ុននោះទេ ដោយសារការឡើងថ្លៃនេះ ក្រុមហ៊ុន DC បានខាតបង់ព្រោះ DC បានចុះកិច្ចសន្យាជាមួយអតិថិជនរបស់ខ្លួន។ ក្នុងពាក្យបណ្តឹងក្រុមហ៊ុន GT Group មានរាយនាមអភិបាលរបស់ក្រុមហ៊ុនទាំងអស់នៅក្នុងពាក្យបណ្តឹងនេះដោយបានចោទថា ពួកគេគួរ

---

[188] Roger LeRoy Miller & Gaylord A. Jentz, above n 27.

[189] David F. Larcker, above n 129, 15.

[190] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៨៩។

[191] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៣។

[192] David F. Larcker, above n 129, 16.

បាន ចៀសវាងចំពោះការដំឡើងថ្លៃដែលប្រព្រឹត្តដោយបុគ្គលិកទាំងពីរនេះ និងចោទថាពួកគេមានការធ្វេសប្រហែសក្នុងការបង្ហាញពីការយកចិត្តទុកដាក់ក្នុងការដឹងអំពីការដំឡើងថ្លៃនេះ។ ចំពោះករណីបែបនេះ ក្រុមហ៊ុននៅតែទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់បុគ្គលិក ប៉ុន្តែ អភិបាលប្រហែលជាមិនទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តដោយបុគ្គលិកទេ។

ក្នុងការបង្ហាញអំពីធ្វេសប្រហែស លុះត្រាតែបង្ហាញថា អភិបាលមានមូលហេតុក្នុងការដឹងអំពីការដំឡើងថ្លៃនេះបានធ្វើដោយបុគ្គលិករបស់ខ្លួន។ មួយវិញនោះ ក្រុមហ៊ុននឹងមិនមានដំណើរការនោះទេ ប្រសិនបើអភិបាលត្រូវសង្ស័យចំពោះសកម្មភាពរបស់បុគ្គលិកទាំងអស់អំពីការប្រព្រឹត្តល្មើសច្បាប់ទាំងព្រហ្មទណ្ឌក្តី ឬ រដ្ឋប្បវេណីក្តី។ ការប្រព្រឹត្តរបស់អភិបាលចំពោះតួនាទីយកចិត្តទុកដាក់សមរម្យត្រូវបកស្រាយដោយតុលាការដើម្បីដឹងថា ចំនួនប៉ុណ្ណានៃការយកចិត្តទុកដាក់ដែលបុគ្គលមានមធ្យតែយល់ឃើញថាសមហេតុផលចំពោះសកម្មភាពដែលកើតឡើង។ ក្នុងករណីនេះ ប្រសិនអភិបាលមិនបានដឹង ឬ គ្មានមូលហេតុក្នុងការដឹងអំពីការដំឡើងថ្លៃ នោះតុលាការនឹងមិនតម្រូវឲ្យអភិបាលមានការទទួលខុសត្រូវផ្ទាល់ចំពោះការប្រព្រឹត្តរបស់បុគ្គលិកនោះទេ។

កំហុសនៃការដឹកនាំ គឺជាកំហុសមួយដែលអាចកើតឡើងដោយការធ្វេសប្រហែស ឬ ការប្រើឧបាយកលរបស់អភិបាល ចំពោះបញ្ហានេះទោះបីមានចេតនា ឬ អចេតនាក្តីក៏អភិបាលអាចនឹងត្រូវទទួលខុសត្រូវចំពោះកំហុសដែលកើតឡើង។[193] កំហុសនេះ អាចជាការបញ្ជាទិញក្នុងស្ថានភាពមិនត្រឹមត្រូវ ខ្វះការត្រួតពិនិត្យលើចរន្តសាច់ប្រាក់ ការមិនធ្វើរបាយការណ៍ច្បាស់លាស់ជូនដំណឹងចំពោះភាគហ៊ុនិកអំពីស្ថានភាពហិរញ្ញវត្ថុ និងការធ្វេសប្រហែសដែលធ្វើឲ្យក្រុមហ៊ុនខាតប្រយោជន៍។[194]

នៅពេលកំហុសនៃការដឹកនាំជាការសម្រេចរបស់អភិបាល ការទទួលខុសត្រូវមានតែនៅចំណុចដែលការសម្រេចនោះមិនមានមូលហេតុក្នុងការបង្ហាញ ឬ ពន្យល់ មិនតែប៉ុណ្ណោះ អភិបាលបរាជ័យក្នុងការលើកហេតុផលសមរម្យមកបង្ហាញចំពោះសកម្មភាពដែលប្រព្រឹត្ត ដូចជា ការអភិវឌ្ឍគម្រោងដែលអភិបាលដឹងថានឹងមិនអាចនាំឲ្យដំណើរការទទួលបានប្រាក់ចំណេញនោះ។[195] ការទទួលខុសត្រូវដែលកើតចេញពីកំហុសនៃការដឹកនាំនេះ មានពាក់ព័ន្ធគ្នាជាមួយនឹងតួនាទីរបស់អភិបាល ដូចជា Duty of Care, Duty of Loyalty និង Duty of Good Faith ដែលចំពោះ Duty of Good Faith ជាធម្មតាវាជាតួនាទីមួយដែលជាផ្នែកមួយនៅក្នុង Duty of Loyalty ប៉ុន្តែ ចំពោះការទទួលខុស

[193] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ២៨៩។
[194] Ibid.
[195] Carter G. Bishop, “A Good Faith Revival of Duty of Care Liability in Business Organization Law”, (Research Paper 07-02 Vol. 41, January 24, 2007), Suffolk University Law School, 488.

ត្រូវក្នុងកំហុសដែលកើតឡើងដោយការដឹកនាំរបស់អភិបាលមានតម្រូវឲ្យបង្ហាញថា អភិបាលបានប្រព្រឹត្តដោយស្មោះត្រង់ (Good Faith)។[196]

គោលការណ៍នៃ Duty of Good Faith គឺជាតួនាទីមួយដែលជាអញ្ញត្រកម្ម នៅក្នុងការទទួលខុសត្រូវរបស់អភិបាលដែលត្រូវបានចាត់ទុកថាជាបញ្ញត្តិ Exculpatory។[197] Duty of Care និង Business Judgement Rule បានលើកឡើងនៅក្នុងសហរដ្ឋអាមេរិច នៅក្នុងរឿងក្តី Graham v. Allis-Chalmers Manufacturing Co. នៅក្នុងរឿងនេះបានលើកឡើងថាអភិបាលបានធ្វេសប្រហែសក្នុងការដំឡើងប្រព័ន្ធឃ្លាំមើល ដើម្បីដោះស្រាយបញ្ហាហានិភ័យ ចំពោះបញ្ហាបុគ្គលិកចុះកិច្ចសន្យាកំណត់តម្លៃខុសច្បាប់ក្រុមហ៊ុន។[198] ប៉ុន្តែ តុលាការកំពូលនៃរដ្ឋ Delaware បានលើកឡើងថាអភិបាលមិនមានការសម្គាល់ពិតប្រាកដណាចំពោះសកម្មភាពដែលកើតឡើងនោះទេ ដូច្នេះអភិបាលមិនមានការទទួលខុសត្រូវនៅក្នុងបញ្ញត្តិ Duty of Care។[199] ប៉ុន្តែ ចំពោះករណីទាមទារថាអភិបាលមានការធ្វេសប្រហែសនោះ គឺមានពាក់ព័ន្ធនឹងគោលការណ៍នៃ Business Judgement Rule មានន័យថាការទទួលខុសត្រូវរបស់អភិបាលនឹងមិនមានទេបើមិនមានបង្ហាញអំពី Gross Negligence ។[200]

គោលការណ៍នៃ Business Judgement Rule នេះមានធាតុផ្សំ៣ទៀតគឺ នៅក្នុងការសន្មតមួយដែលការសម្រេចរបស់អភិបាលធ្វើតាមការជូនដំណឹងត្រឹមត្រូវទៅក្រុមប្រឹក្សាភិបាល, ដោយភាពស្មោះត្រង់ និងការជឿជាក់ថាសកម្មភាពនោះបានធ្វើនៅក្នុងផលប្រយោជន៍ខ្ពស់បំផុតរបស់ក្រុមហ៊ុន។[201] នៅក្នុង Business Judgment Rule គឺអនុវត្តទៅលើអភិបាលដែលមានផលប្រយោជន៍ពីសកម្មភាពពាណិជ្ជកម្ម ដែលហៅថា Self-Dealing ។[202] ចំពោះនិយមន័យនេះ Self-Dealing នេះមិនឃើញមាននិយមន័យនៅក្នុងច្បាប់នោះទេ ប៉ុន្តែវាមាននៅក្នុងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ Self-Dealing សំដៅទៅលើទង្វើដែលទាញយកប្រយោជន៍ពីមុខតំណែងរបស់ខ្លួននៅក្នុងប្រតិបត្តិការណាមួយ ដែលតំណែងនោះអាចជាក្រុមហ៊ុនដែលរក្សាទ្រព្យសម្បត្តិជំនួស អ្នកផ្តល់ប្រឹក្សាច្បាប់ បុគ្គលិករបស់ក្រុមហ៊ុន ឬបុគ្គលដែលពាក់ព័ន្ធនឹងកិច្ចសន្យា។[203]

[196] Ibid 492.
[197] Ibid 496.
[198] Ibid 485.
[199] Ibid.
[200] Ibid.
[201] David F. Larcker, above n 129, 15.
[202] Ibid.
[203] ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម, ប្រការ ៤(១០)។

រាល់ការល្មើសនឹង Fiduciary Duties គឺត្រូវមានការអនុវត្តដោយមានការចូលលូកដៃនៃតុលាការ ដូចជា Injunction គឺតុលាការចេញបញ្ជា ឬ ដីកាឲ្យក្រុមប្រឹក្សាភិបាលដើម្បីបញ្ឈប់សកម្មភាពណាជាក់លាក់មួយ និង Damages គឺតម្រូវឲ្យក្រុមប្រឹក្សាភិបាលចេញសងចំពោះការខូចខាត។[204] នៅក្នុង Business Judgement Rule តុលាការនឹងមិនធ្វើការជ្រៀតជ្រែកចូលការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនោះទេ បើ (១) ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវដំណាក់កាលមួយដែលសមហេតុសមផល (២) ក្រុមប្រឹក្សាភិបាលបានគិតពីអង្គហេតុពាក់ព័ន្ធទាំងឡាយ និង(៣) ក្រុមប្រឹក្សាភិបាលបានសម្រេចដោយស្មោះត្រង់ចំពោះក្រុមហ៊ុន។[205]

នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម ក៏បានលើកឡើងនូវចំណុចដែលអភិបាលត្រូវប្រកាន់យកតួនាទីមួយស្មោះត្រង់នឹងក្រុមហ៊ុន។ ច្បាប់នេះបានលើកឡើងថា ក្រុមហ៊ុនអាចចេញសងចំពោះអភិបាលរបស់ខ្លួនចំពោះដំណើរការនីតិវិធីច្បាប់ ដែលនាំឲ្យអភិបាលមានការទទួលខុសត្រូវក្នុងការបំពេញភារកិច្ច ប៉ុន្តែអភិបាលត្រូវធ្វើសកម្មភាពដោយស្មោះត្រង់ និងសមហេតុ សមផល។[206] ដើម្បីបង្ហាញពីភាពស្មោះត្រង់ និងសមហេតុសមផលរបស់អភិបាល អភិបាលត្រូវសំអាងឆន្ទៈល្អនៅលើកំណត់ហេតុ ឬ សៀវភៅបញ្ជី ដែលមានភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ឬ នៅលើពតិមានមតិយោបល់របាយការណ៍ផ្សេងៗ ឬ របាយការណ៍ដែលបង្ហាញដោយអ្នកគ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬ ជនណាម្នាក់ផ្សេងអំពីអភិបាលដែលបានធ្វើសកម្មភាពនោះ។[207] ចំពោះការចេញសងនេះក៏ត្រូវយកមកអនុវត្តផងដែរចំពោះអ្នកគ្រប់គ្រង អភិបាលពីមុន និងបច្ចុប្បន្ន ឬ បុគ្គលិកផ្សេងទៀតរបស់ក្រុមហ៊ុន។[208] ប៉ុន្តែការចេញសងដោយក្រុមហ៊ុននេះត្រូវកំណត់មកតែករណីដែលការចំណាយ ឬ ការខូចខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកនៅនៅពេលបម្រើការងារឲ្យក្រុមហ៊ុនប៉ុណ្ណោះ។[209]

[204] David F. Larcker, above n 129, 15.
[205] Ibid.
[206] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៣។
[207] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៣។
[208] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៣។
[209] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៣៣។

# ផ្នែកទី២៖ ការទទួលខុសត្រូវរដ្ឋប្បវេណី

ការទទួលខុសត្រូវរដ្ឋប្បវេណី គឺជាផ្នែកមួយដែលច្បាប់មានទំនាក់ទំនងទៅនឹងកិច្ចការនៅក្នុងនីតិបុគ្គល ការទទួលខុសត្រូវរដ្ឋប្បវេណីមួយសំខាន់ គឺជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលប្រព្រឹត្តដោយនាយក ឬ អ្នកតំណាងរបស់នីតិបុគ្គល។ ទំនាក់ទំនង២កើតឡើងគឺការទទួលខុសត្រូវរបស់និយោជក ឬ អ្នកត្រួតពិនិត្យជំនួសនិយោជក ចំពោះបុគ្គលិកនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន និងការទទួលខុសត្រូវដោយនីតិបុគ្គលចំពោះការប្រព្រឹត្តដោយសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងរបស់ក្រុមហ៊ុន។ បើមើលទៅលើទំនាក់ទំនងនៃការទទួលខុសត្រូវរបស់នីតិបុគ្គល វាមានរូបភាពដូចនឹងរចនាសម្ព័ន្ធរបស់នីតិបុគ្គល ពីព្រោះអភិបាលជាបុគ្គលដែលស្ថិតនៅក្នុងរូបភាពជាអ្នកតំណាង ឬ សមាជិកនៃគណៈកម្មការនាយក (ក្រុមប្រឹក្សាភិបាល) នេះអាស្រ័យទៅតាមការបកស្រាយរវាងទំនាក់ទំនងអភិបាល និងក្រុមហ៊ុន តើរូបភាពពេលណាដែលអភិបាលជាសមាជិកនៃរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ហើយក្នុងករណីណាដែលអភិបាលមានរូបភាពជាអ្នកតំណាង។ ប៉ុន្តែ ទោះអភិបាលស្ថិតនៅក្នុងឋានៈមួយណាក៏ដោយក៏ក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលបានប្រព្រឹត្តដែរ។ ចំពោះការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចំពោះអំពើអនីត្យានុកូល មានការងាយស្រួលក្នុងការបង្ហាញជាងការប្រព្រឹត្តល្មើសនឹងបទល្មើសព្រហ្មទណ្ឌធុរៈកិច្ចចំពោះលក្ខខ័ណ្ឌ និងការបញ្ជាក់អំពើអំពីអនីត្យានុកូល។ ចំពោះលក្ខខ័ណ្ឌដែលនាំឲ្យមានអំពើអនីត្យានុកូលនោះគឺ មានការបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ឬ បុគ្គលប្រព្រឹត្តមានករណីយកិច្ចបំពេញតួនាទី ទោះបុគ្គលបំពានមានចេតនា ឬ អចេតនាការទទួលខុសត្រូវនឹងកើតមានឡើង។ បន្ទុកនៃការបញ្ជាក់អំពីការខូចខាតកើតមានឡើង គឺជាភារកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញ។

នៅក្នុងការទទួលខុសត្រូវរដ្ឋប្បវេណីនេះ នឹងលើកអំពីការទទួលខុសត្រូវរបស់អភិបាលចំពោះច្បាប់ការងារ (២.១) ក្នុងទំហំនៃអំពើអនីត្យានុកូលដែលប្រព្រឹត្តដោយមានតួនាទីជាអ្នកត្រួតពិនិត្យចំពោះបុគ្គលិកដែលអភិបាលបានផ្ទេរសិទ្ធិឲ្យក្នុងការមើលខុសត្រូវ ឬ អំពើនោះប្រព្រឹត្តដោយអភិបាលផ្ទាល់។ មួយវិញទៀតនឹងលើកអំពើអនីត្យានុកូលចំពោះតួនាទីដែលអភិបាលមាន ប៉ុន្តែអភិបាលមិនបានប្រកាន់តួនាទីនាពេលអនុវត្តកាតព្វកិច្ច ដែលអំពើនោះជា ករណីដែលក្រុមហ៊ុនជិតនឹងក្ស័យធន (២.២)។

## ២.១.ការទទួលខុសត្រូវរបស់អភិបាលក្នុងនីតិការងារ

និយោជិតត្រូវទទួលបានអត្ថប្រយោជន៍ជាច្រើនពីក្រុមហ៊ុនដែលខ្លួនបម្រើការ ច្បាប់ការងារនៃប្រទេសកម្ពុជា បានតម្រូវឲ្យនិយោជករបស់ក្រុមហ៊ុនបំពេញនូវការធានានូវអត្ថប្រយោជន៍ដែលមិនបានកំណត់ច្បាស់លាស់។[210] ដូច្នេះ និយោជកអាចបំពេញតាមកាលៈទេសៈផ្សេងៗអាស្រ័យទៅតាមប្រភេទនៃក្រុមហ៊ុន។ ច្បាប់នេះក៏បានតម្រូវនិយោជកបង្កើតឲ្យមានបរិយាកាសនៃកន្លែងធ្វើការស្អាត និងមានស្តង់ដារទៅតាមលក្ខខណ្ឌនៃការងាររបស់និយោជិតផង។[211]

ច្បាប់ការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានចែងទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងដែលអាចជា អភិបាលក្រុមហ៊ុន ឬ បណ្ណាធិការ ឬ និយោជកនៅក្នុងក្រុមហ៊ុនទទួលខុសត្រូវក្នុងការល្មើសនឹងបទប្បញ្ញត្តិមួយចំនួនដែលមានចែងនៅក្នុងច្បាប់នេះ។[212] ចំពោះករណីការធានាដែលតម្រូវដោយច្បាប់ចំពោះអនាម័យ និងស្តង់ដារនៃលក្ខខណ្ឌការងាររបស់បុគ្គលិកតម្រូវឲ្យនិយោជករបស់ក្រុមហ៊ុនធានាឲ្យបាននូវ គុណភាពនៃទីកន្លែងធ្វើការ ការបោសសម្អាតបបនភ័ណ្ឌសុខាភិបាលដែលត្រូវមានសម្រាប់សេចក្តីត្រូវការរបស់បុគ្គលិក ភេសជ្ជៈ និងអាហារ ការស្នាក់នៅជាយថាហេតុរបស់បុគ្គលិក ប៉ុស្តិ៍ការងារ និងការរៀបចំអាសនៈធ្វើការ វិធានការសម្រាប់ធ្វើឲ្យខ្យល់ចេញចូលបានស្រួល និងការសម្អាតបរិយាកាសកន្លែងធ្វើការ ឧបករណ៍ការពារខ្លួន និងសំលៀកបំពាក់ការងារ ពន្លឺ និងសំលេងក្នុងកន្លែងធ្វើការ។[213] មិនតែប៉ុណ្ណោះច្បាប់ក៏បានតម្រូវផងដែរចំពោះសុវត្ថិភាពនៃការបំពេញការងាររបស់និយោជិត មានន័យថា ក្រុមហ៊ុនត្រូវការពារនូវរាល់ហានិភ័យទាំងឡាយដែលអាចកើតមានដោយសារគ្រោះថ្នាក់ការងារដូចជា ហានិភ័យនៃការជ្រុះធ្លាក់ ការប្តូរទីតាំងនៃវត្ថុធ្ងន់ៗ ហានិភ័យនៃអគ្គិភ័យជាដើម។[214] បញ្ញត្តិនេះត្រូវចែងលម្អិត ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយរាល់សកម្មភាពនៃការធានារបស់ក្រុមហ៊ុនត្រូវមានការឃ្លាំមើលដោយក្រសួងផងដែរ។[215]

ចំពោះការប្រព្រឹត្តដោយផ្ទាល់របស់បុគ្គលពាក់ព័ន្ធនឹងការអនុវត្តនូវបញ្ញត្តិនេះ មានដូចជានាយកក្រុមហ៊ុន ចាងហ្វាង បណ្ណាធិការ ឬ អ្នកទទួលអាណត្តិ ក្នុងកាលៈទេសៈណា អ្នកទាំងនេះ

---

[210] Sciaroni & Associates Law Firm, *Doing Business in Cambodia*, (Phnom Penh, 2015), 31, available at: http://www.sa-asia.com/home/upload/thumbnails/files/DBG%20Cambodia%202017_FINAL(1).pdf.

[211] Ibid.

[212] ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១ ១៣ មិនា ១៩៩៧ មាត្រា ៣៧៥ (ចាប់ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីការងារ)។

[213] ច្បាប់ស្តីពីការងារ មាត្រា ២២៩ និង ២៧៥។

[214] ច្បាប់ស្តីពីការងារ មាត្រា ២៣០។

[215] ច្បាប់ស្តីពីការងារ, មាត្រា ២២៩, ២៣០។

ប្រព្រឹត្តល្មើស គឺត្រូវទទួលខុសត្រូវរដ្ឋប្បវេណីជាប្រាក់ក្នុងការជួសជុលការខូចខាតជូនបុគ្គលិករងគ្រោះ។[216] ចំនួនទឹកប្រាក់ដែលត្រូវពិន័យ គឺចំនួនសាមសិប (៣០) ថ្ងៃ ដល់ មួយរយម្ភៃ (១២០) ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។[217] ក្នុងបញ្ញត្តិនេះ វាពិតជាពិបាកក្នុងការកំណត់ថាតើ អភិបាលត្រូវមានកាតព្វកិច្ចបែបណាខ្លះសម្រាប់ធានារក្សាអនាម័យ សន្តិសុខនៅក្នុងគ្រឹះស្ថាននោះ ព្រោះបញ្ញត្តិនេះមានលក្ខណៈទូលំទូលាយពេក។[218] បន្ថែមពីនេះ ទាមទារអោយគ្រឹះស្ថានទាំងអស់ត្រូវកំណត់អំពីគោលនយោបាយទាក់ទងនឹងបញ្ហាអនាម័យ និងសន្តិសុខ ដោយខ្លួនឯង និយាយជារួមធ្វើយ៉ាងណា ត្រូវរក្សាភាពស្អាត និងសុខសុវត្ថិភាពរបស់បុគ្គលិកឲ្យបានល្អ។[219] វិធានច្បាប់អនុវត្តក្នុងវិស័យនេះ ជាវិធានដែលចាត់ទុកថា សេចក្តីបង្គាប់ជាសាធារណៈ សម្រាប់ដាក់ឲ្យស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត បញ្ញត្តិនេះគ្មានបដិប្បញ្ញត្តិបានឡើយ មិនតែប៉ុណ្ណោះ វិធានអំពីសន្តិសុខសុវត្ថិភាព អនាម័យ និងហានិភ័យនៃការងារនេះត្រូវមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនផងដែរ។[220] ដើម្បីបកស្រាយនូវបញ្ញត្តិនេះឲ្យឃើញនូវភាពទាក់ទងគ្នារវាងការទទួលដែលអាចជានាយក ឬ អភិបាលនោះ ដំបូងត្រូវយល់ថានេះជាអំពើអនីត្យានុកូលដែលនិយោជក ឬ អ្នកគ្រប់គ្រងក្រុមហ៊ុនប្រព្រឹត្ត។

ធាតុផ្សំនៃអំពើអនីត្យានុកូលទូទៅមានលក្ខខណ្ឌ ៤ គឺ (១) មានអំពើបំពានដោយចេតនា ឬ អចេតនានូវសិទ្ធិ ឬ ផលប្រយោជន៍ (២) ភាពខុសច្បាប់នៃអំពើបំពានរបស់ចារី (៣) មានការខូចខាតដោយសារបំពានដល់សិទ្ធិ ឬ ផលប្រយោជន៍របស់ជនរងគ្រោះ និង(៤) ទំនាក់ទំនងរវាងហេតុ និងផលនៃការបំពានរបស់ចារី និងការខូចខាត។[221] នៅក្នុងក្រមរដ្ឋប្បវេណីការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់នីតិបុគ្គលចំពោះអំពើអនីត្យានុកូលបានប្រព្រឹត្តដោយសមាជិក គណៈកម្មាការនាយក ឬ អ្នកតំណាង ដែលលក្ខខណ្ឌនៃការល្មើសនេះគឺ បុគ្គលដែលជានាយក ឬ អ្នកតំណាងបញ្ហាដល់អ្នកដទៃ (១) ដោយខុសច្បាប់ ឬ កំហុសចេតនា ឬ អចេតនា (២) និងក្នុងពេលអនុវត្តភារកិច្ច (៣)។[222] ច្បាប់ការងារបានសង្កត់ធ្ងន់ចំពោះការប្រព្រឹត្តដោយផ្ទាល់ខ្លួនល្មើសនឹងបទប្បញ្ញត្តិក្នុងមាត្រា ២២៩ (បញ្ហាអនាម័យ) មាត្រា ២៣០ (សុវត្ថិភាពរបស់និយោជិត) និងមាត្រា ២៣០ (ការអនុវត្តប្រកាសរបស់ក្រសួង)។ ករណីនេះបញ្ជាក់ថា ប្រសិនបើ អភិបាលប្រព្រឹត្តផ្ទុយនឹងច្បាប់

[216] ច្បាប់ស្តីពីការងារ, មាត្រា ២៧៥។
[217] ច្បាប់ស្តីពីការងារ, មាត្រា ២៧៥។
[218] ហៃល ចំរើន, នីតិការងារ, (ហ្វូណន៖ ២០០៥), ១៥៥។
[219] Ibid.
[220] Ibid 150-151.
[221] ចក សម្បត្តិ, អំពើអនីត្យានុកូល, ការផ្សាយរបស់ក្រុមត្រាជូ, (សាលាត្រាជូ៖ មិនា ២០១៥), ៣។
[222] ក្រមរដ្ឋប្បវេណី, មាត្រា ៧៤៨។

ការងារ នេះ នាំឲ្យមានគ្រោះថ្នាក់ដល់បុគ្គលិកនោះ ហើយអភិបាលប្រឈមនឹងការទទួលខុសត្រូវដោយ ផ្ទាល់ស្របតាមច្បាប់ការងារ។

ឧទាហរណ៍ នៅក្នុងក្រុមហ៊ុនផលិតខោអាវកីឡាសម្រាប់នាំចេញទៅក្រៅប្រទេស Unique Sportwear ដែលមានអភិបាលបានអនុម័តនូវបទបញ្ជាផ្ទៃក្នុងសម្រាប់អនាម័យ និងហានិភ័យនៃគ្រោះថ្នាក់ការងារសម្រាប់ដាក់ឲ្យអភិបាលប្រតិបត្តិអនុវត្ត។ ក្នុងខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងនោះចែងថា ប្រសិនបើលក្ខខណ្ឌការងារបង្កឲ្យមានគ្រោះថ្នាក់ ឬ និយោជិតយល់ថាគ្មានសុវត្ថិភាព និយោជិតត្រូវរាយការណ៍មកអភិបាលប្រតិបត្តិ ដើម្បីឲ្យមានការបើកពិភាក្សាក្នុងការផ្អាកការងារនោះជាបណ្ដោះអាសន្ន។ កន្លះខែកន្លងទៅនេះ និយោជិតបានរាយការណ៍ថា កំណាត់មានក្លិនសារធាតុអ្វីម៉្យាងដែលអាចធ្វើឲ្យបុគ្គលិកកាត់ដេរនៅក្នុងរោងចក្រសន្លប់។ នាងឈ្មោះ កញ្ញា ជាបុគ្គលិកគ្រប់គ្រងឃ្លាំង ដែលបានចូលទៅក្នុងឃ្លាំងដើម្បីធ្វើរបាយការណ៍ចំនួនកំណាត់ត្រូវសន្លប់នៅក្នុងឃ្លាំង និងបញ្ជូនទៅមន្ទីពេទ្យដើម្បីសង្គ្រោះបន្ទាន់។ ព្រឹត្តិការណ៍នេះកើតឡើង នៅពេលបន្ទាប់ពីការជូនដំណឹងនេះ គ្មានការចាត់វិធានការណាមួយមកពីអភិបាល ឬ អភិបាលប្រតិបត្តិដើម្បីឲ្យត្រួតពិនិត្យចំពោះករណីនេះទេ ហើយក៏មិនមានការពិភាក្សាអ្វីជាបន្ទាន់នោះដែរ។ ប៉ុន្តែ ការចេញសេចក្ដីសម្រេចរួមមួយដោយអភិបាល និងអភិបាល ឬ អភិបាលប្រតិបត្តិថា កំណាត់មិនមានសារធាតុណាដែលបង្កឲ្យអសុវត្ថិភាពរបស់បុគ្គលិកនោះទេ ព្រោះកំណាត់បានពិនិត្យរួចហើយមុននឹងនាំចូលក្រុមហ៊ុន។ ខ្លឹមសារនៃសេចក្ដីសម្រេចនោះបានបង្គាប់ឲ្យបុគ្គលិកទាំងអស់ដំណើរការងាររបស់ខ្លួនតាមតួនាទីផងដែរ។ និយោជិតដែលរងគ្រោះថ្នាក់ ដោយសារការមិនយកចិត្តទុកដាក់របស់អ្នកគ្រប់គ្រង ហើយជនរងគ្រោះពីការបំពានបានដាក់ពាក្យបណ្ដឹងទៅតុលាការទាមទារសំណងការខូចខាត។

ដោយហេតុថា ករណីនេះជាវិវាទរវាងនិយោជិត និងនិយោជក ជាវិវាទបុគ្គលតាមច្បាប់ការងារជាច្បាប់ពិសេស មិនមែនក្រមរដ្ឋប្បវេណី ដូច្នេះសមត្ថកិច្ចរបស់តុលាការ គឺអាស្រ័យទៅតាមច្បាប់ពិសេសនេះ ត្រង់មាត្រា ៣៨៧ ចែងថា សមត្ថកិច្ចរបស់តុលាការការងារជាស្ថាប័នដែលមានសមត្ថកិច្ចចំពោះវិវាទបុគ្គល។[223] ប៉ុន្តែ ដោយហេតុថា តុលាការនេះពុំទាន់មាននាពេលនេះ វិវាទបុគ្គលនេះត្រូវបញ្ជូនមកដោះស្រាយដោយតុលាការនីតិរួម។[224] ប៉ុន្តែ ចំពោះវិវាទនេះត្រូវដាក់ទៅ

[223] ច្បាប់ស្ដីពីការងារ, មាត្រា ៣៨៧។
[224] ហ៊ែល ចំរើន, above n 175, 295.

អធិការកិច្ចការងារដើម្បីធ្វើការផ្សះផ្សាជាមុនសិន តែបើលទ្ធផលអវិជ្ជមាន នោះភាគីអាចប្តឹងទៅតុលាការបាន។[225]

បើយោងតាមឧទាហរណ៍អង្គហេតុ គឺកញ្ញាបានសន្លប់ដោយសារ គ្រោះថ្នាក់បង្កដោយការអនុវត្តការងារតាមការសម្រេចរបស់អភិបាល និងអ្នកគ្រប់គ្រង នៅក្នុងស្ថានភាពមួយគ្រោះថ្នាក់។ នាងបានពុលក្លិនពីកំណាត់ ហើយត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យជាច្រើនថ្ងៃ និងមិនអាចបំពេញការងារបានមួយរយៈ។ នាងបានប្តឹងទាមទារការខូចខាតដែលបង្កដោយការធ្វេសប្រហែសរបស់អភិបាល និងអ្នកគ្រប់គ្រងក្រុមហ៊ុនក្នុងការរក្សាសុវត្ថិភាពការងារដែលបង្កឲ្យកញ្ញាខូចខាតទាំងផលប្រយោជន៍ និងមានគ្រោះថ្នាក់ថែមទៀត។

យោងតាមអង្គច្បាប់ ច្បាប់ស្តីពីការងារ មាត្រា ៣៧៥ បានចែងថា ៖ នៅពេលដែលអភិបាលក្រុមហ៊ុន ឬ អ្នកទទួលអាណត្តិប្រព្រឹត្តដោយផ្ទាល់ល្មើសនឹងបទប្បញ្ញត្តិនៃ មាត្រា ២២៩ មាត្រា ២៣០ និងមាត្រា២៣១ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីសាមសិប (៣០)ថ្ងៃ ដល់មួយរយម្ភៃ (១២០)ថ្ងៃ នៃប្រាក់ប្រាក់ឈ្នួល។ ហើយមាត្រា ៣៧៦ នៃច្បាប់នេះក៏បានចែងបន្ថែមថា៖

> "ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីសាមសិបថ្ងៃទៅមួយរយម្ភៃថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃចំពោះជនណាដែលប្រព្រឹត្តបទល្មើស ដូចចែងក្នុងមាត្រាខាងលើបណ្តាលអោយ មានគ្រោះថ្នាក់ដល់សុខភាព ឬ សន្តិសុខអ្នកដទៃ។"

នៅក្នុងក្រមរដ្ឋប្បវេណី អំពើអនីត្យានុកូលប្រព្រឹត្តដោយសមាជិកគណៈកម្មាធិការនាយក ឬ អ្នកតំណាង គឺជាការបង្កដោយខុសច្បាប់ចំពោះអ្នកដទៃ ដោយកំហុសចេតនា ឬ អចេតនាក្នុងការបំពេញការងារ។ នីតិបុគ្គលត្រូវទទួលខុសត្រូវពីការចេញសងការខូចខាតដែលប្រព្រឹត្តដោយនាយក ឬ អ្នកតំណាង ហើយអាចទាមទារសំណងមកវិញចំពោះអំពើបង្កការខូចខាតនោះ។

យោងតាមអង្គហេតុ និងច្បាប់ អំពើដែលប្រព្រឹត្តដល់និយោជិតដោយខុសនឹងបទប្បញ្ញត្តិផ្ទៃក្នុងរបស់ក្រុមហ៊ុន និងល្មើសនឹងច្បាប់ស្តីពីការងារអំពីសុវត្ថិភាពរបស់បុគ្គលិកផង។ តាមការសំយោគបង្ហាញឲ្យឃើញថា តាមរយៈការសង្ស័យថា គ្មានសុវត្ថិភាពដោយសារមានក្លិនចម្លែកចេញពីកំណាត់ បុគ្គលិកបានរាយការណ៍អំពីព្រឹត្តិការណ៍នោះជូនអ្នកគ្រប់គ្រងដើម្បីដាក់ជូនឲ្យចាត់វិធានការជាបន្ទាន់ តែគ្មានការចាត់វិធានការអ្វីនោះទេ មានតែសេចក្តីឲ្យបញ្ចេញកំណាត់សម្រាប់យកទៅ

[225] ហៃ៉ល ចំរើន, above n 175, 292.

ដេរ ដោយលើកឡើងថា ក្រុមហ៊ុនបានត្រួតពិនិត្យរួចរាល់ហើយមុននឹងនាំកំណាត់ចូលឃ្លាំងរបស់ក្រុមហ៊ុន ព្រមទាំងបញ្ជាឲ្យដំណើរការការងារជាធម្មតា។ នៅក្នុងករណីនេះ អភិបាលមានតួនាទីជាបុគ្គលដែលអាចបញ្ចៀសគ្រោះថ្នាក់នេះបាន ប៉ុន្តែអភិបាលមិនបានបំពេញនូវតួនាទីរបស់ខ្លួនតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងករណីនេះអភិបាលបានប្រព្រឹត្ត និងសម្រេចឲ្យដំណើរការការងារដោយខុសច្បាប់ការងារផងដែរ។ ការទទួលខុសត្រូវរបស់អភិបាល គឺស្ថិតត្រង់ថា អ្នកគ្រប់គ្រងបានដាក់នូវរបាយការណ៍ជូនអភិបាលជាអ្នកសម្រេច ហើយការសម្រេចនេះស្ថិតនៅក្នុងរង្វង់នៃការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពីព្រោះបញ្ហាធំនេះ ការបញ្ឈប់ដំណើរការបណ្តោះអាសន្ននឹងធ្វើឲ្យប៉ះពាល់ដល់ការបញ្ជាទិញរបស់អតិថិជនរបស់ក្រុមហ៊ុន។ អភិបាលបានដឹងអំពើអំពើរបស់ខ្លួនថាខុសច្បាប់ និងអាចនាំឲ្យមានគ្រោះថ្នាក់ដល់បុគ្គលិកប្រសិនបើកំណាត់នោះពិតជាមានសារធាតុពុលពិតមែន។ បើយោងតាមក្រមរដ្ឋប្បវេណី ក្រុមហ៊ុនត្រូវចេញសងការខូចខាតជូនអភិបាលតាមទោសពិន័យដែលមានចែងនៅក្នុងច្បាប់ការងារ ហើយក្រុមហ៊ុនអាចទាមទារចំពោះសំណងនោះពីអភិបាលវិញ។ បើយោងតាមច្បាប់ស្តីពីការងារ អភិបាលត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដោយមានពិន័យចំពោះអំពើល្មើសជាប្រាក់ចំនួនពីសាមសិប (៣០)ថ្ងៃ ទៅមួយរយម្ភៃ (១២០)ថ្ងៃនៃប្រាក់ឈ្នួលប្រចាំថ្ងៃ និងពិន័យចំពោះការល្មើសនោះបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព ឬ សន្តិសុខអ្នកដទៃ។

ដូច្នេះ ក្រុមហ៊ុនត្រូវចេញសងការខូចខាត និងពិន័យចំពោះអំពើរបស់អភិបាលឲ្យ "កញ្ញា" ប៉ុន្តែ ក្រុមហ៊ុនអាចទាមទារមកវិញចំពោះសំណងនេះពីអភិបាលដែលបានប្រព្រឹត្ត។ សំណងតាមច្បាប់ការងារ គឺពិន័យចំពោះអំពើល្មើសចំនួនសាមសិប (៣០)ថ្ងៃ ទៅមួយរយម្ភៃថ្ងៃ (១២០) នៃប្រាក់ឈ្នួលប្រចាំថ្ងៃ បូកនឹងសំណងការខូចខាតជាប្រាក់ចំនួនសាមសិប (៣០)ថ្ងៃ ទៅមួយរយ (១០០) ថ្ងៃនៃប្រាក់ឈ្នួលប្រចាំថ្ងៃផងដែរ។

## ២.២.តួនាទីអភិបាលនៅក្នុងដំណាក់កាលធនក្ស័យក្រុមហ៊ុន

អភិបាលមាន Fiduciary Duty ចំពោះក្រុមហ៊ុនដែលត្រូវមានតួនាទី និងទំនួលខុសត្រូវច្រើន ហើយ Fiduciary Duity នេះមិនបញ្ចប់នោះទេនៅពេលដែលក្រុមហ៊ុនជួបនឹងបញ្ហា។[226] ទោះបីជាក្រុមហ៊ុនជួបនឹងបញ្ហាប្រឈមនឹងក្ស័យធនក៏អភិបាលមិនមាន Fiduciary Duty ចំពោះម្ចាស់បំណុលរបស់ក្រុមហ៊ុនដែរ។[227]

យោងតាមសាលដីកាតុលាការកំពូលដែលសម្រេចក្នុងរឿង Peoples Department Store Inc. (Trustee) v. Wise[228] តុលាការកំពូលនៃប្រទេសកាណាដា បានលើកឡើងថា អំពីតួនាទីរបស់អភិបាលនៅក្នុងច្បាប់កាណាដានៅពេលក្រុមហ៊ុនជិតនឹងក្ស័យធន។ នៅក្នុងបណ្តឹងនេះមានការទាមទារដោយអ្នកគ្រប់គ្រងក្រុមហ៊ុនក្ស័យធន (Trustee) ប្រឆាំងនឹងអភិបាលក្រុមហ៊ុនមុននៃក្រុមហ៊ុន។[229] អង្គហេតុនៅក្នុងរឿងនេះគឺ អភិបាលនៃក្រុមហ៊ុន Peoples Department Stores បានអនុវត្តគោលការណ៍មួយក្នុងការសហការរវាង Peoples Department Stores និង Wise Stores Inc. ក្នុងគោលបំណងផ្គត់ផ្គង់សំភារៈដើម្បីលក់នៅហាងទាំងពីរ។ នៅពេលដែលអនុវត្តគោលការណ៍នេះ Peoples បានផ្តល់កម្ចីឥវិកាទៅឲ្យ Wise នៅពេល Wise ក្ស័យធន People ក៏ត្រូវបានដាក់ក្នុងដំណាក់កាលមួយត្រូវក្ស័យធនដែរ។ ក្នុងការទាមទារដោយអ្នកគ្រប់គ្រងក្រុមហ៊ុនក្ស័យធន ឬអភិបាលបណ្តោះអាសន្ន (truestee) បានប្តឹងអតីតអភិបាលពីការល្មើសនឹងកាតព្វកិច្ចនៃ Fiduciary Duties ចំពោះម្ចាស់បំណុលនៃក្រុមហ៊ុន Peoples។ នៅតុលាការដំបូង ចៅក្រមបានទទួលស្គាល់ថាតុលាការរបស់ប្រទេសអង់គ្លេស អូស្ត្រាលី និងនូវែលហ្សេឡង់ ទាំងអស់បានលើកឡើងថា នៅពេលដែលក្រុមហ៊ុនជិតក្ស័យធន អភិបាលមានតួនាទីមិនត្រឹមតែចំពោះភាគហ៊ុនិកនោះទេ តែមានចំពោះម្ចាស់បំណុលរបស់ក្រុមហ៊ុនផងដែរ។ ប៉ុន្តែរឿងនេះត្រូវបានបណ្តឹងសាទុក្ខទៅ Quebec Court of Appeal តុលាការនេះបានបដិសេធចំពោះទស្សនៈលើកឡើងដោយតុលាការដំបូង។ តុលាការកំពូលបានយល់ស្របនឹងតុលាការឧទ្ធរណ៍ ហើយពន្យល់បញ្ជាក់អំពីបញ្ហា តើអភិបាលមាន Fiduciary Duties ចំពោះម្ចាស់បំណុលរបស់ក្រុមហ៊ុនដែរឬទេ។ ចំពោះបញ្ហានេះ តុលាការកំពូលលើកឡើងថា អភិបាលមាន Duty of Care ចំពោះម្ចាស់បំណុល ប៉ុន្តែតួនាទីនេះមិនលើកឡើងចំពោះ Fiduciary Duty ដែលអភិបាលមានចំពោះក្រុមហ៊ុននោះទេ។ តួនាទីដែលអភិបាលមាន

[226] Rajah & Tann, "Duties of Directors of Insolvent Companies And Companies In Liquidation", (Singapore, March 2001), 1, available at: https://eoasis.rajahtann.com/eoasis/lb/pdf/Duties-Of-Dirs-Insolvent-Co.pdf.
[227] Scott Bomhof, "Duties of Directors in the Insolvency Zone", *Corporate Governance Report*, (Vol. 5, No. 2, June 2010), 13, available at: https://www.torys.com/Publications/Documents/Publication%20PDFs/AR2010-24.pdf.
[228] Ibid 14-15.

ចំពោះក្រុមហ៊ុន តុលាការកំពូលបានលើកឡើងថាមានតួនាទីពីរគឺ Duty of Loyalty និង Duty of Care ដែលតម្រូវឲ្យអភិបាលធ្វើសកម្មភាពយ៉ាងទៀងត្រង់ និងដោយស្មោះត្រង់ដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន។ តុលាការកំពូលក៏លើកឡើងបន្ថែមទៀតដែរថា Duty of Loyalty របស់អភិបាលគ្រប់ពេល គឺជាកាតព្វកិច្ច Fiduciary មានចំពោះក្រុមហ៊ុន។ Duty of Loyalty នេះមិនយកមកអនុវត្តចំពោះភាគីផ្សេងទៀតនៅក្រៅក្រុមហ៊ុនឡើយ។ នៅក្នុងសាលដីកានេះក៏បានលើកឡើងដែរថា តុលាការគួរតែគោរពនូវសេចក្តីសម្រេចរបស់អភិបាលនៅក្នុងពាណិជ្ជកម្មនៅក្នុងក្រុមហ៊ុនក្នុងការពិនិត្យចំពោះសកម្មភាពនៃអភិបាល។ តុលាការបានបង្កើតវិធានមួយដែលថៅក្រម គឺជាជំនួយមិនសមស្របក្នុងការស្មាន ឬ លូកដៃចូលក្នុងការសម្រេចរបស់អភិបាលក្នុងការសម្រេច របស់ក្រុមហ៊ុន។ ថៅក្រមគួរតែផ្តោតសំខាន់ លើការពិនិត្យថា តើអភិបាលបានប្រើកម្រិតសមរម្យចំពោះគោលការណ៍មធ្យ័តភាព និងការខិតខំប្រឹងប្រែងដើម្បីអនុម័តកិច្ចការក្រុមហ៊ុនដែរឬទេ។

ជាការពិតណាស់ អភិបាលត្រូវតែច្បាស់លាស់ថា អភិបាលបានចូលទៅក្នុងព្រំដែនមួយថ្មីនៅក្នុងច្បាប់មួយថ្មី ក្នុងសកម្មភាពដើម្បីការពារក្រុមហ៊ុន អភិបាលគួរតែប្រាកដថាមិនដំណើរការក្រុមហ៊ុនដោយមិនមើលលើច្បាប់ថ្មីនោះទេ។[230] នៅពេលដែលក្រុមហ៊ុនជួបនឹងលក្ខខណ្ឌហិរញ្ញវត្ថុ អភិបាល គឺស្ថិតនៅក្រោមកាតព្វកិច្ចតាមច្បាប់ រួមទាំងការទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះបំណុលក្រុមហ៊ុនផងដែរ ប្រសិនបើក្រុមហ៊ុននៅតែបន្តសកម្មភាពពាណិជ្ជកម្មនៅពេលដែលក្ស័យធន។[231] ជាទូទៅ អភិបាលអាចនឹងទទួលខុសត្រូវចំពោះបំណុលរបស់ក្រុមហ៊ុនក្នុងពីរករណីគឺ ការទទួលខុសត្រូវចំពោះអំពើដែលអភិបាលមិនប្រុងប្រយ័ត្ន និង/ឬ ការធ្វើពាណិជ្ជកម្មដោយបោកប្រាស់។[232] ប្រសិនបើអំពើនោះ អភិបាល គឺជាភាគីនៃពាណិជ្ជកម្មដែលអភិបាលមានការយល់ដឹងចំពោះជំនាញ និងបទពិសោធន៍ពីមុន ដែលបង្កឲ្យបាត់បង់ប្រយោជន៍ដល់ម្ចាស់បំណុលនៃក្រុមហ៊ុន ឬ អ្នកផ្សេងទៀត។[233] មួយវិញទៀត នៅក្នុងករណីដែលអភិបាលជាភាគីនៃកិច្ចសន្យាបំណុលរបស់ក្រុមហ៊ុន និងគ្មានភាពស្មោះត្រង់ទៅលើមូលហេតុសមរម្យថា ក្រុមហ៊ុនអាចនឹងសងបំណុលបាននៅពេលក្រុមហ៊ុនក្ស័យធន។[234] ការទទួលខុសត្រូវនេះអាចជាការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ

[230] Ibid 15.

[231] Fergal McManus, “DIRECTORS DUTIES – INSOLVENT COMPANIES & WINDING UP”, (January 2011), 1, available at: https://www.morganmcmanus.com/wp-content/uploads/2015/09/Directors_Duties_Insolvent%20Companies.%20pdf.

[232] Ibid 2.

[233] Ibid.

[234] Ibid.

រដ្ឋប្បវេណីអាស្រ័យទៅលើភស្តុតាងរកឃើញ ប៉ុន្តែ ទំហំនៃការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អភិបាលគឺសងបំណុលក្រុមហ៊ុនចំពោះអំពើរបស់អភិបាលប្រព្រឹត្ត។[235]

## ផ្នែកទី៣៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អភិបាល

នៅពេលបុគ្គលម្នាក់មានតួនាទីជាអភិបាល ឬ បុគ្គលិកជាន់ខ្ពស់នៅក្នុងក្រុមហ៊ុន បុគ្គលទាំងនោះតែងតែមានទំនួលខុសត្រូវ ហើយទំនួលខុសត្រូវនេះមិនត្រឹមតែជាកិច្ចដំណើរការគ្រប់គ្រងក្រុមហ៊ុននោះទេ ប៉ុន្តែ ត្រូវធានាថាក្រុមហ៊ុនមិនបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិព្រហ្មទណ្ឌ ឬ អភិបាលធានាថាខ្លួនមិនបានយល់ព្រមក្នុងការផ្តល់ពត៌មាន ឬ ការណែនាំ ឬ ចូលរួមក្នុងការប្រព្រឹត្តផ្ទុយនឹង ច្បាប់។[236] ក្នុងនាមជាអភិបាលគឺ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តផ្ទុយច្បាប់ដោយផ្ទាល់ ឬ ដោយប្រយោល ដោយក្រុមហ៊ុនមិនរួមចំណែកក្នុងការទទួលខុសត្រូវចំពោះអំពើដែលអភិបាលបានប្រព្រឹត្តនោះទេ។[237] នៅក្នុងរឿងក្តីព្រហ្មទណ្ឌនេះ អភិបាលត្រូវចាត់ទុកថាទទួលខុសត្រូវព្រហ្មទណ្ឌគឺ នៅពេលដែលព្រះរាជអាជ្ញា ឬ ម្ចាស់បណ្តឹងអាជ្ញា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើអភិបាល ដែលក្នុងន័យនេះចង់សបញ្ជាក់ឲ្យឃើញថា ការទទួលខុសត្រូវរបស់អភិបាលមិនត្រូវបានសន្និដ្ឋានដោយស្វ័យប្រវត្តិថា បានប្រព្រឹត្តបទល្មើសជាមួយក្រុមហ៊ុនដែលអភិបាលគ្រប់គ្រងនោះទេ។[238] ប៉ុន្តែ អភិបាលនៅតែទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើរកឃើញថា អភិបាលបានណែនាំ ធ្វើសកម្មភាព ឬ យល់ព្រមធ្វើសកម្មភាព នៅក្នុងសកម្មភាពដែលធ្វើឲ្យមានការប្រព្រឹត្តបទល្មើសដោយក្រុមហ៊ុន។[239]

ច្បាប់សហគ្រាសពាណិជ្ជកម្មក៏បានលើកឡើងថា ការទទួលខុសត្រូវរបស់អភិបាល គឺជាការទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា។[240] តើចំណុចនេះសំខាន់ដែរឬទេសម្រាប់ការបញ្ជាក់ដោយអភិបាលនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចំពោះប្រទេសថៃពីមុនឆ្នាំ ២០១៧ ការទទួលខុសត្រូវរបស់អភិបាលគឺស្ថិតនៅពេលដែលក្រុមហ៊ុនប្រព្រឹត្តបទល្មើស មានន័យថានៅមុនឆ្នាំ ២០១៧

[235] Ibid.
[236] Napat Siri-armart & Athistha Chitranukroh, "New Law on Criminal Liabilities for Directors: Elimination of Strict Liability Presumption", *Tilleke & Gibbins International Ltd.*, (2017), avaible at: https://www.tilleke.com/resources/new-law-criminal-liabilities-directors-elimination-strict-liability-presumption.
[237] Ibid.
[238] ក្រមនីតិនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ០៨ មិថុនា ២០១៣, មាត្រា២ (ចាប់ពីពេលនេះតទៅហៅថា ក្រមនីតិវិធីព្រហ្មទណ្ឌ)។
[239] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ២៧ កុម្ភៈ ២០១៨, មាត្រា ២៨, ២៩ (ចាប់ពីពេលនេះតទៅហៅថា ក្រមព្រហ្មទណ្ឌ)។
[240] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ១៤០។

ប្រទេសថៃប្រើគោលការណ៍ Strict Liability Presumption ។[241] នៅក្នុងការអនុវត្តគោលការណ៍នេះ គឺអភិបាលត្រូវបានចាត់ទុកថាជាប់ចោទ នៅក្នុងរឿងក្តីព្រហ្មទណ្ឌជាមួយក្រុមហ៊ុនដោយស្វ័យប្រវត្តិ ហើយអភិបាលមានបន្ទុកក្នុងការរកភស្តុតាងដោះបន្ទុកខ្លួនឯងចំពោះការចោទនេះ។[242] នៅឆ្នាំ ២០១៧ ថ្ងៃទី១២ កន្លងមកនេះគោលការណ៍នេះមិនត្រូវបានប្រើទៀតនោះទេ ដោយតុលាការធម្មនុញ្ញភាពរបស់ប្រទេសថៃរកឃើញថា បញ្ញត្តិនេះផ្ទុយនឹងធម្មនុញ្ញភាពរបស់ប្រទេសថៃ។[243]

ចំពោះប្រទេសកម្ពុជា នៅក្នុងបរិបទរឿងក្តីព្រហ្មទណ្ឌមិនមានប្រើនូវគោលការណ៍នេះទេ ព្រោះក្រមព្រហ្មទណ្ឌបានលើកឡើងថា បុគ្គលម្នាក់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែតុលាការរកឃើញថាបានប្រព្រឹត្តបទល្មើស ឬ បានប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬ សមគំនិតក្នុងការប្រព្រឹត្តបទល្មើស ដោយបំពេញនូវធាតុផ្សំចំនួនបីគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំអត្តនោម័ត និង ធាតុផ្សំសត្យានុម័ត។[244] មុននឹងធ្វើការបកស្រាយនូវបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយអភិបាល ដំបូងគប្បីត្រូវយល់អំពីអត្ថន័យខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌប្រព្រឹត្តដោយនីតិបុគ្គល និងបទល្មើសព្រហ្មទណ្ឌប្រព្រឹត្តដោយអភិបាលរបស់នីតិបុគ្គល។

យោងតាមក្រមព្រហ្មទណ្ឌ គ្រប់នីតិបុគ្គលទាំងអស់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ លើកលែងតែរដ្ឋចេញ នីតិបុគ្គលត្រូវទទួលខុសត្រូវគ្រប់បទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន។[245] ប៉ុន្តែ ការទទួលខុសត្រូវនេះមិនត្រូវបានលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។[246] ចំពោះច្បាប់សហគ្រាសពាណិជ្ជកម្ម ដែលត្រូវបានចាត់ទុកថាជាច្បាប់ពិសេស បានចែងថា៖[247]

> "នៅពេលដែលក្រុមហ៊ុនប្រព្រឹត្តបទល្មើស អភិបាល ឬ បុគ្គលិករបស់ក្រុមហ៊ុន ណា ដែល បានប្រគល់សិទ្ធិឲ្យប្រព្រឹត្តបទល្មើស ឬ អនុញ្ញាត ឬ បានយល់ព្រម ឲ្យប្រព្រឹត្តបទល្មើស ជា អ្នកទទួលខុសត្រូវមួយនៃបទល្មើសនោះ។"

នៅត្រង់នេះមានន័យថា បុគ្គលដែលជាអភិបាលអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែលប្រព្រឹត្តដោយក្រុមហ៊ុនរបស់ខ្លួន នៅពេលណាដែលខ្លួនជាបុគ្គលដែលមានតំណែង អភិបាល ឬ

[241] Napat Siri-armart & Athistha Chitranukroh, above n 203.
[242] Ibid.
[243] Ibid
[244] ហ៊ី សោភា, *នីតិព្រហ្មទណ្ឌ*, ៣៦,៣៧។
[245] ក្រមព្រហ្មទណ្ឌ, មាត្រា ៤២។
[246] ក្រមព្រហ្មទណ្ឌ, មាត្រា ៤២។
[247] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ២៩១។

បុគ្គលិកដែលបានប្រគល់សិទ្ធិ ឬ អនុញ្ញាត ឬ យល់ព្រមឲ្យបុគ្គលនៅក្រោមអំណាចប្រព្រឹត្តបទល្មើស ឬ ប្រព្រឹត្តដោយផ្ទាល់។

បញ្ជាក់ផងដែរ ការទទួលខុសត្រូវរបស់នីតិបុគ្គល និងការទទួលខុសត្រូវរបស់អភិបាលគឺជាការទទួលខុសត្រូវពីរផ្សេងពីគ្នា នៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយប្រព្រឹត្តដោយក្រុមហ៊ុន។ លទ្ធផលនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនអាចត្រូវបានពិន័យ ឬ/និង រំលាយក្រុមហ៊ុនចោល ផ្អាកដំណើរការក្រុមហ៊ុន ក៏អាចជាទណ្ឌកម្មផ្សេងទៀត។[248] ប៉ុន្តែអភិបាលអាចត្រូវបានផ្តន្ទាទោសដោយពិន័យ និងជាប់ពន្ធនាគារ។ អត្ថបទនេះនឹងសិក្សាលើបទល្មើសរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត(៣.១) និងបទស៊ីសំណូករបស់អភិបាល ជាអាទិ៍ (៣.២)។

## ៣.១.បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត

បទប្បញ្ញត្តិនៃបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាលនេះ មានសារសំខាន់ណាស់ក្នុងការកំណត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌដោយបុគ្គលម្នាក់ៗដាច់ចេញពីក្រុមហ៊ុន មានន័យថាស្ទើរតែគ្រប់ករណីដែលបញ្ញត្តិនេះ អនុវត្តទៅលើអ្នកដែលធ្វើសកម្មភាពក្នុងនាមអ្នកដទៃ។[249] នៅក្នុងករណីនេះ អភិបាលអាចត្រូវបានចោទប្រកាន់ថារំលោភលើទំនុកចិត្តពិសេស នៅពេលដែលអភិបាលបានល្មើសនឹងតួនាទីក្នុងការលើកកម្ពស់ឲ្យក្រុមហ៊ុនទទួលបានជោគជ័យ ឬ តួនាទីផ្សេងទៀតដែលច្បាប់បានចែង។[250] នៅប្រទេសអាឡឺម៉ង់ បទល្មើសនេះមានការបំពានច្រើនរបៀប អាចជា ការល្មើសនឹងអំណាច និងការរំលោភលើទំនុកចិត្តដែលធ្វើឲ្យបាត់បង់នូវហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។[251] នៅក្នុងចំណុចទីមួយ អ្នកប្រព្រឹត្តបទល្មើសបានធ្វើសកម្មភាព ultra vires និងចំណុចសំខាន់មួយទៀតនោះគឺ អភិបាលបានល្មើសនឹងតួនាទីការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងល្មើសនឹងឋានៈជាអភិបាលរបស់ខ្លួន។[252] បើផ្អែកលើនិយមន័យនៃបទរំលោភលើទំនុកចិត្ត ដែលពន្យល់នៅក្នុងក្រមព្រហ្មទណ្ឌរបស់កម្ពុជា លើកឡើងថា៖[253]

[248] ក្រមព្រហ្មទណ្ឌ, មាត្រា ៤២។
[249] MANEUL LADIEGES, above n 168, 100.
[250] Ibid.
[251] Ibid 101.
[252] Ibid.
[253] ក្រមព្រហ្មទណ្ឌ, មាត្រា ៣៩៣។

"អំពើរំលោភលើទំនុកចិត្ត គឺជាអំពើតែបំបាត់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ នាំអោយខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលគេបានប្រគល់អោយបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចសងវិញ បង្ហាញ ឬ យកមូលនិធិតម្លៃ ឬ ទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។"

ក្រមនេះក៏បានកំណត់ជាក់លាក់ផងដែរ ចំពោះបទរំលោភលើទំនុកចិត្តដោយអភិបាល ដោយលើកឡើងថា ជាការរំលោភទំនុកចិត្តក្នុងគោលបំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬ គោលបំណងធ្វើឲ្យខូចខាតដល់នីតិបុគ្គល ហើយដោយសារអំពើនេះនីតិបុគ្គលមានការខូចខាតទ្រព្យសម្បត្តិ។

មួយវិញទៀត ប្រភេទនៃបទល្មើសនេះ វាទាក់ទងនឹងក្រុមហ៊ុនមូលធន ដែលចារីអាចជាអភិបាល ឬ អ្នកត្រួតពិនិត្យរបស់នីតិបុគ្គល ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឲ្យធ្វើជំនួស ឬ និយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ហើយនៅក្នុងបញ្ហាដែលកើតនៅក្នុងបទល្មើសនេះ មានដូចជា ការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ឬ អំណាចរបស់ខ្លួនដែលក្រុមហ៊ុនបានប្រគល់ឲ្យតាមរយៈច្បាប់ ឬ លក្ខន្តិកៈ ក្នុងការទាញផលប្រយោជន៍ដើម្បីខ្លួនឯង ឬ សម្រាប់តតិយជន និងការប្រព្រឹត្តអំពើទុច្ចរិតដែលធ្វើអោយខាតបង់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬ មូលនិធិរបស់ក្រុមហ៊ុន។[254] បើយោងតាមអត្ថន័យនៃច្បាប់សហគ្រាសពាណិជ្ជកម្មដែលបានលើកឡើងមុននេះ អភិបាលមិនចាំបាច់ទាល់តែប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្តនេះដោយខ្លួនឯងនោះទេ អភិបាលក៏អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ចំពោះបុគ្គលិកដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន មានន័យថា អភិបាលបានយល់ព្រមឲ្យប្រព្រឹត្ត ឬ ណែនាំដល់បុគ្គលដែលប្រព្រឹត្ត។ សរុបមក នៅក្នុងឋានៈជាអភិបាលក្រុមហ៊ុនការទទួលខុសត្រូវមានច្រើន ដូចនៅក្នុងរឿងព្រហ្មទណ្ឌនេះ អភិបាលអាចត្រូវទទួលខុសត្រូវដោយការប្រព្រឹត្ត ចំពោះអំពើរបស់ខ្លួនដែលរំលោភលើទំនុកចិត្ត ហើយអភិបាលក៏អាចត្រូវបានចោទប្រកាន់ចំពោះបទល្មើសនេះផងដែរនៅពេលដែលមានភស្តុតាងបញ្ជាក់ថា អភិបាលជាប្រភពនៃការប្រព្រឹត្តបទល្មើសនេះ គឺនៅពេលដែលអភិបាលបានយល់ព្រម ឬ ណែនាំឲ្យមានការប្រព្រឹត្តបទល្មើស ដែលនាំឲ្យខូចខាតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

ចំពោះករណីនេះ វាហាក់បីដូចជាការទទួលខុសត្រូវ ដែលធ្លាប់បានកើតឡើងនៅក្នុងរឿងក្តី R. v. H.M. Coroner for East Kent ដែលនេះជាករណីដែលឧបទ្ទវហេតុ Zeebrugge ferry ដោយសារ Herald of Free Enterprise បានដាក់ Zeebrugge ferry ទៅក្នុងសមុទ្រជាមួយទ្វារខាង

[254] *នីតិព្រហ្មទណ្ឌធុរកិច្ច*, បទល្មើស៖ ការរំលោភលើសេចក្តីទុកចិត្ត។

ឆ្វេង (bow doors) បើកចំហ បណ្តាលឲ្យមានមនុស្ស ២០០នាក់ស្លាប់។[255] ករណីនេះ គឺជាករណីធ្វេសប្រហែសនៅថ្នាក់ក្រោមដែលភ្លេចពិនិត្យថា តើ bow doors បានបិទហើយឬនៅ។ នៅក្នុងករណីនេះ គោលការណ៍នៃ "Directing Mind" ត្រូវយកមកអនុវត្ត ដែលជាទូទៅគោលការណ៍នេះនឹងផ្តាច់ការទទួលខុសត្រូវរវាងការទទួលខុសត្រូវរបស់ក្រុមហ៊ុន (Absolute Liability ឬ Respondeat Superior ឬ Vicarious Liability) និងការទទួលខុសត្រូវរបស់បុគ្គលដែលប្រព្រឹត្តអំពើ ហើយអំពើនោះកំណត់ដោយច្បាប់ទោះបីបុគ្គលដែលប្រព្រឹត្តនោះមិនបានធ្វេសប្រហែសក៏ដោយ (Strict Liability)។ ទោះជាយ៉ាងណា Absolute Liability គឺជាផ្នែកមួយនៃការទទួលខុសត្រូវនៅក្នុងការទទួលខុសត្រូវរបស់ Strict Liability។ ត្រលប់មកករណី R. v. H.M. Coroner for East Kent ក្រុមប្រឹក្សាភិបាលមិនទទួលខុសត្រូវចំពោះឧបទ្ទវហេតុនេះទេ ព្រោះករណីនេះមិនមានក្រុមប្រឹក្សាភិបាលទេ ដែលជាអ្នកប្រើនូវគំនិតរបស់ខ្លួន។ ក្នុងករណីនេះ តុលាការបានលើកឡើងថា ភស្តុតាងមិនគ្រប់គ្រាន់សម្រាប់ឲ្យក្រុមហ៊ុនទទួលខុសត្រូវ ឬ បុគ្គលណាម្នាក់ក្នុងការទទួលខុសត្រូវចំពោះអំពើដែលកើតនៅថ្នាក់ក្រោមនោះទេ។

ឧទាហរណ៍៖[256] លោក ចិន្តា ដែលមានតួនាទីជាអគ្គនាយករងនៃក្រុមហ៊ុន TM world Co, Ltd បានលួចបន្លំ និងកែបំបាត់ប្រាក់របស់ក្រុមហ៊ុនចំនួន ២០លានដុល្លាអាមេរិកដើម្បីយកទៅចាត់ចែងសាងសង់ផ្សារទំនើបមួយ និងបានបញ្ចូលទៅក្នុងគណនីដែលមានឈ្មោះ ចិន្តា និងសុភាព ដោយមិនប្រក្រតី។ បន្ទាប់មកលោក ហុង យុ ដែលជាអគ្គនាយកក្រុមហ៊ុន មានការសង្ស័យទើបឲ្យលោក ចិន្តា យកបញ្ជីប្រតិបត្តិការរបស់ក្រុមហ៊ុន និងស្នើសុំដកប្រាក់ ៥លានដុល្លារអាមេរិក។ លោក ចិន្តា មិនបានយកបញ្ជីមកអោយលោក ហុង យុ ត្រួតពិនិត្យនោះទេ ហើយថែមទាំងគ្មានទឹកប្រាក់ដែលបានស្នើសុំនោះនៅក្នុងគណនីទេ។ ក្រោយមួយសប្តាហ៍មក លោក ចិន្តា បានសារភាពថា ខ្លួនពិតជាបានយកប្រាក់ចំនួន ២០ លានដុល្លារអាមេរិកដើម្បីប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន។

ចំណែកទឹកប្រាក់ ១០លាន ទៀត លោក ហុង យុ បានឲ្យខ្លួនដកដើម្បីចំណាយលើការទិញផ្ទះ ដែលមានតម្លៃ ១លានដុល្លារអាមេរិក ថ្លៃទិញដីចំនួន ២ដង តម្លៃ ៩ លានដុល្លារអាមេរិក ដែលលុយដែលបានដកទាំងនោះមិនបានចុះបញ្ជីក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុនទេ។ លោក ចិន្តា បានវេលុយត្រលប់មកក្រុមហ៊ុនវិញចំនួន ១០ លានដុល្លារអាមេរិក និងបានសន្យាសងប្រាក់ចំនួន ១០ លានដុល្លារអាមេរិក ទៅលោក ហុង យុ ក្នុងរយៈពេល ២ឆ្នាំ ជា៤ដំណាក់កាល។

[255] Matsiko Godwin Muhwezi, "THE CASE FOR CRIMINAL LIABILITY", *ResearchGate*, (May 2016), 15, available at: https://www.researchgate.net/publication/309041784.

[256] ក្រុមមេធាវី សំរិទ្ធ(SLG), វិភាគសាលក្រមព្រហ្មទណ្ឌ៖បទរំលោភលើសេចក្តីទុកចិត្ត (សីហា ២០១៤)។

នៅក្នុងករណីសិក្សាឧទាហរណ៍ខាងលើនេះ ក្រុមហ៊ុន TM world Co, Ltd ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (ក្រុមហ៊ុនមូលធន) ដែលមានលោក ចិន្តា មានតួនាទី ជាអគ្គនាយករង (អភិបាល) លោក ចិន្តា បានសារភាពថា គាត់បានប្រើប្រាស់លុយចំនួន ២០ លានដុល្លារអាមេរិក ក្នុងការប្រើប្រាស់ដើម្បីជាប្រយោជន៍របស់ខ្លួន ដែលជាការប្រើប្រាស់ផ្ទុយនឹងប្រយោជន៍របស់ក្រុមហ៊ុន ដែលគ្មានការអនុញ្ញាតពីក្រុមហ៊ុនទៀត ជាទង្វើមួយដែលប៉ះពាល់ដល់ទំនុកចិត្ត និងអាចធ្វើអោយក្រុមហ៊ុនទទួលរងនូវការខូចខាតក្នុងប្រការណាមួយ ឬជាចេតនាទុច្ចរិតរបស់អភិបាល ដោយដឹងថា ការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ នឹងធ្វើអោយប៉ះដល់ផលប្រយោជន៍របស់ក្រុមហ៊ុន។

បើផ្អែកទៅលើការវិភាគសាលក្រមរឿងនេះត្រូវបានប្តឹងសាទុក្ខដល់តុលាការកំពូល ហើយតុលាការកំពូលបានទទួលបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមច្បាប់ និងគតិច្បាប់ ហើយបានបដិសេធដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទាំងមូល និងបង្វិលសំណុំរឿងព្រហ្មទណ្ឌនេះទៅអោយសាលាឧទ្ធរណ៍ជម្រះសារជាថ្មី ចំពោះអត្ថិភាព ឬនត្ថិភាពដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ចិន្តា និងសម្រេចអោយ សុភាព រួចផុតពីចោទប្រកាន់។ នៅក្នុងវិភាគសាលក្រមនេះ ការចោទប្រកាទពុំមានភាពច្បាស់លាស់ដោយមានភស្តុតាងរបស់ភាគីដើមបណ្តឹងតែម្ខាង មិនគោរពគោលការណ៍ចំពោះមុខ, គ្មានការពិនិត្យភស្តុតាងជនជាប់ចោទបានស្នើសុំ និងមួយទៀត ការចោទលើ សុភាព ធ្វើឡើងដោយការសន្មត់ដោយយកតាមទំនាក់ទំនងប្តីនិងប្រពន្ធ កាលណាព្រះរាជអាជ្ញាធ្វើរបៀបនេះ គឺមិនត្រឹមត្រូវទេ ព្រោះថាការចោទប្រកាន់ទៅជនជាប់ចោទ ត្រូវមានភស្តុតាងដើម្បីធ្វើការចោទ។

ក្នុងការណ៍នេះ លោក ចិន្តា នឹងអាចត្រូវចោទពី បទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬ បុគ្គលផ្សេងទៀត តាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ បើមានភស្តុតាងបញ្ជាក់ច្បាស់ថា គាត់បានប្រើប្រាស់ជាប្រយោជន៍របស់គាត់មែន។ ចំនែកឯប្រពន្ធរបស់គាត់ លោកស្រី សុភាព អាចត្រូវរួចផុតពីការចោទប្រកាន់បាន លុះត្រាតែគាត់មានភស្តុតាង ឬសក្ខីកម្មណាមួយដែលបញ្ជាក់ថា គាត់មិនបានចូលរួមក្នុងសកម្មភាពបែបនេះជាមួយប្តីរបស់គាត់ទេ។

## ៣.២.បទស៊ីសំណូករបស់អភិបាលជាអាទិ៍

អភិបាលក្រុមហ៊ុន គឺជាបុគ្គលមួយដែលអនុវត្តសកម្មភាពរបស់ខ្លួនតាមកាតព្វកិច្ចដែលមានចែងដោយច្បាប់ លក្ខន្តិកៈរបស់ក្រុមហ៊ុន បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខសន្យារក្សាការសម្ងាត់ក្រុមហ៊ុន និងមានតួនាទីគោរពច្បាប់ ក៏ធានាប្រាកដថាក្រុមហ៊ុនរបស់ខ្លួនបានគោរពច្បាប់។ នៅក្នុងករណីបទស៊ីសំណូករបស់អភិបាលនេះគឺជា បទល្មើសមួយដែលអភិបាលត្រូវធ្វើសកម្មភាពល្មើសនឹងច្បាប់ តួនាទី ឬ ខសម្ងាត់របស់ក្រុមហ៊ុនដើម្បីទទួលបានផលប្រយោជន៍របស់ខ្លួន។ បទល្មើសនេះគឺសំដៅទៅលើចារីជា អភិបាល អ្នកត្រួតពិនិត្យ ឬ និយោជិតរបស់ក្រុមហ៊ុន ។ល។ ទំនាក់ទំនងនៃបទល្មើសនេះ មានលក្ខណៈខុសគ្នាពីបទសូកប៉ាន់ ដែលបទសូកប៉ាន់គឺសំដៅទៅលើបុគ្គលឯកជន អាចជាបុគ្គលិករបស់នីតិបុគ្គល ធ្វើសកម្មភាពសូកប៉ាន់មន្ត្រីសាធារណៈដើម្បីទទួលជោគជ័យនៅក្នុងពាណិជ្ជកម្ម ហើយក៏ដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន។ បទល្មើសសូកប៉ាន់នេះការទទួលខុសត្រូវនៃបទប្រព្រឹត្តខុសពីបទស៊ីសំណូករបស់អភិបាល។ បទស៊ីសំណូករបស់អភិបាលលើកឡើងដោយក្រមព្រហ្មទណ្ឌថា៖[257]

> "បើបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រា ៣៩៣ (បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត) នៃក្រមនេះ ឬអធិការបានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬបានទាមទារ ឬបានសន្យាទទួលផលប្រយោជន៍នោះ ដោយបានទទួលការពឹងពាក់ខុសច្បាប់..."។

នៅក្នុងមាត្រានេះចង់បង្ហាញ ការប្រព្រឹត្តរបស់ចារីជាអភិបាល ឬ អ្នកត្រួតពិនិត្យរបស់នីតិបុគ្គលដែលបានកំណត់នៅក្នុងមាត្រា ៣៩៣ នៃកថាខណ្ឌទី១ និងទី២ ជាប្រភេទអំពើពុករលួយនៅក្រុមហ៊ុនមូលធន (ផ្នែកឯកជន) ហើយនៅក្នុងនេះ ក៏បានបញ្ជាក់ពីចេតនាទុច្ចរិតរបស់អភិបាលក្នុងធ្វើសកម្មភាពផ្ទុយនឹងសកម្មភាព ឬ ខសម្ងាត់របស់ក្រុមហ៊ុន និងបានទទួលផលប្រយោជន៍ពីបុគ្គលដែលបានផ្តល់អោយនោះ នោះបុគ្គលដែលបានទទួល និងបុគ្គលដែលបានផ្តល់នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ មួយវិញទៀត ផលប្រយោជន៍ដែលជាកម្មវត្ថុនៃសំណូកដល់អភិបាលអាចជា ទ្រព្យសម្បត្តិ ឬ សេវា។[258]

ជាឧទាហរណ៍៖ ក្រុមហ៊ុន "ក" បានទាក់ទងទៅសមាជិកក្រុមប្រឹក្សាភិបាលចំនួន២នាក់ នៅក្នុងក្រុមហ៊ុន "ខ" ថា ក្រុមហ៊ុន "ក" នឹងឲ្យរង្វាន់ជាសាច់ប្រាក់ និងភាគហ៊ុនក្នុងក្រុមហ៊ុន ដែល

[257] ក្រមព្រហ្មទណ្ឌ, មាត្រា ២៨០។

[258] ក្រុមមេធាវី សំរិទ្ធ (SLG), above n 256.

សមាជិកក្រុមប្រឹក្សាភិបាល ២នាក់នោះបានធ្វើការ បើសិនជាសមាជិកក្រុមប្រឹក្សាភិបាលទាំង ២ នាក់ អាចបញ្ចុះបញ្ចូលឲ្យភាគហ៊ុនិកដទៃទៀតបោះឆ្នោតលក់ភាគហ៊ុននោះឲ្យក្រុមហ៊ុន "ខ"។ ក្រុមហ៊ុនទាំងពីរនេះជាក្រុមហ៊ុនលក់ផលិតផលអាហារបំប៉នដូចគ្នា។

ក្នុងករណីឧទាហរណ៍ខាងលើនេះ បើសិន ក្រុមហ៊ុន "ក" បានទិញភាគហ៊ុននោះបានមែន នោះសមាជិកនៃក្រុមប្រឹក្សាទាំងពីរនាក់នោះ នឹងអាចត្រូវចោទពីបទស៊ីសំណូករបស់អភិបាល បើសិនមានភស្តុតាងបញ្ជាក់ថា ពួកគេទាំងពីរនាក់នោះបានទទួលផលប្រយោជន៍ពីក្រុមហ៊ុន "ក" នោះ ដោយទទួលបានសាច់ប្រាក់ និងភាគហ៊ុន និងភស្តុតាងផ្សេងៗទៀតដែលកើតមាន។ ក្នុងករណីនេះ អភិបាលដទៃទៀតនៃក្រុមប្រឹក្សាភិបាល ឬ ភាគហ៊ុនិករបស់ក្រុមហ៊ុន ខ អាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងអំពើរបស់អភិបាលទាំងពីរ ពីបទស៊ីសំណូកដោយអភិបាលតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនេះបាន។ អភិបាលបានឆ្លៀតឱកាសពីការស៊ីសំណូកនេះក្នុងការប្រកួតប្រជែងជាមួយក្រុមហ៊ុនរបស់ខ្លួន ពីព្រោះក្រុមហ៊ុន ក គឺជាក្រុមហ៊ុនលក់អាហារបំប៉នដូចនឹងក្រុមហ៊ុនរបស់ខ្លួន។ ជាទូទៅ អភិបាលត្រូវជាប់ខសម្ងាត់របស់ក្រុមហ៊ុន ដែលដាក់បម្រាមមិនឲ្យមានសកម្មភាព Self-Dealing ការទទួលអំណោយ ឬ រង្វាន់ ឬ ធ្វើសកម្មភាពនាំឲ្យបាត់បង់ប្រយោជន៍ក្រុមហ៊ុន។ នៅក្នុងករណីនេះផងដែរ អភិបាលបានល្មើសនឹងតួនាទីរបស់ខ្លួន ដែលអភិបាលមានតួនាទីតាមច្បាប់សហគ្រាសពាណិជ្ជកម្មផងនោះ អភិបាលមិនបានដើរតួនាទីជាអ្នកថែរក្សាទ្រព្យសម្បត្តិក្រុមហ៊ុន និងការជោគជ័យរបស់ក្រុមហ៊ុនទេ។

បន្ថែមពីនេះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានចែងទាក់ទងនឹងបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ជាបណ្តឹងដែលមានគោលបំណងក្នុងការស្វែងរកអត្ថិភាពនៃ បទល្មើស ក្នុងការបង្ហាញអោយឃើញពីពិរុទ្ធភាពនៃជនល្មើស និងចាត់វិធានការតាមផ្លូវច្បាប់។[259] នៅក្នុងបណ្តឹងអាជ្ញានេះ អនុវត្តទៅលើគ្រប់បុគ្គលទាំងអស់រួមទាំង រូបបុគ្គល និងនីតិបុគ្គល ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទជាដើម។[260] ទន្ទឹមនឹងក្នុងបណ្តឹងអាជ្ញាក៏មានមូលហេតុ ដែលធ្វើអោយបណ្តឹងត្រូវរលត់ផងដែរមានដូចជា ជនល្មើសបានទទួលមរណភាព ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ និងចុងក្រោយការផុតរលត់នៃអាជ្ញាយុកាល។[261]

[259] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២។
[260] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣។
[261] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៧។

នៅក្នុងបទល្មើស ដែលបានរៀបរាប់នៅក្នុងឧទាហរណ៍ខាងលើ បទស៊ីសំណូកករបស់អភិបាលជាអាទិ៍ ជាបទឧក្រិដ្ឋ ដែលអាជ្ញាយុកាលនៃបទល្មើសមានរយៈពេល ១៥ឆ្នាំ ត្រូវបានគិតចាប់ពីការប្រព្រឹត្តបទល្មើស។[262] ម្យ៉ាងទៀត បើអភិបាលទាំងពីរប្រព្រឹត្តបទល្មើសមិនបានសម្រេចនោះ ទេ ក៏អ្នកទាំងពីរអាចត្រូវបានចោទពីបទប៉ុនប៉ងស៊ីសំណូកករបស់អភិបាលជាអាទិ៍ផងដែរ ក្នុងករណី ដែលមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ ហើយភាគីដែលជាសហចារីក៏អាចនឹងត្រូវជាប់ពីបទប៉ុនប៉ង នេះផងដែរ។[263]

[262] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ១០។

[263] ក្រមព្រហ្មទណ្ឌ, មាត្រា ២៨១។

# សេចក្តីសន្និដ្ឋាន

ការវិវត្តិនៃការគ្រប់គ្រងក្រុមហ៊ុន បានធ្វើឲ្យតួនាទីរបស់អភិបាលមានការបែងចែកខុសពីមុន ដែលតួនាទីជាអភិបាលពេលខ្លះពុំអាចកំណត់បានថា តើអភិបាលជាបុគ្គលម្នាក់ក្នុងនាមជាអ្នកតំណាងនីតិបុគ្គល ឬ ជារចនាសម្ព័ន្ធនៃនីតិបុគ្គល ឬ ជាបុគ្គលិកគ្រប់គ្រងដោយកិច្ចសន្យាការងារ និងច្បាប់ការងារ ឬ ពេលខ្លះទៀតអភិបាលត្រូវបានមើលឃើញថាជា អ្នកទទួលគ្រប់គ្រង (Trustee)។ ប៉ុន្តែ បើយោងតាមសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីបានលើកឡើងថា អភិបាលជាអ្នកតំណាងរបស់នីតិបុគ្គល។ មួយវិញទៀត ច្បាប់សហគ្រាសពាណិជ្ជកម្ម ក៏មានចែងអំពីតួនាទីសំខាន់ៗពីរគឺ ធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីផលប្រយោជន៍ខ្ពស់ដល់ក្រុមហ៊ុន និងអនុវត្តដោយយកចិត្តទុកដាក់ ព្យាយាម និងជំនាញ។

ជាទូទៅ តួនាទីនេះត្រូវបានស្គាល់ថាជា Duty of Loyalty និង Duty of Care តួនាទីពីរនេះមានភាពច្របូកច្របល់នៅក្នុងប្រទេស Common Law ហើយដាក់បន្ទុកនៃការទទួលខុសត្រូវធ្ងន់ទៅលើអភិបាល ប៉ុន្តែ ក្រោយមកយុត្តាធិការរបស់តុលាការនៃប្រទេសប្រព័ន្ធ Common Law ក៏ដូចជាការបង្កើតច្បាប់ផ្សេងៗ ដើម្បីដោះស្រាយនូវបញ្ហានេះ។ ចំពោះប្រទេសដែលប្រើប្រព័ន្ធច្បាប់ Civil Law ដែលមានតែបញ្ញត្តិច្បាប់ ហើយបញ្ញត្តិនោះត្រឹមតែន័យទូទៅ នាំឲ្យមានការបកស្រាយខុសគ្នា និងផ្ទុយពីគោលគំនិតនៃបញ្ញត្តិច្បាប់។ នៅតៃវ៉ាន់ Fiduciary duty ដែលបានបញ្ចូលទៅក្នុងច្បាប់ក្រុមហ៊ុន គឺជាវិធានមួយក្នុងការពង្រឹងអភិបាលកិច្ចល្អរបស់ក្រុមហ៊ុន អ្វីដែលជាបញ្ហាកើតមាននៅតៃវ៉ាន់នោះ គឺច្បាប់ពុំមានសមធម៌ តៃវ៉ាន់ គឺជាប្រទេសដែលប្រើប្រព័ន្ធច្បាប់ Civil Law មិនមានការ ប្រើប្រាស់យុត្តាធិការ និងការដាក់ Fiduciary duty នៅក្នុងច្បាប់មិនមានការបង្ហាញបន្ថែម ដូចជា បញ្ហា Self-Dealing ឱកាស ឬ ផលប្រយោជន៍ក្រុមហ៊ុន និងសកម្មភាពណាចាត់ទុកថាសមហេតុផលតាមគោលបំណងរបស់ក្រុមហ៊ុន។

ប្រកាសស្តី ពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ បានកែប្រែរចនាសម្ព័ន្ធមួយចំនួនរបស់ក្រុមហ៊ុន។ បញ្ញត្តិមួយនៃប្រកាសនេះចែងថា “ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា។” ប្រសិនបើ ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ មិនមានយកមកអនុវត្តនៅក្នុងការទទួលខុសត្រូវរបស់អភិបាលទៅលើតួនាទីទេនោះ បទបញ្ញត្តិនៃច្បាប់សហគ្រាសពាណិជ្ជកម្ម មិនគ្រាប់គ្រាន់សម្រាប់ជាការវិនិច្ឆ័យទង្វើណាជាកំហុសរបស់អភិបាល។ទន្ទឹមនឹងនេះដែរ រចនាសម្ព័ន្ធដែល

មានថៃង នៅក្នុងប្រកាសនេះមានភាពខុសគ្នានៃច្បាប់សហគ្រាសពាណិជ្ជកម្ម ហើយបើយោងតាមការអនុវត្តរបស់ធនាគារអេស៊ីលីដា ធនាគារនេះមានរចនាសម្ព័ន្ធទាំងស្រុងដូចនឹងប្រកាសនេះ។

ការទទួលខុសត្រូវរបស់អភិបាលនៅពេលដែលអភិបាលបានប្រព្រឹត្តល្មើសនឹងសិទ្ធិ និងអំណាចស្របច្បាប់ ឬ កំហុសនៃការដឹកនាំ។ ចំពោះកំហុសនៃការដឹងនាំនេះ ដើម្បីដឹងថាអភិបាលមានកំហុសឬអត់គឺផ្អែកទៅលើបញ្ញត្តិនៃតួនាទី ថាតើអភិបាលបានយក Duty of Care និង Duty of Loyalty មកអនុវត្តចំពោះការដឹកនាំរបស់ខ្លួនដែរទេ។ ការទទួលខុសត្រូវរដ្ឋប្បវេណីភាគច្រើន គឺដោយសារកំហុសនៃការដឹកនាំរបស់អភិបាល ឬ អំពើធ្វេសប្រហែសផ្សេងៗ។ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីមិនពិបាកក្នុងការបញ្ជាក់ថាជាកំហុសនោះទេ ប៉ុន្តែ ការទទួលខុសត្រូវព្រហ្មទណ្ឌគឺត្រូវប្រាកដថា អភិបាលជាបុគ្គលដែលបានស្ថិតនៅក្នុងការប្រព្រឹត្តបទល្មើស។ ដើម្បីដឹងថាអភិបាលបានប្រព្រឹត្តបទល្មើសនោះ នៅពេលសកម្មភាពអភិបាលស្ថិតក្នុង Ultra Vires និងល្មើសនឹងតួនាទី ឬ ឋានៈជាអភិបាល។ មួយវិញទៀត ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌគឺនៅពេលអភិបាលបានអនុវត្ត "Directed Mind" នេះក៏ជាចំណុចមួយដែលអភិបាលត្រូវប្រយ័ត្ន។ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងបរិបទនៃប្រទេសថៃ បានបង្ហាញថា អភិបាលដែលមានទំនួលខុសត្រូវក្នុងការគ្រប់គ្រង ជាទូទៅ អភិបាលប្រតិបត្តិ គឺជាបុគ្គលដែលអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនៅក្រោមគោលការណ៍ "Directed Mind" នេះនៅក្នុងច្បាប់របស់ប្រទេសថៃ។

# អនុសាសន៍

ដើម្បីពង្រឹងការអនុវត្ត ចំពោះចន្លោះខ្វះខាតក្នុងការកំណត់ការទទួលខុសត្រូវរបស់អភិបាល ដោយផ្អែកលើការសិក្សាខាងលើ ក្នុងអត្ថបទនេះនឹងលើកការអនុវត្តជោគជ័យរបស់បណ្ដាប្រទេសមួយចំនួនដើម្បីយកមកបំពេញនូវចន្លោះខ្វះខាតនេះ។ មូលហេតុដែលបញ្ហានេះត្រូវយកចិត្តទុកដាក់នោះដោយសារ កម្ពុជាកំពុងមានការរីកចំរើនវិស័យឯកជន ជាពិសេសទីផ្សារមូលបត្រកម្ពុជាកំពុងជំរុញឲ្យមានការកើនឡើង នៅវិស័យសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ។ អនុសាសន៍នៃអត្ថបទនេះមាន ៣ចំណុចគឺ៖

អនុសាសន៍ដំបូង ច្បាប់ទាក់ទងនឹងវិស័យក្រុមហ៊ុននេះត្រូវឲ្យមានភាពយុត្តិធម៌ចំពោះអភិបាល ដូច្នេះហើយ តួនាទី Fiduciary Duty ត្រូវកំណត់ឲ្យបានច្បាស់លាស់ ជាពិសេសនៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម។

អនុសាសន៍ទីពីរ គឺត្រូវបែងចែកចំណុចសំខាន់ៗនៃការទទួលខុសត្រូវរបស់អភិបាលឲ្យបានច្បាស់លាស់។ បញ្ញត្តិមួយចំនួនដែលមានចែងក្នុងប្រកាស អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ គឺជាបញ្ញត្តិថ្មីមួយក្នុងការកំណត់អំពីតួនាទីរបស់អភិបាលរបស់អភិបាល ប៉ុន្តែ បញ្ញត្តិនេះត្រូវមានចែងនៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មមុនសិន។

អនុសាសន៍ចុងក្រោយ ទោះបីជាអនុសាសន៍ទាំងពីរខាងលើបានកំណត់រួចរាល់ហើយក៏បញ្ញត្តិដែលទាក់ទងនោះបានដាក់បន្ទុកដល់អភិបាលទាំងស្រុង ក្នុងការទទួលខុសត្រូវចំពោះការវិនិច្ឆ័យសេចក្ដីរបស់ខ្លួន។ ទន្ទឹមនេះផងដែរ ក៏មានគោលការណ៍ផ្សេងទៀតក្នុងការកាត់បន្ថយការទទួលខុសត្រូវរបស់អភិបាល ដូចជា គោលការណ៍ Exculpatory ជាគោលការណ៍ដែលក្រុមហ៊ុនចេញសងនៅពេលដែលអភិបាលធ្វើសកម្មភាពដោយសុចរិត, Exculpaltory ជាគោលការណ៍តម្រូវឲ្យលក្ខន្តិកៈក្រុមហ៊ុនមិនឲ្យអភិបាលទទួលខុសត្រូវ ចំពោះសកម្មភាពការធ្វេសប្រហែសដោយអចេតនា និងគោលការណ៍ ប្រើធានារ៉ាប់រង គឺជាគោលការណ៍ថ្មីមួយដែលគោលការណ៍នេះប្រើ នៅពេល ដែលមានការចំណាយពេលចាញ់ក្ដី និងចំណាយក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងៗ និងចំពោះការខូចខាត។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


ក្រមនីតិនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ០៨ មិថុនា ២០១៣។

ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ២៧ កុម្ភៈ ២០១៨។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១ ១៣ មិនា ១៩៩៧។

ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងចុះបញ្ជីពាណិជ្ជកម្ម,លេខ នស/រកម/១១៩៩/១២, ១៨ វិច្ឆិកា ១៩៩៩។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។

ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ (១៥ មករា ២០១០)។


## សៀវភៅ


Bryan A. Garner. 2006. *BLACK LAW DICTIONARY*, (Thomson/West, 3rd ed.).

Deloitte Touche Tohmastsu Limited. 2013. *Duties of Directors*, available at: https://www2.deloitte .com/content/dam/Deloitte/za/Documents/governance-risk-compliance/ZA_DutiesOfDirec 201 _16042014.pdf.

DFDL law firm. 2011. *A Look at Cambodia's Legal Framework for Company Director Liability*, Available at: https://www.dfdl.com/resources/legal-and-tax-updates/a-look-at-cambodias-legal-framework-for-company-director-liability/.

Roger LeRoy Miller & Gaylord A. Jentz. 1997. *Business Law today: text and summarized cases legal, ethical, regulatory & internation environment*. west publishing company.

Sciaroni & Associates Law Firm, *Doing Business in Cambodia*, (Phnom Penh, 2015), 31, available at: http://www.saasia.com/home/upload/thumbnails/files/DBG% 20Cambodia%202017_FINAL(1).pdf.

កៅ មុយថង. ២០១៥. *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣, ភ្នំពេញ៖ អង្គរ។

គុយ នាម. ២០១៦. *ច្បាប់ក្រុមហ៊ុន* ។

ហ៊ី សោភា, *នីតិព្រហ្មទណ្ឌ*។

ហៃល ចំរើន. ២០០៥. *នីតិការងារ*, ហ្វូណន។

## ដើនណល

Andrew Keay, Shareholder Primacy in Corporate Law: Can it Survive? Should it Survive?.

Andrew Keay. 2010. THE DUTY TO PROMOTE THE SUCCESS OF THE COMPANY: IS IT FIT FOR PURPOSE?. University of Leeds School of Law, Centre for Business Law and Practice Working Paper (August 20).

Austin Tyler, Junior Policy Analyst and et al. 2015 “OECD-Southeast Asia Corporate Governance Initiative (Hanoi, Vietnam, Issue Paper 12-13 May).

Bernard S. Sharfman.2014. Shareholder Wealth Maximization And Its Implementation Under Corporate Law (Vol. 66).

Carsten Gerner-Beuerle, Philipp Paech & Edmund Philipp Schuster. 2010. “Study on Director’s Duties and Liability”, (London, April).

Carter G. Bishop. 2007. A Good Faith Revival of Duty of Care Liability in Business Organization Law (Research Paper 07-02 Vol. 41, January 24) Suffolk University Law School.

Christoph Van der Elst. Shareholder Rights and Shareholder Activism: The Role of the General Meeting of Shareholders.

Christopher CHEN Choa-hung. 2010. Transplantation of Fiduciary Duties into Civil Law Jurisdiction: Experiences from Taiwan. Hong Kong .

David Block and Anne-Marie Gerstner, One-Tier vs. Two-Tier Board Structure: A Comparison Between the United States and Germany, (2016), Comparative Corporate Governance and Financial Regulation, Paper 1.

David F. Larcker. Board of Director: Duties & Liabilities (Stanford Graduate School of Business, Center for Leadership Development & Research)

Fergal McManus. 2011. DIRECTORS DUTIES – INSOLVENT COMPANIES & WINDING UP”, (January) available at: https://www.morganmcmanus.com/wp-content/uploads/2015/09/Directors_Duties_Insolvent%20 Companies . %20pdf.

Fidy Xiangxing Hong.2010. DIRECTOR REGULATION IN CHINA: THE SINONIZATION PROCESS (November).

IR Global Rankings Team. 2010.THE BOARD OF DIRECTORS AND SHAREHOLDERS. issue 21 (October).

Julian Velasco. 2010. HOW MANY FIDUCIARY DUTIES ARE THERE IN CORPORATE LAW?, University of Notre Dame (Notre Dame Law School, Legal Studies Research Paper No. 09-35), (Southen California Law Review: No. 6, Vol. 83).

Lorne N. Switzer and Yu Cao. 2011. Shareholder Interest vs. Board of Director Member's Interests and the Profitability of Firms (March)

MANEUL LADIEGES. 2013. CRIMINAL LIABILITY OF DIRECTORS OF A PRIVATE LIMITED COMPANY SEATED IN GERMANY. *Springerlink.com*, (DOI 10.1007/s10609-012-9189-x).

Matsiko Godwin Muhwezi, "THE CASE FOR CRIMINAL LIABILITY", *ResearchGate*, (May 2016), 15, available at: https://www.researchgate.net/publication/309041784.

Matthew Conaglen and Jennifer G. Hill. 2017. Directors' Duties and Legal Safe Harbours: A Comparative Analysis (March).

MPDF, 2005. A Summary of Cambodia's WTO Agreement. *Business Issue Bulletin* 6.

MPDF.2005. កិច្ចព្រមព្រៀងជាមួយអង្គការពិភពលោក (WTO) របស់កម្ពុជា (ការពិនិត្យមើលកាតព្វកិច្ចនីតិកម្ម). *ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្ម* ១០។

Napat Siri-armart & Athistha Chitranukroh. 2017. New Law on Criminal Liabilities for Directors: Elimination of Strict Liability Presumption. *Tilleke & Gibbins International Ltd*, avaible at: https://www.tilleke.com/resources/new-law-criminal-liabilities-directors-elimination-strict-liability-presumption.

Nicolene Schoeman. 2011. EXECUTIVE AND NON-EXECUTIVE DIRECTOR IN TERMS OF THE NEW COMPANIES ACT. (Schoeman Attorneys).

Paul L Davies. 2000. The Board of Directors: Composition, Structure, Duties and Powers, ORGANISATION FOR ECONOMIC CO-OPERATION AND DEVELOPMENT (OECD). (7-8 Dec, Stockholm Sweden).

Rajah & Tann. 2001. Duties of Directors of Insolvent Companies And Companies In Liquidation (Singapore, March) available at: https://eoasis.rajahtann.com/eoasis/lb/pdf/Duties-Of-Dirs-Insolvent-Co.pdf.

Scott Bomhof. 2010. Duties of Directors in the Insolvency Zone. *Corporate Governance Report*,(Vol. 5, No. 2, June) available at: https://www.torys.com/Publications/Documents/Publication%20PDFs/AR2010-24.pdf.

Stephen M. Bainbridge. Director Primacy: The Means and Ends of Corporate Governance (University of California, Research Paper No. 02-06).

Susan Watson. The Significance of the Source of the Power of Boards of Directors in UK company Law.

ក្រុមមេធាវី សំរិទ្ធ(SLG).២០១៤. វិភាគសាលក្រមព្រហ្មទណ្ឌ ៖បទរំលោភលើសេចក្តីទុកចិត្ត (សីហា)។

ចក សម្បត្តិ. ២០១៥. អំពើអនីត្យានុកូល. ការផ្សាយរបស់ក្រុមត្រាជូ (សាលាត្រាជូ៖ មិនា)។

## កាសែត

Cheng Sokhorng. 2016. Firms flimsy on corporate governance. *Phnom Penh Post*, 05 August, Available at: https://www.phnompenhpost.com/business/firms-flimsy-corporate-governance.

Austin Tyler. 2017. Junior Policy AnalystHor Kimsay. Regulator pushes for corporate governance. *Phnom Penh Post*, 12 April, Available at: https://www.phnompenhpost.com/business/regulator-pushes-corporate-governance.

Hor Kimsay. 2017. Suits filed over ponzi schemes. *Phnom Penh Post*. 31 May , Available at: https://www.phnompenhpost.com/business/suits-filed-over-ponzi-schemes.

Kong Meta. 2018. Number of plaintiffs in Empire Big Capital fraud suit up to 900. *Phnom Penh Post*, 08 January,

May Kunmakara. 2018. Cambodia urged to focus on good corporate governance. *Khmer Times* , January 23, Available at: https://www.khmertimeskh.com/50103714/cambodia-urged-to-focus-on-good-corporate-governance/

Siv Meng. 2016. A year on, Cambodia has gained little from the AEC integration. *Phnom Penh Post*. 15 December Available at: https://www.phnompenhpost.com/post-property/year-cambodia-has-gained-little-aec-integration.

## បទបង្ហាញ

អ្នកនិពន្ធអនាមិក. នីតិព្រហ្មទណ្ឌធុរកិច្ច។

## គេហទំព័រ

https://www.acledabank.com.kh/kh/eng/ff_orgchart (រចនាសម្ព័ន្ធធនាគារអេស៊ីលីដា)។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មការមូលបត្រកម្ពុជា

# SECURITIES AND EXCHANGE COMMISSION OF CAMBODIA

# ប្រកាស

## ស្តីពី

## អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

# PRAKAS

## ON

## THE CORPORATE GOVERNANCE FOR LISTED COMPANIES

២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ ០០៧............គ ម ក

# ប្រកាស

## ស្តីពី

## អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

*****

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន


អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ការកំណត់សិទ្ធិអំណាចនិងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ ស្របតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ៤.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ÷

១-ក្រុមប្រឹក្សាភិបាល សំដៅដល់បុគ្គលមួយក្រុមដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិកតាមរយៈមហាសន្និបាតភាគហ៊ុនិក ហើយមានសិទ្ធិអំណាចអនុវត្តភារកិច្ចដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន។

២-គណៈកម្មាធិការសវនកម្ម សំដៅដល់គណៈកម្មាធិការមួយនៃក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ រាល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ ព្រមទាំងសវនកម្ម។

៣-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការវិភាគ វាយតម្លៃ តាមដាន និងរាយការណ៍អំពីហានិភ័យរបស់ក្រុមហ៊ុន ព្រមទាំងគ្រប់គ្រងហានិភ័យទាំងនោះ។

៤-គណៈកម្មាធិការតែងតាំង សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញ និងវាយតម្លៃ អំពីគុណវុឌ្ឍិបុគ្គលទាំងឡាយដែលជាបេក្ខភាពសម្រាប់ការតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលទទួលបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

៥-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៦-បុគ្គលិកជាន់ខ្ពស់ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការក្រុមហ៊ុន និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៧-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច  សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនតិចជាង ០៥ (ប្រាំ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន។

៨-សមាជិកគ្រួសារផ្ទាល់ សំដៅដល់ប្ដី ប្រពន្ធ កូន ឪពុកម្ដាយ បងប្អូនប្រុស បងប្អូនស្រី។

៩-សវនករឯករាជ្យ  សំដៅដល់សវនកររបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ហើយដែលទទួលស្គាល់ដោយ **គ.ម.ក.**។

១០-សែលហ្វ៍ឌៀលីង (Self-Dealing) សំដៅដល់ទង្វើរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិ ជំនួស អ្នកផ្ដល់ប្រឹក្សាច្បាប់ បុគ្គលិករបស់ក្រុមហ៊ុន ឬក៏បុគ្គលពាក់ព័ន្ធនឹងកិច្ចសន្យាដែលទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួន នៅក្នុងប្រតិបត្តិការណាមួយ។

១១-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

១២-អភិបាលឯករាជ្យ  សំដៅដល់សមាជិកឯករាជ្យដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។

១៣-អភិបាលប្រតិបត្តិ  សំដៅដល់អភិបាលដែលមានមុខតំណែងជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

១៤-អភិបាលមិនប្រតិបត្តិ  សំដៅដល់អភិបាលដែលមិនមែនជាអភិបាលប្រតិបត្តិ។

## ជំពូកទី ២
## ភាគហ៊ុនិក

**ប្រការ ៥.-**

សិទ្ធិជាមូលដ្ឋានរបស់ភាគហ៊ុនិក ដែលបានកំណត់ដោយច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម មិនត្រូវបានដកហូតឬរឹតត្បិតដោយការចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនឡើយ។ ភាគហ៊ុនិកត្រូវទទួលបាននូវការគោរព និងការពារសិទ្ធិទាំងនេះ ពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុន។

ភាគហ៊ុនិកមានសិទ្ធិទទួលបានការចុះបញ្ជីជាកម្មសិទ្ធិករលើបណ្ណភាគហ៊ុនប្រកបដោយសុវត្ថិភាព សិទ្ធិក្នុងការផ្ទេរ ឬកាត់កងបណ្ណភាគហ៊ុន សិទ្ធិទទួលបាននូវព័ត៌មានពីក្រុមហ៊ុន សិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក និងអនុវត្តសិទ្ធិបោះឆ្នោត ដូចជា សិទ្ធិបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួសនូវសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់។

**ប្រការ ៦.-**

ការជ្រើសរើសអភិបាលត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត ដោយអនុលោមតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន។ ភាគហ៊ុនិកមានសិទ្ធិធ្វើការបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួស នូវអភិបាល ព្រមទាំងការបោះឆ្នោតអនុម័តនូវកិច្ចការផ្សេងៗរបស់ក្រុមហ៊ុន តាមរយៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកក្នុងរូបភាពដោយផ្ទាល់ តាមរយៈអាណត្តិគាហកៈ។

**ប្រការ ៧.-**

ដោយអនុលោមតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាន នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការ ឬនៅពេលប្រជុំមហាសន្និបាតភាគហ៊ុនិកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ។

ក្រុមហ៊ុនគួរតែមានគេហទំព័រមួយដែលអាចឱ្យភាគហ៊ុនិក និងសាធារណជនអាចទទួលបានព័ត៌មាន។ ភាគហ៊ុនិកអាចទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព្រមទាំងព័ត៌មានរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ តាមរយៈគេហទំព័ររបស់ក្រុមហ៊ុន និងព័ត៌មានផ្សេងទៀតអំពីក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនមិនមានគេហទំព័រទេ ភាគហ៊ុនិកអាចធ្វើសំណើសុំថតចម្លងឯកសារដូចរៀបរាប់ខាងលើ ដោយតម្រូវឱ្យបង់ថ្លៃសមរម្យសម្រាប់ការបោះពុម្ព និងការចែកចាយឯកសារទាំងនោះ។ ភាគហ៊ុនិកមានសិទ្ធិទទួលបានទាន់ពេល អំពីព័ត៌មានដែលបានរៀបរាប់ខាងលើ។

**ប្រការ ៨.-**

ដោយអនុលោមតាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកដែលប្រមូលផ្ដុំសម្លេងបានចាប់ពី ៥១ (ហាសិបមួយ) ភាគរយឡើងទៅ មានសិទ្ធិស្នើឱ្យអភិបាលរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ និងស្នើឡើងនូវកម្មវត្ថុដើម្បីដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំ ដែលកម្មវត្ថុទាំងនោះមាន ដូចជា ការកែតម្រូវលក្ខន្តិកៈក្រុមហ៊ុន បញ្ហាអភិបាលកិច្ចរបស់ក្រុមហ៊ុន ការប្រែប្រួលមូលធន ព្រមទាំងកម្មវត្ថុផ្សេងទៀតដែលអនុញ្ញាតដោយលក្ខន្តិកៈក្រុមហ៊ុន។

អភិបាលមានសិទ្ធិកោះប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ និងវិសាមញ្ញ។

**ប្រការ ៩.-**

ក្រុមប្រឹក្សាភិបាលត្រូវតែការពារផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ និងត្រូវការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច រួមមាន ៖

-សិទ្ធិស្វែងរកព័ត៌មាន

-សិទ្ធិក្នុងការបញ្ចេញយោបល់

-សិទ្ធិស្នើកែតម្រូវ។

ក្រុមប្រឹក្សាភិបាលត្រូវធានាធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងអន្តរកម្មរវាងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច បុគ្គលិកជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវស្នើសុំការអនុម័តពីភាគហ៊ុនិក លើការកែតម្រូវនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អំពីប្រព័ន្ធបោះឆ្នោតគ្រួតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ ករណីទទួលបានការអនុម័ត ប្រព័ន្ធបោះឆ្នោតគ្រួតនេះត្រូវបានអនុវត្តនៅរាល់កិច្ចប្រជុំ។

**ប្រការ ១០.-**

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានថ្នាក់ដូចគ្នាត្រូវមានសិទ្ធិដូចគ្នា។ នីតិវិធី និងដំណើរការនៃមហាសន្និបាតភាគហ៊ុនិក ត្រូវរៀបចំឡើងក្នុងលក្ខខណ្ឌដែលអនុញ្ញាតឱ្យភាគហ៊ុនិកទទួលបាននូវសិទ្ធិដូចគ្នា។

ភាគហ៊ុនធម្មតាក្នុងមួយភាគហ៊ុន ត្រូវផ្តល់ឱ្យភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោតមួយសម្លេង ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយសិទ្ធិបោះឆ្នោតនេះមិនអាចត្រូវបានរឹតត្បិតដោយបុគ្គលណាឡើយ។

ភាគហ៊ុនិកត្រូវតែទទួលបាននូវព័ត៌មានចាំបាច់ និងទាន់ពេល ពីក្រុមហ៊ុនដូចៗគ្នា ដោយគ្មានភាគហ៊ុនិកណាម្នាក់អាចទទួលបានព័ត៌មានដែលមិនទាន់បង្ហាញជាសាធារណៈពីក្រុមហ៊ុននោះទេ។

**ប្រការ ១១.-**

អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក មិនត្រូវមានជាប់ពាក់ព័ន្ធ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬសៃហ្វ៍ឌៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមិនត្រូវធ្វើការជួញដូរមូលបត្ររបស់ក្រុមហ៊ុនក្នុងរយៈពេល ៖

- ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ។

- ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

នៅក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនត្រូវអនុម័ត និងផ្សព្វផ្សាយគោលនយោបាយគ្រប់គ្រងការជួញដូរមូលបត្ររបស់ក្រុមហ៊ុនដែលធ្វើឡើងដោយអភិបាល និងបុគ្គលិក។

**ប្រការ ១២.-**

ភាគហ៊ុនិកត្រូវមានការទទួលខុសត្រូវ ចំពោះការប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។ ចំពោះភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ត្រូវតែមានកាតព្វកិច្ចផ្តល់ព័ត៌មានដល់សាធារណជន នៅពេលដែលមានការផ្លាស់ប្តូរចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់ ដូចមានចែងក្នុងអនុក្រឹត្យ។

## ជំពូកទី ៣
## ក្រុមប្រឹក្សាភិបាល

**ប្រការ ១៣.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានក្រុមប្រឹក្សាភិបាលដែលដឹកនាំ និងត្រួតពិនិត្យក្រុមហ៊ុន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ក្រុមប្រឹក្សាភិបាលត្រូវតែជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់ភាគហ៊ុនិក ដែលចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក។

**ប្រការ ១៤.-**

ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិចបំផុតចំនួន ០៥ (ប្រាំ) រូប និងមិនត្រូវលើសពី ១៥ (ដប់ប្រាំ) រូបឡើយ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវតែមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ១/៥ (មួយភាគប្រាំ) នៃចំនួន

អភិបាលសរុប។ ករណីអភិបាលឯករាជ្យជាជនបរទេស អភិបាលនេះត្រូវមានបទពិសោធន៍ការងារនៅកម្ពុជាយ៉ាងហោចណាស់រយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលក្លាយជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន។

អភិបាលត្រូវមានការទទួលខុសត្រូវច្បាស់លាស់ ក្នុងន័យថា គ្មានបុគ្គលជាអភិបាលណាម្នាក់ ឬបុគ្គលមួយក្រុមតូចណាមួយ អាចគ្របសង្កត់លើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលឡើយ។

**ប្រការ ១៥. –**

ក្រុមប្រឹក្សាភិបាលត្រូវបំពេញតួនាទីរបស់ខ្លួន ប្រកបដោយសុចរិត ជំនាញ និងយកចិត្តទុកដាក់ ដោយអនុវត្តនូវតួនាទីសំខាន់ៗ ដូចខាងក្រោម ÷

១-ត្រូវមានការទទួលខុសត្រូវពេញលេញ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

២-ត្រូវតែប្រតិបត្តិដោយស្មោះត្រង់ ប្រកបដោយសុឆន្ទៈ និងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

៣-ត្រូវធានាថា ក្រុមហ៊ុនបានធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិក និងភាគីពាក់ព័ន្ធដទៃទៀត។

៤-ធ្វើការកំណត់ តាមដាន និងវាយតម្លៃយុទ្ធសាស្ត្រ គោលនយោបាយ លក្ខណៈវិនិច្ឆ័យ ប្រសិទ្ធភាពគ្រប់គ្រង និងផែនការធុរកិច្ច។

៥-បង្កើត និងតាមដានការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង។

៦-ផ្តល់នូវភាពជាអ្នកដឹកនាំ ដោយដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ព្រមទាំងធានាឱ្យបានថា ធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបចំពោះគោលដៅដែលបានកំណត់។

៧-អភិបាលមិនត្រូវប្រើអំណាចផ្ទាល់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ទៅគាបសង្កត់បុគ្គលិកជាន់ខ្ពស់ នៅក្នុងការអនុវត្តការងាររបស់គេឡើយ។

**ប្រការ ១៦. –**

ក្រុមប្រឹក្សាភិបាលត្រូវរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់យ៉ាងហោចណាស់ ០១ (មួយ) ដងរៀងរាល់ត្រីមាស។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមដោយផ្ទាល់គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ទាំងសាមញ្ញ និងវិសាមញ្ញ។ ករណីក្រុមហ៊ុនមានអភិបាលឯករាជ្យរាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវតែមានវត្តមានរបស់អភិបាលឯករាជ្យយ៉ាងតិច ០១ (មួយ) រូប។

**ប្រការ ១៧.-**

ក្រុមប្រឹក្សាភិបាលត្រូវមានការទទួលខុសត្រូវ ដោយធានាថា កម្រិតនៃប្រាក់បំណាច់ ឬលាភការត្រូវតែសមល្មមដើម្បីទាក់ទាញ និងរក្សាអភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់ ដើម្បីភាពជោគជ័យរបស់ក្រុមហ៊ុន។ សមាមាត្រនៃប្រាក់បំណាច់ និងលាភការរបស់អភិបាលប្រតិបត្តិ ត្រូវតែធ្វើយ៉ាងណាឱ្យមានការជាប់ទាក់ទងរវាងរង្វាន់លើកទឹកចិត្តជាមួយនឹងលទ្ធផលរបស់បុគ្គល ក្រុមការងារ និងមាននិរន្តភាពធុរកិច្ចក្រុមហ៊ុនចំពោះភាគហ៊ុនិក។

ក្រុមហ៊ុនត្រូវមានគោលនយោបាយផ្លូវការ និងមានតម្លាភាពស្ដីអំពីលាភការ ដោយត្រូវកំណត់កញ្ចប់លាភការ និងប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ឱ្យបានច្បាស់លាស់។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនត្រូវបង្ហាញដោយឡែកអំពីព័ត៌មានស្ដីពីប្រាក់បំណាច់ និងលាភការផ្ទាល់ ឬប្រយោលសរុបរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ រួមទាំងអគ្គនាយក។

**ប្រការ ១៨.-**

អភិបាលត្រូវទទួលបានព័ត៌មានពេញលេញ គ្រប់គ្រាន់ និងទាន់ពេល មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តជាគោលការណ៍សម្រាប់ការផ្ដល់ព័ត៌មានទាំងនោះជូនក្រុមប្រឹក្សាភិបាល។

បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមានកាតព្វកិច្ចផ្ដល់ជូនក្រុមប្រឹក្សាភិបាលនូវព័ត៌មានពេញលេញ គ្រប់គ្រាន់និងទាន់ពេល។ ករណីចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អ អភិបាលម្នាក់ៗអាចតម្រូវឱ្យបុគ្គលិកជាន់ខ្ពស់ផ្ដល់ព័ត៌មានបន្ថែម។

ព័ត៌មានដែលត្រូវផ្ដល់ជូនសមាជិកក្រុមប្រឹក្សាភិបាលមានដូចជា សាវតារឿង សេចក្ដីពន្យល់លម្អិតពាក់ព័ន្ធនឹងបញ្ហានានា ដែលត្រូវដាក់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ឯកសារផ្ដល់ព័ត៌មានថវិកាចម្បង បញ្ញាថវិកាក្រុមហ៊ុន ការព្យាករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ។ ពាក់ព័ន្ធនឹងបញ្ហាថវិកា ករណីដែលមានគំលាតណាមួយរវាងគម្រោង និងលទ្ធផលជាក់ស្ដែង គឺត្រូវធ្វើការបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់។

**ប្រការ ១៩.-**

អភិបាលត្រូវមានសិទ្ធិដូចខាងក្រោម ៖

១-ទទួលបាននូវរបៀបវារៈ និងព័ត៌មានទាន់ពេល ដើម្បីត្រៀមប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

២-ទទួលបានព័ត៌មានបច្ចុប្បន្នកម្មអំពីក្រុមហ៊ុន។

៣-ជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងសកម្មភាព ឬការសម្រេចចិត្តណាមួយរបស់ក្រុមប្រឹក្សាភិបាល ដោយតម្រូវឱ្យកត់ត្រាឱ្យបានច្បាស់លាស់នូវការបោះឆ្នោតជំទាស់។

៤-ស្នើនូវប្រធានបទពាក់ព័ន្ធណាមួយទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

៥-ជួបជាមួយនឹងបុគ្គលិកជាន់ខ្ពស់ណាម្នាក់តាមការចាំបាច់ ដោយឈរលើភាពសមស្របទៅវិញទៅមក។

៦-ទទួលបានយោបល់លើគ្រប់ភារកិច្ច។

៧-ទទួលបានប្រាក់បំណាច់ ឬលាភការសមរម្យ និងមានតម្លាភាព។

៨-ទទួលបានយោបល់ឯករាជ្យ ប្រសិនបើមានការស្នើសុំ។

**ប្រការ ២០.-**

អភិបាលត្រូវមានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

១-អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ក្រុមហ៊ុន។

២-ចូលរួមចំណែក និងអនុម័តលើផែនការយុទ្ធសាស្ត្រ។

៣-តាមដាននូវការអនុវត្តគោលនយោបាយ។

៤-ធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

៥-ទទួលខុសត្រូវចំពោះក្រុមហ៊ុន។

៦-ជ្រើសតាំងនាយកប្រតិបត្តិ។

៧-ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តាមរយៈការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ភាគហ៊ុនិក។

៨-ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត។

៩-ធានាថា ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមហ៊ុន។

១០-ធានានូវការសម្រេចបានគោលដៅរបស់ក្រុមហ៊ុន។

១១-ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធិភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។

**ប្រការ ២១.-**

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវចំពោះភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុន ព្រមទាំងចីរភាពនៃរបៀបប្រកួតប្រជែង ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងការ

ទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ហើយត្រូវធ្វើសកម្មភាពណាដែលបម្រើនូវផលប្រយោជន៍ទាំងស្រុងរបស់ក្រុមហ៊ុន និងភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា អភិបាលទទួលការបណ្ដុះបណ្ដាល ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវត្តនៃអភិបាលកិច្ចសាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលមានផលប៉ះពាល់ដល់ដំណើរការធុរកិច្ចក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលគួរបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំនូវព័ត៌មានស្ដីពីការបណ្ដុះបណ្ដាលអភិបាល។

**ប្រការ ២២.-**

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចធ្វើការវិនិច្ឆ័យ និងធ្វើសកម្មភាពដោយឯករាជ្យ និងប្រកាន់យកជំហានសមស្របនានា ដើម្បីធានាភាពរឹងមាំនៃការសម្រេចចិត្តរបស់ក្រុម-ប្រឹក្សាភិបាល។ កាតព្វកិច្ចទាំងនោះ រួមមាន ÷

១-ធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល និងភាគហ៊ុនិក។

២-ប្រើប្រាស់អំណាចឱ្យចំគោលដៅដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល។

៣-មិនត្រូវផ្ទេរអំណាច លើកលែងតែមានការអនុញ្ញាតត្រឹមត្រូវ និងមានភារកិច្ចដើម្បីអនុវត្ត។

៤-អនុវត្តការងារដោយប្រុងប្រយ័ត្ន ប្រកបដោយភាពជំនាញ និងភាពវាងវៃ។

៥-ដោះស្រាយរាល់ទំនាស់ផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ។

៦-មិនត្រូវធ្វើប្រតិបត្តិការណាដែលអភិបាលមានផលប្រយោជន៍ លើកលែងតែស្របតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត។

៧-មិនត្រូវកេងយកផលប្រយោជន៍ក្នុងមុខតំណែងជាអភិបាល។

៨-មិនត្រូវប្រើប្រាស់ខុសទិសដៅចំពោះព័ត៌មានដែលទទួលបានពីក្រុមហ៊ុន។

៩-មិនត្រូវទទួលយកអំណោយពីតតិយជន ដែលផ្ដល់ឱ្យដោយសារតែមុខតំណែងជាអភិបាល។

១០-អនុវត្តតាមលក្ខន្តិកៈក្រុមហ៊ុន និងសេចក្ដីសម្រេចផ្សេងៗរបស់ក្រុមហ៊ុន។

១១-ធ្វើសេចក្ដីប្រកាសអំពីទំនាស់ផលប្រយោជន៍របស់ខ្លួនដែលកើតមានពាក់ព័ន្ធនឹងក្រុមហ៊ុន។

**ប្រការ ២៣.-**

ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តក្រមសីលធម៌ សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ហើយត្រូវបង្ហាញជាសាធារណៈ។

**ប្រការ ២៤.-**

ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងលេខាធិការរបស់ក្រុមហ៊ុន ដើម្បីជាជំនួយការក្នុងការអនុវត្តការងារ។ លេខាធិការរបស់ក្រុមហ៊ុនត្រូវមានលក្ខណសម្បត្តិល្អ មានសញ្ជាតិខ្មែរ ជាបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដោយអនុវត្តការងារល្អ ស្មោះត្រង់ និងមានគោលជំហរនឹងនរពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន។

**ប្រការ ២៥.-**

លេខាធិការក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាភិបាល ហើយត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

១-ត្រូវបង្កើតទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់នានារបស់ក្រុមហ៊ុន។

២-ត្រូវគាំទ្រដល់កិច្ចដំណើរការការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣-ត្រូវធ្វើបច្ចុប្បន្នកម្មនូវរាល់ការវិវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាភិបាល និងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៤-ត្រូវធ្វើបច្ចុប្បន្នកម្មអំពីអភិបាលកិច្ចសាជីវកម្ម និងការវិវត្តនៃការទទួលខុសត្រូវសង្គម។

៥-ត្រូវបង្កលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីគាំទ្រដល់ដំណើរការនៃការសម្រេចចិត្ត។

៦-ត្រូវចាត់ចែង រៀបចំ នីតិវិធី និងរក្សាទុក កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក។

## ជំពូកទី ៤
## ការជ្រើសរើស និងការបញ្ឈប់តំណែងសមាជិកក្រុមប្រឹក្សាភិបាល

**ប្រការ ២៦.-**

នៅពេលដែលក្រុមហ៊ុនបង្កើតគណៈកម្មាធិការតែងតាំង រាល់ការជ្រើសតាំងបេក្ខភាពអភិបាលត្រូវធ្វើឡើងដោយគណៈកម្មាធិការតែងតាំងដូចមានចែងក្នុងប្រការ ៣៦ នៃប្រកាសនេះ។ ការជ្រើសតាំងត្រូវធ្វើឡើងតាមនីតិវិធីផ្លូវការ និងមានតម្លាភាព ដោយត្រូវធានានូវភាពត្រឹមត្រូវ និងឯករាជ្យ។

គណៈកម្មាធិការតែងតាំងត្រូវតែបញ្ចូលនូវនីតិវិធី ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចអាចស្នើឡើងនូវបេក្ខភាពអភិបាល។ អភិបាលទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិក។

**ប្រការ ២៧.-**

គណៈកម្មាធិការតែងតាំងត្រូវពិចារណាលើលក្ខខណ្ឌគុណវុឌ្ឍិរបស់បេក្ខភាពអភិបាលដូចខាងក្រោម ÷

១-នីត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព។

២-មានការប្ដេជ្ញាចិត្តខ្ពស់ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុននិងភាគហ៊ុនិក។

៣-មានពេលវេលា ថាមពល និងការគាំទ្រដើម្បីបំពេញគ្រប់ភារកិច្ច រួមមានការជួបប្រជុំ និងការចូលរួមសន្និសីទ។

៤-មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព។

៥-មានលទ្ធភាពអាចធ្វើការប្រកបដោយប្រសិទ្ធភាពឆ្ពោះទៅរកគោលដៅរួមរបស់ក្រុមហ៊ុន និងភាគហ៊ុនិក ។

៦-យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច។

៧-មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងវិស័យពាក់ព័ន្ធជាមួយនឹងមុខតំណែងរបស់ខ្លួន

៨-បង្ហាញអំពីភាពជាអ្នកដឹកនាំ។

៩-មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែលក្រុមហ៊ុនជួបប្រទះស្ថានភាពវិករ។

**ប្រការ ២៨.-**

គណៈកម្មាធិការតែងតាំងមិនអាចជ្រើសតាំងបេក្ខភាពអភិបាល នូវបុគ្គលដែលស្ថិតក្នុងស្ថានភាព ដូចខាងក្រោម ÷

១-បុគ្គលនោះធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ។

២-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ពន្ធ័នឹងការបំភាន់ ការកែបន្លំ ការក្លែងបន្លំ ការស្មុកស្មាញ ការរំលោភលើសេចក្តីទុកចិត្ត ការញុះញង់ ការសមគំនិត ឬការចូលរួមក្នុងការប្រព្រឹត្តអំពើល្មើសណាមួយ។

៣-បុគ្គលដែលតុលាការបានប្រកាសក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ ចុងក្រោយ។

៤-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការបរទេស ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស។

៥-បុគ្គលដែលជាប់ពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ២៩.-**

អភិបាលមិនត្រូវបានបញ្ឈប់ពីតំណែង ឬត្រូវបានបណ្តេញចេញ ដោយគ្មានមូលហេតុត្រឹមត្រូវ និងសមស្របឡើយ និងត្រូវជូនដំណឹងជាមុនទៅអភិបាលនោះដើម្បីជ្រាបជាព័ត៌មាន។

មូលដ្ឋានសម្រាប់ការបញ្ឈប់ ឬការបណ្តេញចេញពីតំណែង រួមមាន ÷

១-ការមិនបង្ហាញព័ត៌មានពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។

២-ករណីអវត្តមាន ឬមិនបានចូលរួមទាំងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិកលើសព ៥០ (ហាសិប) ភាគរយឡើងទៅ ក្នុង ០១ (មួយ) ឆ្នាំសារពើពន្ធ ទោះបីក្នុងហេតុផលអ្វីក៏ដោយ។

៣-ករណីត្រូវបានព្យួរ បញ្ឈប់ ឬបណ្តេញចេញពីតំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយ។

៤-អភិបាលឯករាជ្យបានក្លាយជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់ក្រុមហ៊ុន។

៥-អភិបាលឯករាជ្យមានភាគហ៊ុនរបស់ក្រុមហ៊ុនលើសពី ០១ (មួយ)ភាគរយឡើងទៅ។

៦-ត្រូវបានផ្តន្ទាទោសពីបទល្មើសណាមួយ ដូចមានចែងក្នុងប្រការ ២៨។

## ជំពូកទី ៥

## អភិបាលឯករាជ្យ

**ប្រការ ៣០.-**

អភិបាលឯករាជ្យត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ៖

១-មិនត្រូវបានជួលដោយក្រុមហ៊ុន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

២-មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់ក្រុមហ៊ុន។

៣-មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយក្រុមហ៊ុន ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន។

៤-មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយដែលធ្លាប់ទទួលមូលនិធិពីក្រុមហ៊ុន។

៥-មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គលដែលធ្លាប់ធ្វើជាអភិបាលឱ្យក្រុមហ៊ុន ឬធ្លាប់បានជួលដោយក្រុមហ៊ុន ឱ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

៦-មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឱ្យក្រុមហ៊ុន ។

**ប្រការ ៣១.-**

អភិបាលឯករាជ្យត្រូវមានកាតព្វកិច្ចចូលរួមនៅគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់ក្រុមហ៊ុន ព្រមទាំងត្រូវតាមដានត្រួតពិនិត្យ និងគាំទ្រដល់បុគ្គលិកជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ថា អភិបាលឯករាជ្យមិនមានទំនាក់ទំនងសំខាន់ជាមួយបុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកដទៃទៀត ដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យ ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុន និងបំពេញនូវតួនាទី ដូចខាងក្រោម ៖

១-ចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយនាំមកនូវការសម្រេចចិត្តឯករាជ្យទៅលើបញ្ហានានា ដូចជា យុទ្ធសាស្ត្រ គោលនយោបាយ ការអនុវត្ត គណនេយ្យភាព ធនធាន ការជ្រើសតាំងបុគ្គលិកជាន់ខ្ពស់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការដឹកនាំ។

២-ត្រូវឈានមុខគេក្នុងការដោះស្រាយ និងទប់ស្កាត់នូវទំនាស់ផលប្រយោជន៍ជាសក្តានុពលដែលនឹងអាចកើតឡើង។

៣-បម្រើការងារក្នុងគណៈកម្មាធិការនានា ដូចជា គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង ប្រសិនបើមាន ព្រមទាំងគណៈកម្មាធិការផ្សេងៗទៀត។

៤-ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការអនុវត្តរបស់ក្រុមហ៊ុន ដើម្បីសម្រេចបានតាមគោលបំណង និងគោលដៅដែលបានឯកភាព និងតាមផែនការអនុវត្តការងារ។

**ប្រការ ៣២. –**

អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ ដែលនាំឱ្យរារាំងដល់ឯករាជ្យភាពរបស់ខ្លួនឡើយ។

អភិបាលឯករាជ្យ ÷

១-មិនត្រូវកាន់កាប់ភាគហ៊ុនក្រុមហ៊ុនលើសពី ០១ (មួយ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនឡើយ។

២-ត្រូវដាក់លិខិតបញ្ជាក់ថា មិនមានផលប្រយោជន៍សំខាន់ណាមួយនៅក្នុងក្រុមហ៊ុននៅពេលត្រូវបានតែងតាំង។

បុគ្គលមិនមានគុណវុឌ្ឍិជាអភិបាលឯករាជ្យ ប្រសិនបើខ្លួនគេ ឬសមាជិកគ្រួសាររបស់គេត្រូវបាន ÷

ក-ផ្តល់ឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ខ-បម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុន។

គ-កំពុងបម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុនដែលចូលរួមធ្វើសវនកម្មក្រុមហ៊ុននោះ ឬធ្លាប់បានធ្វើសវនកម្មផ្ទាល់លើក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ឃ-កំពុងបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនធានារ៉ាប់រងដែលកំពុងធានារ៉ាប់រងឱ្យក្រុមហ៊ុននោះ។

ង-ផ្តល់ឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលបុគ្គលិកជាន់ខ្ពស់នោះធ្លាប់ជាសមាជិកគណៈកម្មាធិការតបស្នងរបស់ក្រុមហ៊ុននោះ។

ច-បម្រើការងារជាបុគ្គលិកជាន់ខ្ពស់របស់អង្គភាព ឬអង្គការដែលទទួលបានវិភាគទានពីក្រុមហ៊ុន។

## ជំពូកទី ៦
## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

**ប្រការ ៣៣.-**

ដើម្បីធានានូវអភិបាលកិច្ចសាជីវកម្មល្អ ក្រុមប្រឹក្សាភិបាលត្រូវបង្កើតនូវគណៈកម្មាធិការមួយចំនួន ដូចខាងក្រោម ÷

-គណៈកម្មាធិការសវនកម្ម

-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ករណីទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈមានចំនួនចាប់ពី ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល។ ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល អាចបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅតាមការចាំបាច់។

ដោយឡែក ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការផ្សេងទៀត ទៅតាមការចាំបាច់ និងតាមការណែនាំរបស់ **គ.ម.ក.**។

**ប្រការ ៣៤.-**

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេសនិងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម ÷

-ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

-ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មខាងក្រៅ

-រាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

**ប្រការ ៣៥.-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវមានតួនាទីគន្លឹះក្នុងការគ្រប់គ្រងហានិភ័យ នៅក្នុងកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន។ គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិច ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ ឬគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ តួនាទី និងភារកិច្ចអាចមានជាអាទិ៍ ដូចខាងក្រោម ÷

-ការវិភាគហានិភ័យ (Risk Analysis) រួមមាន ការពិពណ៌នាហានិភ័យ (Risk Description) ការកំណត់អត្តសញ្ញាណហានិភ័យ (Risk Identification) ការប៉ាន់ស្មានអំពីហានិភ័យ (Risk Estimation)

-ការវាយតម្លៃអំពីហានិភ័យ (Risk Evaluation)

-ការរាយការណ៍អំពីហានិភ័យ (Risk Reporting)

-ការលើកវិធានការទប់ទល់ហានិភ័យ (Risk Treatment)

-ការតាមដានអំពីហានិភ័យ (Risk Monitoring)

ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិការសវនកម្ម។

**ប្រការ ៣៦.-**

ករណីដែលមានគណៈកម្មាធិការតែងតាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលសមាជិកទាំងអស់ត្រូវតែជាអភិបាលមិនប្រតិបត្តិ ដោយក្នុងនោះត្រូវមានសមាជិកយ៉ាងតិច ០១ (មួយ) រូប ជាអភិបាលឯករាជ្យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវការពិនិត្យ និងការវាយតម្លៃអំពីគុណវឌ្ឍិបេក្ខភាពអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការតែងតាំងអាចមានការទទួលខុសត្រូវផងដែរ ចំពោះការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។

## ជំពូកទី ៧
## ការត្រួតពិនិត្យ និងសវនកម្ម

**ប្រការ ៣៧.-**

ក្រុមប្រឹក្សាភិបាលត្រូវមានគណនេយ្យភាពចំពោះភាគហ៊ុនិក ហើយបុគ្គលិកជាន់ខ្ពស់ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ជូនភាគហ៊ុនិកនូវការវាយតម្លៃប្រចាំឆមាស ឬការកំណត់ផ្សេងទៀតដោយ **គ.ម.ក.** ឬវិធាននៃការចុះបញ្ជីលក់មូលបត្រ ដែលអាចទទួលយកបាន និងមានតុល្យភាព អំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។ បុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវការវាយតម្លៃប្រចាំត្រីមាសដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន ហើយត្រូវតែរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជារៀងរាល់ខែ អំពីហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុន។

**ប្រការ ៣៨.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃ-ក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងត្រូវមានការទទួលខុសត្រូវ និងភារកិច្ច ដូចខាងក្រោម ÷

១-បង្ហាញពីការវាយតម្លៃដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។

២-រាយការណ៍អំពីដំណើរការធុរកិច្ចរបស់ក្រុមហ៊ុន និងបញ្ហាជាសក្តានុពល។

៣-រក្សាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីការពារផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៤-អនុវត្តការស៊ើបអង្កេតសវនកម្មផ្ទៃក្នុងគ្របដណ្តប់ទៅលើការវាយតម្លៃពីភាពសម-ស្រប និងប្រសិទ្ធភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូលទាំងការការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ។

៥-ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំស្តីអំពីសកម្មភាពពាក់ព័ន្ធនឹងផែនការសវនកម្ម និងយុទ្ធសាស្ត្រដែលបានទទួលការយល់ព្រម

ពីគណៈកម្មាធិការសវនកម្ម។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលទាំងការប្រឈមហានិភ័យ បញ្ហាត្រួតពិនិត្យ បញ្ហាអភិបាលកិច្ចសាជីវកម្ម និងបញ្ហាដទៃទៀតដែលស្នើដោយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។ គណៈកម្មាធិការសវនកម្មត្រូវតែផ្តល់របាយការណ៍ឱ្យភាគហ៊ុនិករបស់ក្រុមហ៊ុន ដែលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

៦-គណៈកម្មាធិការសវនកម្មត្រូវធានាថាសវនករផ្ទៃក្នុងមានសិទ្ធិទទួលបានព័ត៌មានទាំងស្រុងអំពីកំណត់ត្រា ទ្រព្យ និងបុគ្គលិកពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម និងធានាថាសកម្មភាពសវនកម្មផ្ទៃក្នុង មិនទទួលរងការជ្រៀតជ្រែកក្នុងការកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ ការអនុវត្តការងារ និងការបញ្ជូនលទ្ធផលនៃការត្រួតពិនិត្យ។

**ប្រការ ៣៩.-**

ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម ÷

១-មានសញ្ញាបត្រកម្រិតឧត្តមសិក្សាឡើងទៅដោយមានការបណ្តុះបណ្តាល ព្រមទាំងបទពិសោធន៍ខាងសវនកម្ម។

២-មានចំណេះដឹងស្តីពីបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៣-មានសមត្ថភាពក្នុងការដឹកនាំ និងចាត់ចែងបុគ្គលិកសវនកម្ម។

៤-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដារពាក់ពន្ធ័នឹងសវនកម្ម។

៥-មានជំនាញទំនាក់ទំនងល្អក្នុងការងារ។

៦-មានភាពស្មោះត្រង់ និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ ៤០.-**

ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវអនុវត្តការងារដែលបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ÷

១-របាយការណ៍សវនកម្មដែលធ្វើដោយសវនករផ្ទៃក្នុងត្រូវផ្ញើទៅឱ្យគណៈកម្មាធិការសវនកម្ម ព្រមទាំងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ និងបុគ្គលិកជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងផ្នែកដែលត្រូវបានធ្វើសវនកម្ម។

២-រាល់ការរកឃើញនានាដែលអាចមានផលប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុនត្រូវបញ្ជូនទៅឱ្យគណៈកម្មាធិការសវនកម្ម។

៣-ត្រូវជួបជាមួយគណៈកម្មាធិការសវនកម្មយ៉ាងហោចណាស់ ០១ (មួយ) ផង ក្នុង ០១ (មួយ) ឆ្នាំ ដោយពុំចាំបាច់មានវត្តមានរបស់បុគ្គលិកជាន់ខ្ពស់ ។

៤-អនុវត្តការងារផ្សេងទៀតដែលគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាលប្រគល់ជូន។

**ប្រការ ៤១.-**

សវនកម្មហិរញ្ញវត្ថុត្រូវអនុវត្តដោយសវនករឯករាជ្យដែលជ្រើសរើសដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់គណៈកម្មាធិការសវនកម្មក្នុងចំណោមក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលស្គាល់ដោយ **គ.ម.ក.**។ អន្តរកម្មរវាងក្រុមហ៊ុនសាមី និងសវនករឯករាជ្យត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការសវនកម្ម។ ដើម្បីកម្រិតហានិភ័យនៃទំនាស់ផលប្រយោជន៍ រាល់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម និងកម្រៃដែលត្រូវបង់ទៅឱ្យសវនករឯករាជ្យសម្រាប់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម ត្រូវតែទទួលបានការយល់ព្រមជាមុនពីគណៈកម្មាធិការសវនកម្ម ហើយត្រូវបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវផ្លាស់ប្តូរក្រុមហ៊ុនគណនេយ្យជំនាញដែលធ្វើសវនកម្ម ក្នុងរយៈពេលមិនលើសពី ០៣ (បី) ឆ្នាំ។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ មិនត្រូវប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលឡើងវិញ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីកិច្ចសន្យាប្រើប្រាស់សេវាកម្មមុនត្រូវបានបញ្ចប់។ ក្នុងគោលបំណងជៀសវាងនូវទំនាស់ផលប្រយោជន៍ ក្រុមហ៊ុនគណនេយ្យជំនាញមិនត្រូវផ្តល់សេវាកម្ម ដូចជា សវនករផ្ទៃក្នុង សេវាកម្មបញ្ជិកាគណនេយ្យ ការបង្កើតនិងអនុវត្តន៍ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ សេវាកម្មវាយតម្លៃ សេវាកម្មពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិករបស់ក្រុមហ៊ុន និងសេវាកម្មផ្សេងទៀតដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ ៤២.-**

រាល់ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកសេវាកម្មសវនកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញត្រូវមានការបញ្ជាក់នូវហេតុផលឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ភ្លាមក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ របាយការណ៍ប្រចាំឆ្នាំត្រូវបញ្ចូល ការពិភាក្សាអំពីការមិនយល់ស្របរបស់

អតីតក្រុមហ៊ុនគណនេយ្យជំនាញទៅលើបញ្ហាគោលការណ៍ និងការអនុវត្តគណនេយ្យ ទៅលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងវិសាលភាពនៃសវនកម្ម ឬលើនីតិវិធីសវនកម្ម ដែលមិនមានដំណោះស្រាយធ្វើឱ្យពេញចិត្តអតីតក្រុមហ៊ុនគណនេយ្យជំនាញ។

**ប្រការ ៤៣.-**

សវនករឯករាជ្យត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១-ត្រូវផ្តល់នូវទស្សនៈឯករាជ្យ និងប្រាកដនិយមថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុន ស្របទៅតាមស្តង់ដាររបាយ-ការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវអនុវត្តតាមស្តង់ដារសវនកម្ម ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណា-ចក្រកម្ពុជា។

## ជំពូកទី ៨
## ភាគីពាក់ព័ន្ធ

**ប្រការ ៤៤.-**

ឥណទាយក បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬមានកិច្ចសន្យាជាមួយក្រុមហ៊ុន ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ រាល់ភាគីពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុនត្រូវទទួលបាននូវការការពារសិទ្ធិ។ ក្រុមហ៊ុនត្រូវធានាការការពារសិទ្ធិដល់ភាគីពាក់-ព័ន្ធជាអាទិ៍ ដូចខាងក្រោម ៖

១-ត្រូវមានគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីគាំទ្រ និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

២-ត្រូវធានាការអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

៣-មិនត្រូវធ្វេសប្រហែសចំពោះការទទួលខុសត្រូវសង្គម ដូចជាការការពារអ្នកប្រើ-ប្រាស់ និងការការពារបរិស្ថាន។

៤-ទទួលស្គាល់ និងការពារសិទ្ធិដាច់ចេញពីគ្នានៅពេលដែលបុគ្គលជាភាគីពាក់ព័ន្ធ និងជាភាគហ៊ុនិក។

**ប្រការ ៤៥.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យភាគីពាក់ព័ន្ធដូចជា ឥណទាយក និងនិយោជិត នូវព័ត៌មានពាក់ព័ន្ធដែលចាំបាច់ដើម្បីតាមដាននូវដំណើរការរបស់ក្រុមហ៊ុន ព្រមទាំងត្រូវការពារសិទ្ធិរបស់ពួកគេ។

## ជំពូកទី ៩
## ការបង្ហាញព័ត៌មាន និងតម្លាភាព

**ប្រការ ៤៦.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុនតាមរយៈយន្តការទីផ្សារ ដូចជា ៖

១-យន្តការត្រូវធ្វើឡើងតាមរយៈនីតិវិធីប្រកបដោយយុត្តិធម៌ និងមានតម្លាភាពនៅពេលដែលមានសកម្មភាពនាំឱ្យមានការផ្លាស់ប្តូរក្នុងការត្រួតត្រាក្រុមហ៊ុន ដូចជា ការទទួលកាន់កាប់បន្ត (Takeovers) ការរួមបញ្ចូល (Mergers) ការទិញយក (Acquisitions) និងការផ្ទេរអាជីវកម្ម (Transfers of business)។

២-យន្តការទាក់ទងនឹងសកម្មភាពការពារក្រុមហ៊ុនឱ្យផុតពីការការត្រួតត្រា ដោយធ្វើយ៉ាងណាសកម្មភាពការពារនោះមិនត្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។ ប្រសិនបើសកម្មភាពការពារនោះតម្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក ការលះបង់ផលប្រយោជន៍នោះត្រូវមានការយល់ព្រមពីភាគហ៊ុនិក។

៣-យន្តការចាំបាច់នានាក្នុងការចាត់វិធានការប្រឆាំងនឹងការទទួលកាន់កាប់បន្តអមិត្ត (Hostile takeovers) ដូចជា ការទិញភាគហ៊ុនត្រឡប់មកវិញក្នុងបំណង ដើម្បីការពារការត្រួត-ត្រាក្រុមហ៊ុនដែលការទិញភាគហ៊ុនត្រឡប់មកវិញនេះត្រូវធ្វើការប្រកាសឱ្យបានលម្អិត ដើម្បីឱ្យភាគីពាក់ពន្ធ័យល់ដឹងពីហេតុផលនិងអាចព្យាករណ៍បាននូវផលវិបាកដែលអាចកើតឡើង។

**ប្រការ ៤៧.-**

ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ទាន់ពេល និងមានប្រសិទ្ធភាព ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ និងពត៌មានផ្សេងទៀតដែលអាចមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគហ៊ុនិក និងភាគីពាក់ពន្ធ័ដទៃទៀត។

ព័ត៌មានសំខាន់ៗដែលទាក់ទងនឹងអភិបាលកិច្ចសាជីវកម្ម ដែលក្រុមហ៊ុនត្រូវបង្ហាញរួមមាន ÷

១-សមាសភាពក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ អភិបាលឯករាជ្យ របនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល របនាសម្ព័ន្ធគ្រប់គ្រង គោលនយោបាយលើកទឹកចិត្ត គោលនយោបាយពាក់ព័ន្ធទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

២-សិទ្ធិ តួនាទី និងភារកិច្ច និងសកម្មភាពនៃគណៈកម្មាធិការនានារបស់ក្រុម-ប្រឹក្សាភិបាល។

៣-សកម្មភាពរបស់អភិបាលម្នាក់ៗ និងក្រុមប្រឹក្សាភិបាល។

៤-ដំណើរការប្រព័ន្ធបោះឆ្នោតត្រួត ករណីទទួលបានការអនុម័តពីភាគហ៊ុនិក។

**ប្រការ ៤៨.** –

ក្រុមហ៊ុនត្រូវរៀបចំព័ត៌មានដើម្បីធ្វើការបង្ហាញក្នុងទម្រង់ងាយយល់ ដោយជៀសវាងការប្រើប្រាស់ពាក្យដែលមានន័យមិនច្បាស់លាស់ និងពាក្យបច្ចេកទេសស្មុគស្មាញ។ ការបង្ហាញព័ត៌មានជាសាធារណៈត្រូវធ្វើយ៉ាងណាងាយទទួលបាន និងមានតម្លៃទាប។ ចំពោះពាក្យបច្ចេកទេសស្មុគស្មាញទាំងនោះ ក្រុមហ៊ុនត្រូវរៀបចំឱ្យមានការពន្យល់ភ្ជាប់មកជាមួយដើម្បីឱ្យសាធារណជនទូទៅបានយល់។

ករណីឯកសារដែលត្រូវបង្ហាញធ្វើឡើងជាភាសាបរទេសក្រុមហ៊ុនត្រូវតែរៀបចំបកប្រែឯកសារទាំងនោះមកជាភាសាខ្មែរដោយភ្ជាក់ងារបកប្រែដែលទទួលស្គាល់ដោយ **គ.ម.ក.**។

ក្រុមហ៊ុនត្រូវចាត់តាំងបុគ្គលិកម្នាក់ ដើម្បីទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន រួមទាំងការរាយការណ៍ទៅទីផ្សារ និង **គ.ម.ក.** ដោយក្រុមប្រឹក្សាភិបាល និងត្រូវមានប្រពន្ធ័ត្រួតពិនិត្យព័ត៌មានផ្ទៃក្នុង (Internal Information Control System) ដែលអាចបញ្ជូនព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុនឱ្យបានឆាប់រហ័សដល់បុគ្គលិកនោះ។ ដើម្បីបញ្ជូនព័ត៌មានដល់សាធារណជនឱ្យបានទាន់ពេល ត្រឹមត្រូវ និងមានប្រសិទ្ធភាព បុគ្គលិកដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានត្រូវមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗរបស់ក្រុមហ៊ុន។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**ប្រការ ៤៩. –**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការរដ្ឋបាល ដូចខាងក្រោម ÷

-ការព្រមាន

-ការណែនាំឱ្យកែតម្រូវកំហុស

-ការព្យួរជាបណ្ដោះអាសន្ន ឬការបញ្ឈប់ការងាររបស់អភិបាល និង/ឬ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

-ការព្យួរ ឬការលុបចោលការចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន

-ការព្យួរ ឬការបញ្ឈប់ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្របុព្វមិស្ទុត។

**ប្រការ ៥០. –**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៥១. –**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ភាគី ឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងសាធារណជន។

**ប្រការ ៥២. –**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៣.** –

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ